សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការលើកកម្ពស់ស្ថានភាពស្ត្រីកម្ពុជានៅក្នុងវិស័យសេដ្ឋកិច្ច

ស្រាវជ្រាវពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. សួត៍ បុប្ផារត្ន័**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **សឿន សោភ័ណ**


ថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ

ជំនាន់ទី ៩

ឆ្នាំចូលសិក្សា ២០១២

ឆ្នាំសរសេរសារណា ២០១៦

# លិខិតថ្លែងអំណរគុណ

ជាបឋម នាងខ្ញុំ **សូត្រ បុប្ផារត្ន័** ជានិស្សិត បរិញ្ញាបត្រជំនាញរដ្ឋបាលសាធារណៈ ជំនាន់ទី៩ ឆ្នាំសិក្សា២០១២-២០១៦ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ៖

- លោកឪពុក និងអ្នកម្តាយដែលបានផ្តល់កំណើតដល់កូន និងខិតខំបីបាច់ថែរក្សា អប់រំទូន្មានកូនដោយជួយទំនុកបម្រុងកូន ឲ្យបានទទួលបានការអប់រំដ៏ខ្ពង់ខ្ពស់រហូតមកដល់សព្វថ្ងៃនេះ ប្រកបដោយទឹកចិត្តដ៏ថ្លៃថ្លាគួរជាទីមោទនៈ។

- លោក ពូ អ្នកមីង បងប្រុស និងបងស្រី ដែលបានជួយទំនុកបម្រុងផ្នែកសម្ភារៈ និងស្មារតី ដោយផ្តល់នូវការលើកទឹកចិត្ត ដល់រូបនាងខ្ញុំឲ្យខិតខំរៀនសូត្ររហូតមកដល់ពេលនេះ។

- ថ្នាក់ដឹកនាំលោក លោកស្រីសាស្ត្រាចារ្យទាំងអស់ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀនដល់នាងខ្ញុំ យ៉ាងយកចិត្តទុកដាក់លើគ្រប់មុខវិជ្ជាទាំងអស់ដែលធ្វើឲ្យនាងខ្ញុំ ទទួលបាននូវចំណេះដឹង ដើម្បីជាពន្លឺ បំភ្លឺនាថ្ងៃអនាគត។

- ជាពិសេស លោកសាស្ត្រាចារ្យ **បណ្ឌិត សឿន សោភណ៌** ដែលបានលះបង់ពេលវេលាដ៏មានតម្លៃរបស់លោក ក្នុងការណែនាំ និងបង្ហាត់បង្រៀនលក្ខណៈយ៉ាងស្រួលដល់នាងខ្ញុំ ក្នុងការសរសេរសារណានេះឡើង។ប្រសិនបើមិនមានវត្តមានរបស់លោកសាស្ត្រាចារ្យទេ នាងខ្ញុំក៏មិនអាចសម្រេចចេញនូវស្នាដៃដ៏ល្អមួយនេះទេ។

- **អ្នកស្រី គង់សាឡុន**ដែលជាប្រធានមន្ទីរកិច្ចការនារីខេត្តព្រៃវែង និង**កញ្ញាម៉ារីគេន ប៊ី. ហាប៊ីត** មន្ត្រីផ្នែកទំនាក់ទំនងរបស់អង្គការសហប្រជាជាតិគាំទ្រសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រីប្រចាំកម្ពុជា ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការផ្តល់កិច្ចសម្ភាសដល់រូបនាងខ្ញុំ។

ជាចុងក្រោយ នាងខ្ញុំសូមបួងសួងដល់បារមីនៃវត្ថុសាកសិទ្ធិទាំងពួងនៅលើពិភពលោកយើងនេះសូមជួយថែរក្សាលោកអ្នកមានគុណទាំងពីរ បងប្រុស បងស្រី ថ្នាក់ដឹកនាំ សាស្ត្រាចារ្យរបស់សាកល វិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អ្នកស្រីប្រធានមន្ទីរ និងមន្ត្រីទំនាក់ទំនងរបស់អង្គការសហប្រជាជាតិ ឲ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើនគ្រប់ពេលវេលា កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ស្ត្រីនៅកម្ពុជាមានចំនួនប្រមាណជា៥១%នៃប្រជាជនសរុប ដែលត្រូវបានចាត់ទុកជាឆ្អឹងខ្នងនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ ដូច្នេះការលើកកម្ពស់ស្ថានភាពស្ត្រីកម្ពុជានៅក្នុងវិស័យសេដ្ឋកិច្ចគឺជាកត្តាស្នូលក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិ។ ពិសេសការចូលរួមលុបបំបាត់វិសមភាពយេនឌ័រ ការបង្កើនភាពអង់អាចដល់ស្ត្រី និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

ការសិក្សាស្រាវជ្រាវស្ដីពី **ការលើកកម្ពស់ស្ថានភាពស្ត្រីកម្ពុជានៅក្នុងវិស័យសេដ្ឋកិច្ច** នឹងផ្ដល់ជាប្រភពចំណេះដឹងដ៏សំខាន់ដល់ប្រជាជនកម្ពុជា ក៏ដូចអ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយនូវច្បាប់ និងគោលនយោបាយសំខាន់ៗដែលបានចូលរួមលើកកម្ពស់សិទ្ធិ និងស្ថានភាពស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច។ ជាពិសេសគឺការវិភាគទៅលើបញ្ហាប្រឈមដែលជាឧបសគ្គរបស់ស្ត្រីនៅក្នុងវិស័យនេះដែលមនុស្សភាគច្រើនបានមើលរំលង និងមិនយកចិត្ត សូម្បីតែស្ត្រីកម្ពុជាចំនួនផ្ទាល់។ អ្វីដែលសំខាន់ជាងនេះទៀត គឺជំរុញឲ្យសង្គម និងស្ត្រីកម្ពុជាយល់ដឹងពីសារៈសំខាន់របស់ខ្លួនក្នុងចូលរួមនៅក្នុងវិស័យសេដ្ឋកិច្ច នៅក្នុងគោលបំណងជំរុញការលូតលាស់កំណើនសេដ្ឋកិច្ច ដើម្បីសុខដុមរមនារបស់ប្រជាជននៅក្នុងប្រទេសកម្ពុជា។

ដោយសារតែនេះគឺជា ឯកសារដែលបានស្រាវជ្រាវជាលើកដំបូងរបស់នាងខ្ញុំ ដូច្នេះប្រាកដជាមានការខ្វះចន្លោះ និងកំហុសមួយចំនួនជាក់ជាពុំខាន។ ហេតុនេះហើយ នាងខ្ញុំរង់ចាំទទួល នូវការរិះគន់ ដោយក្ដីសោមនស្សរីករាយគ្រប់ពេលវេលា ដើម្បីកែលម្អក្នុងន័យស្ថាបនា ចំពោះស្នាដៃមួយនេះ។

នាងខ្ញុំសូមសម្ដែងនូវសេចក្ដីគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះចិត្តអ្នកអានទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីអានឯកសារមួយនេះ។លើសពីនេះទៅទៀត ក្នុងនាមនាងខ្ញុំផ្ទាល់ជាអ្នកស្រាវជ្រាវ ក៏ដូចជាអ្នករៀបរៀង សូមគោរពជូនពរអ្នកទាំងអស់គ្នា ឲ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ ជូនដល់អ្នកទាំងអស់រាល់គ្នាកុំបីខាន។

# មាតិកា


**សេចក្តីផ្តើម** ........................................................ ១

**ជំពូកទី១ កិច្ចចូលរួមលើកកម្ពស់សិទ្ធិ និងស្ថានភាពស្ត្រីកម្ពុជា** ........................................................ ៦

**១.១. មូលដ្ឋានគតិយុត្តទាក់ទងនឹងការលើកកម្ពស់សិទ្ធិ និងស្ថានភាពស្ត្រី** ........................................................ ៦

**១.១.១. ច្បាប់ជាតិ** ........................................................ ៦

១.១.១.១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ........................................................ ៦

១.១.១.២. ច្បាប់ស្តីពីការងារ ........................................................ ៧

១.១.១.៣. ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ........................................................ ៧

១.១.១.៤. ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ........................................................ ៨

១.១.១.៥. ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ........................................................ ៨

**១.១.២. ច្បាប់អន្តរជាតិ** ........................................................ ៩

១.១.២.១. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ........................................................ ៩

១.១.២.២. អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ ........................................................ ១០

១.១.២.៣. សេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងប៉េកាំង ........................................................ ១១

**១.២. បរិបទគោលនយោបាយ** ........................................................ ១២

**១.២.១. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣** ........................................................ ១២

**១.២.២. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨** ........................................................ ១៣

**១.២.៣. ផែនការយុទ្ធសាស្ត្រនារីរតនៈ** ........................................................ ១៣

**១.២.៤. ក្របខណ្ឌពន្លឿនគោលដៅសហស្សវត្សរ៍** ........................................................ ១៥

**១.២.៥. គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព** ........................................................ ១៦

**១.៣. ស្ថាប័នចូលរួមលើកកម្ពស់សិទ្ធិ និងស្ថានភាពស្ត្រីកម្ពុជា** ........................................................ ១៧

**១.៣.១. ស្ថាប័នថ្នាក់ជាតិ** ........................................................ ១៧

១.៣.១.១. ក្រសួងកិច្ចការនារី ........................................................ ១៧

១.៣.១.២. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ........................................................ ២០

១.៣.១.៣. ក្រុមការងារបញ្ជ្រាបយេនឌ័រតាមក្រសួង ស្ថាប័ន ........................................................ ២១

**១.៣.២. ស្ថាប័នថ្នាក់ក្រោមជាតិ** ........ ២១

១.៣.២.១. មន្ទីរកិច្ចការនារីរាជធានី ខេត្ត និងការិយាល័យកិច្ចការនារីក្រុង ស្រុក ខណ្ឌ ........ ២១

**១.៣.៣. ស្ថាប័នសង្គមស៊ីវិល** ........ ២៣

១.៣.៣.១. គណៈកម្មាធិការទទួលបន្ទុកស្ថានភាពស្ត្រី ........ ២៤

១.៣.៣.២. គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ........ ២៤

១.៣.៣.៣. អង្គការសហប្រជាជាតិគាំទ្រសមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី ........ ២៥

**ជំពូក២ ស្ថានភាពបច្ចុប្បន្នរបស់ស្ត្រីកម្ពុជាក្នុងវិស័យសេដ្ឋកិច្ច** ........ ២៩

**២.១. ការចូលរួមរបស់ស្ត្រីនៅក្នុងសកម្មភាពសេដ្ឋកិច្ច** ........ ២៩

**២.២. អត្ថប្រយោជន៍របស់ស្ត្រីពីការអភិវឌ្ឍន៍សេដ្ឋកិច្ច** ........ ៣១

**២.២.១. ស្ត្រីនៅក្នុងវិស័យកសិកម្ម** ........ ៣១

**២.២.២. ស្ត្រីនៅក្នុងការងារអាជីវកម្ម** ........ ៣១

**២.២.៣. ស្ត្រីនៅក្នុងការងារដែលមានប្រាក់កម្រៃ** ........ ៣៣

**២.៣. សម្លេងរបស់ស្ត្រី និងតួនាទីក្នុងការធ្វើសេចក្តីសម្រេច** ........ ៣៣

**២.៣.១. ស្ថាប័ននីតិប្បញ្ញត្តិ** ........ ៣៤

២.៣.១.១. ស្ថាប័នព្រឹទ្ធសភា ........ ៣៤

២.៣.១.២. ស្ថាប័នរដ្ឋសភា ........ ៣៥

**២.៣.២. ស្ថាប័ននីតិប្រតិបត្តិ** ........ ៣៥

**២.៣.៣. ស្ថាប័នតុលាការ** ........ ៣៦

**២.៣.៤. ស្ត្រីនៅក្នុងមុខងារសាធារណៈ** ........ ៣៦

**ជំពូក៣ បញ្ហាប្រឈមរបស់ស្ត្រីកម្ពុជានៅក្នុងវិស័យសេដ្ឋកិច្ច និងដំណោះស្រាយ** ........ ៤០

**៣.១. បញ្ហាប្រឈមរបស់ស្ត្រីកម្ពុជាក្នុងវិស័យសេដ្ឋកិច្ច** ........ ៤០

**៣.១.១. កម្រិតអក្ខរកម្ម និងចំណេះដឹងទាប** ........ ៤០

**៣.១.២. បញ្ហានៅក្នុងការអភិវឌ្ឍន៍អាជីវកម្ម** ........ ៤១

**៣.១.៣. បញ្ហាកសិកម្ម និងជីវភាពរស់នៅជនបទ** ........ ៤២

**៣.១.៤. ស្ត្រីនៅក្នុងការងារមានប្រាក់កម្រៃ** ........ ៤៥

**៣.១.៥. បញ្ហាស្ត្រីពលករទេសន្តរប្រវេសន៍ក្នុង និងក្រៅប្រទេស** ............ ៤៦
**៣.១.៦. បញ្ហាការអនុវត្តច្បាប់ គោលនយោបាយ ផែនការ និងកម្មវិធី** ............ ៤៧
**៣.២. ដំណោះស្រាយ** ............ ៤៨
**៣.២.១. ដំណោះស្រាយរបស់រាជរដ្ឋាភិបាល** ............ ៤៨
៣.២.១.១. ការបង្កើត និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីស្តីពីការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ............ ៤៨
៣.២.១.២. ការបញ្ជ្រាបយេនឌ័រទៅក្នុងកម្មវិធីកម្រែទម្រង់សំខាន់ៗរបស់រដ្ឋាភិបាល ............ ៤៩
៣.២.១.៣. ការលើកកម្ពស់ការសិក្សា និងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ស្ត្រី ............ ៥១
៣.២.១.៤. ជំរុញការបង្កើត និងការអភិវឌ្ឍន៍សហគ្រាសខ្នាតមីក្រូ តូច និងមធ្យមរបស់ស្ត្រី ............ ៥២
៣.២.១.៥. ការបង្កើនកាលានុវត្តភាពការងារ និងលក្ខ័ខណ្ឌការងារសម្រាប់ស្ត្រី ............ ៥៣
៣.២.១.៦. ការកាត់បន្ថយបញ្ហាប្រឈមរបស់ស្ត្រីនៅក្នុងវិស័យកសិកម្ម និងការអភិវឌ្ឍន៍ជីវភាពរស់ជនបទ ............ ៥៤
**៣.២.២. ដំណោះស្រាយរបស់សង្គមស៊ីវិល** ............ ៥៥
៣.២.២.១. ការគាំទ្រមតិ និងមូលនិធិ ............ ៥៥
៣.២.២.២. ការបង្កើតគម្រោង និងកម្មវិធីលើកស្ទួយស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច ............ ៥៦
៣.២.២.៣. ការសិក្សាស្រាវជ្រាវពីបញ្ហាប្រឈមរបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច ............ ៥៨
៣.២.២.៤. ការចូលរួមបង្កើតច្បាប់ និងគោលនយោបាយ និងតាមដានការអនុវត្ត ............ ៥៩
**សេចក្តីសន្និដ្ឋាន** ............ ៦១
**អនុសាសន៍** ............ ៦៣
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | |
|---|---|
| **ក.ជ.ក.ស** | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |
| **គ.ក.ន.ក** | គណៈកម្មាធិការទទួលបន្ទុកកិច្ចការងារនារី និងកុមារ ឃុំ សង្កាត់ |
| **គ.ក.ស.ក** | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| **ផអ៣** | ផែនការអនុវត្តបីឆ្នាំដំបូង |
| **ADB** | Asian Development Bank ធនាគារអភិវឌ្ឍន៍អាស៊ី |
| **CEDAW** | Convention on the Elimination of all forms of Descriminiation against Women អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ |
| **ILO** | International Labour Organization អង្គការពលកម្មអន្តរជាតិ |
| **JICA** | Japan Internetional Cooperation Agency ភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| **UNDP** | United Nation Development Programme កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| **UN Women** | United Nation Entity for Gender Equality and the Powerment of Women អង្គការសហប្រជាជាតិគាំទ្រសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី |

# បញ្ជីតារាង


តារាងទី១៖ កម្លាំងពលកម្មជាភាគរយចន្លោះអាយុ(១៥-៦៤ឆ្នាំ) បែងចែកទៅតាមវិស័យ និងភេទ ឆ្នាំ២០០៩ និង២០១៤ **ទំព័រ៣០**

តារាងទី២៖ ភាគរយនៃការគ្រប់គ្រងអាជីវកម្ម បែងចែកទៅតាមប្រភេទនិងភេទ,ឆ្នាំ២០១១ **ទំព័រ៣២**

តារាងទី៣៖ តំណាងមន្ត្រីរាជការស៊ីវិលនៅកម្ពុជាឆ្នាំ២០០៧, ២០១៣ និង២០១៥(ជាភាគរយ) **ទំព័រ៣៧**

តារាង៤៖ តំណាងមន្ត្រីរាជការស៊ីវិលជាស្ត្រី និងបុរស ក្នុងតួនាទីដឹកនាំវិស័យសាធារណៈថ្នាក់ជាតិនិងថ្នាក់ស្មើ ឆ្នាំ២០១៣ និង២០១៥(ជាភាគរយ) **ទំព័រ៣៨**

តារាង៥៖ តំណាងមន្ត្រីរាជការជាស្ត្រី និងបុរសក្នុងតួនាទីដឹកនាំវិស័យសាធារណៈថ្នាក់ក្រោមជាតិឆ្នាំ២០១៣ និង២០១៥(ជាភាគរយ) **ទំព័រ៣៨**

តារាងទី៦៖ អាត្រាអក្ខរកម្មរបស់បុរស និងស្ត្រីក្នុងឆ្នាំ២០១៣ និង២០១៤(គិតជា%) **ទំព័រ៤០**

តារាងទី៧៖ ចំនួនអាជីវកម្មសរុប និងចំនួនអាជីវកម្មដែលបានចុះបញ្ជីរបស់ស្ត្រី និងបុរសឆ្នាំ២០១១(គិតជាភាគរយ) **ទំព័រ៤១**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ការលូតលាស់នៃសេដ្ឋកិច្ច គឺជាកត្តាស្នូលក្នុងការអភិវឌ្ឍប្រទេសជាតិ ហើយការអភិវឌ្ឍន៍នៃសេដ្ឋកិច្ចនេះទាមទារឲ្យមានការចូលរួមពីសំណាក់បុរស និងស្ត្រីដោយខានពុំបាន ទោះបីជានៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងអភិវឌ្ឍន៍។ ស្ត្រី និងបុរសគឺមានសិទ្ធិស្មើគ្នាក្នុងការចូលរួម និងទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ច។ ការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច គឺជាកំលាំងចលករជំរុញឲ្យសេដ្ឋកិច្ចឆាប់រីកចម្រើន។ហើយវាត្រូវគេទទួលស្គាល់យ៉ាងទូលំទូលាយថា ជាមូលដ្ឋានគ្រឹះយ៉ាងសំខាន់ ក្នុងការចូលរួមអភិវឌ្ឍជាតិ ការលើកកម្ពស់សមភាពយេនឌ័រ និងការកាត់បន្ថយភាពក្រីក្រ។

ប្រទេសកម្ពុជា ដែលមានស្ត្រីប្រហែលជា៥១%នៃប្រជាជនសរុបចាត់ទុកស្ត្រីគឺជាឆ្អឹងខ្នងនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ តាមសាវតាកម្ពុជា បានបង្ហាញថាស្ត្រីដើរតួយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ដូច្នេះការលើកកម្ពស់ស្ត្រីកម្ពុជានៅក្នុងវិស័យនេះមានសារៈសំខាន់ ហើយត្រូវបានយកចិត្តទុកដាក់ដោយរាជរដ្ឋាភិបាល និងមានកិច្ចសហប្រតិបត្តិការពីអង្គការសង្គមស៊ីវិល។

ការលើកកម្ពស់ស្ថានភាពស្ត្រីកម្ពុជានៅក្នុងវិស័យសេដ្ឋកិច្ច គឺសំដៅទៅលើ ការជំរុញ និងការផ្តល់កាលានុវត្តភាពពេញលេញឲ្យស្ត្រីចូលរួមនៅក្នុងសកម្មភាពអភិវឌ្ឍន៍អាជីវកម្ម កសិកម្ម និងការងារមានប្រាក់កម្រៃ។ ស្ត្រីទទួលបានអត្ថប្រយោជន៍ពីឱកាសទាំងនេះតាមរយៈ ការផលិត ប្រាក់ចំណូល ប្រៀវត្សន៍ពលកម្ម និងជាពិសេសតាមរយៈការបង្កើននូវចំណេះដឹង និងជំនាញ ការលុបបាត់រាល់ទម្រង់នៃការរើសអើង និងការរំលោភបំពានសិទ្ធិរបស់ស្ត្រី រួមទាំងអំពើហិង្សាប្រឆាំងស្ត្រីភេទ។ ជាពិសេស គឺការផ្តល់ឱកាសឲ្យស្ត្រីមានតួនាទីក្នុងការធ្វើសេចក្តីសម្រេច។

ដើម្បីសម្រេចឲ្យបានការលើកកម្ពស់នេះ កម្ពុជាបានផ្តល់សច្ចាប័នលើកតិការសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ នៅក្នុងឆ្នាំ១៩៩២។ រាជរដ្ឋាភិបាលក៏បានបង្កើតក្រសួងកិច្ចការនារី និងក្រុមប្រឹក្សាជាតិដើម្បីស្ត្រី ដែលជាយន្តការជាតិសម្រាប់ការលើកកម្ពស់សមភាពយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រី។ ចាប់តាំងពីឆ្នាំ១៩៩៩មកក្រសួងកិច្ចការនារីបានរៀបចំនូវផែនការយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំ ហៅថា នារីរតនៈ។ នៅក្នុងឆ្នាំ២០១៤ ក្រសួងកិច្ចការនារីបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ (២០១៤ ដល់២០១៨) ដែលជាផ្នែកមួយដ៏សំខាន់នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធិភាព នៅកម្ពុជាដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា និងផែនការយុទ្ធសាស្ត្រ

អភិវឌ្ឍន៍ជាតិឆ្នាំ២០១៤ ដល់២០១៨។ ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ ផ្តល់អាទិភាពជាចម្បងទៅលើការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ដោយរៀបចំអភិក្រមទូទាំងកម្មវិធី ដែលដឹកនាំដោយក្រសួងកិច្ចការនារី ជាមួយដៃគូអភិវឌ្ឍន៍ និងក្រសួងពាក់ពន្ធ័ ដើម្បីលើកម្ពស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច តាមរយៈក្រុមការងារបច្ចេសទេសយេនឌ័រ។

អង្គការសង្គមស៊ីវិល និងអង្គការអន្តរជាតិ ដែលមាន អង្គការសហប្រជាតិគាំទ្រសមភាពយេនឌ័រនិងផ្តល់ភាពអង់អាចដល់ស្ត្រីប្រចាំកម្ពុជា ឬហៅកាត់ថា UN Women ធនាគារអភិវឌ្ឍន៍អាស៊ី និងមួយចំនួនទៀត ក៏បានចូលរួមយ៉ាងសំខាន់ក្នុងការជួយលើកកម្ពស់ស្ត្រីកម្ពុជានៅក្នុងវិស័យសេដ្ឋកិច្ច។ ការលើកកម្ពស់នេះធ្វើឡើងតាមរយៈ ការគាំទ្រមតិ ការផ្តល់នូវមូលិធិ ការបង្កើតគម្រោង និងកម្មវិធីផ្សេងៗដើម្បីគាំទ្រជីវភាពស្ត្រី ការសិក្សាស្រាវជ្រាវពីបញ្ហាប្រឈម ការចូលរួមបង្កើតគោលនយោបាយលើកម្ពស់ស្ត្រី និងការតាមដានវាយតម្លៃការអនុវត្តក្របខណ្ឌកតិការសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ និងផែនការយុទ្ធសាស្ត្ររបស់ក្រសួងកិច្ចការនារី។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

រាជរដ្ឋាភិបាលមានក្រសួងកិច្ចការនារី សហការជាមួយស្ថាប័នពាក់ពន្ធ័ បានខិតខំប្រឹងប្រែងចូលរួមលើកកម្ពស់ស្ត្រីកម្ពុជានៅក្នុងវិស័យសេដ្ឋកិច្ច។ ការខិតខំប្រឹងប្រែងនេះពិតជាបានទទួលលទ្ធផលគួរឲ្យកត់សម្គាល់។ តែទោះបីជាយ៉ាងណាក៏ដោយ ស្ត្រីកម្ពុជានៅតែជួបប្រទះនូវបញ្ហាប្រឈមមួយចំនួននៅក្នុងវិស័យសេដ្ឋកិច្ច ដែលជាហេតុនាំឲ្យស្ត្រីពុំទាន់ទទួលបានកាលានុវត្តភាព និងផលប្រយោជន៍ពេញលេញពីការអភិវឌ្ឍន៍សេដ្ឋកិច្ច។ ជាពិសេស ពាក់ពន្ធ័នឹងលទ្ធភាព ទទួលបាននិងការគ្រប់គ្រងធនធានសេដ្ឋកិច្ច កាលនុវត្តភាពសម្រាប់បង្កើតជំនាញ ការងារកម្រិតខ្ពស់ និងមុខងារក្នុងការធ្វើសេចក្តីសម្រេច។

បញ្ហាប្រឈមទាំងនោះនាំឲ្យស្ត្រីកម្ពុជា បាត់បង់នូវសមត្ថភាពក្នុងការបញ្ចេញនូវសក្តានុភាពរបស់ខ្លួន ដែលនាំឲ្យមានវិសមភាពរវាងបុរស និងស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច។ ដើម្បីជាមគ្គុទេសក៍ឈានទៅរកការបកស្រាយប្រធានបទខាងលើនេះ មានសំនួរមួយចំនួនត្រូវបានចោទសួរឡើងដូចខាងក្រោមៈ

តើការចូលរួមរបស់ស្ត្រីកម្ពុជាបច្ចុប្បន្ននៅវិស័យសេដ្ឋកិច្ចមានលក្ខណៈដូចម្តេច?

តើអ្វីទៅជាបញ្ហាប្រឈម ដែលស្ត្រីកម្ពុជាកំពុងជួបប្រទះនៅក្នុងវិស័យសេដ្ឋកិច្ច?

តើរាជរដ្ឋាភិបាល និងស្ថាប័នពាក់ពន្ធ័ មានដំណោះស្រាយអ្វីខ្លះ ដើម្បីចូលរួមកាត់បន្ថយបញ្ហាប្រឈមទាំងនោះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះមានគោលបំណងសំខាន់គឺ ស្វែងយល់នូវស្ថានភាពបច្ចុប្បន្នរបស់ស្ត្រីកម្ពុជានៅក្នុងវិស័យសេដ្ឋកិច្ច និងបញ្ហាប្រឈមដែលស្ត្រីកំពុងតែជួបប្រទះនៅក្នុងសកម្មភាពសេដ្ឋកិច្ច។ បន្ថែមពីលើនេះផងដែរ ក៏សិក្សាស្រាវជ្រាវទៅលើ កិច្ចចូលរួមលើកកម្ពស់ស្ត្រីនៅក្នុងវិស័យនេះ ដែលក្នុងនោះមាន ច្បាប់ជាតិ ច្បាប់អន្តរជាតិ គោលនយោបាយ ក៏ដូចជាស្ថាប័នដែលពាក់ពន្ធ័ ចូលរួមដោះស្រាយបញ្ហា របស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច។ ជាចុងក្រោយគឺការត្រួតពិនិត្យទៅលទ្ធផលដែលទទួលបាន ពីការខិតខំប្រឹងប្រែងរបស់ស្ថាប័នពាក់ពន្ធ័ដែលព្យាយាមលើកកម្ពស់ស្ត្រីកម្ពុជានៅក្នុងវិស័យសេដ្ឋកិច្ច។

ការយល់ដឹងអំពីស្ថានភាព និងបញ្ហាប្រឈមរបស់ស្ត្រីនៅក្នុងវិស័យនេះគឺមានសារៈសំខាន់ ដោយសារតែ បញ្ហាប្រឈមទាំងនេះហើយ ដែលនាំឲ្យមានភាពយឺតយ៉ាវនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច។ ការសិក្សាស្វែងយល់ច្បាស់ពីបញ្ហានេះ គឺនាំឲ្យមានការផ្តល់អនុសាសន៍ និងដំណោះស្រាយដែលមានប្រសិទ្ធិភាព ដើម្បីកាត់បន្ថយបញ្ហាប្រឈម។ ក្នុងគោលបំណងជំរុញការលូតលាស់សេដ្ឋកិច្ចកម្ពុជា ការកាត់បន្ថយវិមភាព និងការលើកកម្ពស់យេនឌ័រ និងការកាត់បន្ថយភាពក្រីក្រ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការលើកកម្ពស់យេនឌ័រនៅក្នុងវិស័យសេដ្ឋកិច្ច ត្រូវបានទទួលបានទទួលស្គាល់យ៉ាងទូលំទូលាយថា ជាមូលដ្ឋានគ្រឹះក្នុងការចូលរួមអភិវឌ្ឍន៍ជាតិ។ ដោយសារការលើកកម្ពស់ស្ត្រីនៅក្នុងវិស័យនេះ មានសារៈសំខាន់ ហើយត្រូវបានយកចិត្តទុកខ្លាំងដោយរាជរដ្ឋាភិបាល ជាពិសេសគឺបានចាត់វិស័យនេះជាវិស័យអាទិភាព នៅក្នុងផែនការយុទ្ធសាស្ត្រនារីរតនៈទី៥។ ដូច្នេះការសិក្សាស្រាវជ្រាវនេះ គឺផ្តោតសំខាន់តែទៅលើការលើកកម្ពស់ស្ត្រីកម្ពុជានៅវិស័យសេដ្ឋកិច្ចតែប៉ុណ្ណោះ។ នៅក្នុងបរិបទនេះ វិស័យសេដ្ឋកិច្ច គឺផ្តោតសំខាន់ទៅលើវិស័យបីសំខាន់ៗគឺ វិស័យកសិកម្ម អាជីវកម្ម និងការងារដែលមានប្រាក់កម្រៃ។

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ គឺប្រើប្រាស់ ទិន្នន័យ របាយការណ៍ និងការស្រាវជ្រាវ របស់រាជរដ្ឋាភិបាលកម្ពុជា និងសង្គមស៊ីវិល នៅក្នុងចន្លោះឆ្នាំ២០១១ ដល់ ២០១៥ ដើម្បីធានាឲ្យការស្រាវជ្រាវឆ្លើយតបទៅនឹងបញ្ហា និងស្ថានភាពជាក់ស្តែងនៅក្នុងសង្គម។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការលើកកម្ពស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច គឺជាគោលនយោបាយមួយដែលប្រទេសនានាជុំវិញពិភពលោកកំពុងយកចិត្តទុក ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ ដែលភាគច្រើនធ្លាប់ជាប្រទេសមានប្រពៃណីទំនៀមទម្លាប់មិនសូវឲ្យតម្លៃទៅលើស្ត្រី ដូចជាប្រទេសកម្ពុជាជាដើម។ ដោយឃើញថាបញ្ហានេះមានសារៈសំខាន់ក្នុងការចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ច ដូច្នេះការសិក្សាស្រាវជ្រាវពីប្រធានបទនេះ នឹងផ្តល់ជាប្រភពចំណេះដឹងមួយដ៏សំខាន់ ក្នុងការស្វែងយល់កាន់តែច្បាស់ពីស្ថានភាពរបស់ស្ត្រីកម្ពុជាបច្ចុប្បន្ននៅក្នុងវិស័យនេះ។ លើសពីនេះផងការស្រាវជ្រាវនេះ នឹងជាប្រភពឯកសារសំខាន់សម្រាប់អ្នកស្រាវជ្រាវក្រោយៗ ធ្វើជាឯកសារជំនួយស្មារតី និងសិក្សាស្រាវជ្រាវបន្ត ដោយហេតុថា បញ្ហានេះគឺជាបញ្ហាថ្មី និងសំខាន់នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន។ ចំនុចដែលសំខាន់ជាងនេះគឺ ដើម្បីឲ្យសង្គមកម្ពុជា ជាពិសេសស្ត្រីកម្ពុជាខ្លួនឯង យល់ដឹងពីសារៈសំខាន់របស់ខ្លួនក្នុងការចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច។ ជាពិសេសគឺចេះប្រើប្រាស់សិទ្ធិ និងឱកាសរបស់ខ្លួនពេញលេញដើម្បីកាត់បន្ថយនូវការរើសអើង បញ្ហាប្រឈម និងអភិវឌ្ឍន៍ខ្លួនឲ្យក្លាយជាស្ត្រីអង់អាច ដូចដែលគេនិយាយថាស្ត្រីកម្ពុជាគឺជាឆ្អឹងខ្នងនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ គឺត្រូវបានប្រើប្រាស់វិធីសាស្ត្រវិភាគបែបពណ៌នាទៅលើទិន្នន័យដែលពាក់ពន្ធ័។ ចំណែកឯតម្រូវការពត៌មាន មានប្រភពចំនួនពីរ គឺប្រភពចម្បង និងប្រភពបន្ទាប់បន្សំ។

ប្រភពត៌មានចម្បងមានៈ

- ❖ កិច្ចសម្ភាស ជាមួយនឹងអ្នកតំណាងរដ្ឋាភិបាល និងសង្គមស៊ីវិល ដែលទាក់ទងនឹងការចូលរួមលើកម្ពស់ស្ត្រីកម្ពុជានៅក្នុងវិស័យសេដ្ឋកិច្ច។

ប្រភពពត៌មានបន្ទាប់បន្សំមានៈ

- ❖ ច្បាប់ជាតិ ច្បាប់អន្តរជាតិ និងគោលនយោបាយសាធារណៈដែលចូលរួមលើកកម្ពស់សិទ្ធិ និងស្ថានភាពស្ត្រី។
- ❖ របាយកាណ៍ និងការសិក្សាស្រាវជ្រាវ របស់រដ្ឋាភិបាល និងសង្គមស៊ីវិល ទាក់ទងនឹងនឹងការលើកកម្ពស់ស្ត្រីកម្ពុជានៅក្នុងវិស័យសេដ្ឋកិច្ច។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងសារណានេះត្រូវបានបែងចែកជាបីជំពូក។ ជំពូកទី១ និយាយអំពី កិច្ចចូលរួមលើកម្ពស់សិទ្ធិ និងស្ថានភាពស្ត្រីកម្ពុជា។ ដែលក្នុងនេះរៀបរាប់អំពី ច្បាប់ជាតិ ច្បាប់អន្តរជាតិ និងគោលនយោបាយដែលតាក់តែងឡើងចូលរួមលើកកម្ពស់ស្ត្រី។ បន្ថែមពីលើនេះផងដែរ ក៏សិក្សាទៅលើស្ថានប័ន ដែលចូលរួមលើកកម្ពស់ស្ត្រីក្នុងនោះមាន ស្ថានប័នរាជរដ្ឋាភិបាល សង្គមស៊ីវិល និងអង្គការអន្តរជាតិ។

ចំណែកឯជំពូកទី២ គឺបង្ហាញពី ស្ថានភាពស្ត្រីកម្ពុជាបច្ចុប្បន្ននៅក្នុងវិស័យសេដ្ឋកិច្ច។ នៅក្នុងជំពូកនេះផ្តោតសំខាន់ទៅលើបីចំនុចគឺ ការចូលរួមរបស់ស្ត្រីនៅក្នុងសកម្មភាពសេដ្ឋកិច្ច អត្ថប្រយោជន៍ដែលស្ត្រីទទួលបានពីការអភិវឌ្ឍន៍សេដ្ឋកិច្ច ចុងក្រោយគឺសម្លេង និងតួនាទីរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេច។

ជំពូកទី៣ គឺនិយាយអំពី បញ្ហាប្រឈមរបស់ស្ត្រីកម្ពុជាក្នុងវិស័យសេដ្ឋកិច្ច និងដំណោះស្រាយ។នៅក្នុងជំពូកនេះ នឹងធ្វើការបង្ហាញនូវបញ្ហាប្រឈមរបស់ស្ត្រី និងដំណោះរបស់រដ្ឋាភិបាល និងសង្គមស៊ីវិលចូលរួមខិតខំប្រឹងប្រែងក្នុងការលុបបំបាត់នូវបញ្ហា និងជំរុញការលើកស្ទួយស្ត្រីនៅក្នុងវិស័យនេះ។

ចំនុចចុងក្រោយនៃសារណាគឺ សេចក្តីសន្និដ្ឋាន អនុសាសន៍ គន្ថនិទ្ទេស និងឧបសម្ពន្ធ័។

# ជំពូកទី១
# កិច្ចចូលរួមលើកកម្ពស់សិទ្ធិ និងស្ថានភាពស្ត្រីកម្ពុជា

កិច្ចចូលរួមលើកកម្ពស់សិទ្ធិ និងស្ថានភាពស្ត្រីកម្ពុជា មានភាពទូលំទូលាយដែលសំដៅទៅលើទាំងលិខិតបទដ្ឋានគតិយុត្ត និងស្ថាប័នដែលចូលរួមជំរុញ លើកកម្ពស់ស្ត្រី។ នៅក្នុងនេះត្រូវបានបែងចែកជាចំនុចសំខាន់ៗដូចជា៖ (១.១) មូលដ្ឋានគតិយុត្តទាក់ទងនឹងការកម្ពស់សិទ្ធិ និងស្ថានភាពស្ត្រី (១.២) បរិបទគោលនយោបាយ និង(១.៣) ស្ថាប័នចូលរួមលើកកម្ពស់សិទ្ធិ និងស្ថានភាពស្ត្រីកម្ពុជា។

## ១.១. មូលដ្ឋានគតិយុត្តទាក់ទងនឹងការលើកកម្ពស់សិទ្ធិ និងស្ថានភាពស្ត្រី

ជាទូទៅ មានច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ជាច្រើនដែលចូលរួមលើកកម្ពស់ក៏ ដូចជាការពារសិទ្ធិ និងស្ថានភាពស្ត្រីកម្ពុជា ប៉ុន្តែនៅក្នុងចំនុចនេះនឹងយកតែច្បាប់សំខាន់ៗ ដែលចូលរួមការពារសិទ្ធិ និងលើកកម្ពស់ស្ត្រី។ មូលដ្ឋានគតិយុត្តនេះគឺរួមបញ្ចូលទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

### ១.១.១. ច្បាប់ជាតិ

#### ១.១.១.១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានបញ្ជាក់ថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្ម នៅក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រទេស។[1]បន្ថែមពីលើនេះទៅទៀត ក៏មានសិទ្ធិជ្រើសរើស មុខរបរសមស្រប តាមសមត្ថភាព និងតាមសេចក្តីត្រូវការរបស់ខ្លួន ហើយទទួលបានប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។ [2] រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ត្រូវលុបបំបាត់ចោល រួមទាំង ការហាមឃាត់ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រី ដែលអាចជាការជួញដូរស្ត្រី និងការកេងប្រវ័ញ្ចលើកំលាំងពលកម្មជាដើម។[3] ចំពោះអំពើការជួញដូរមនុស្ស អំពើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ស្ត្រីក៏ត្រូវបានហាមឃាត់។[4] ហេតុនេះហើយ ច្បាប់ និងលិខិត

---

[1]រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣, មាត្រា៣៥ (ពីពេលនេះទៅហៅថា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រឆ្នាំ១៩៩៣)។

[2] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា១៩៩៣, មាត្រា៣៦។

[3] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា១៩៩៣, មាត្រា៤៥។

បទដ្ឋានគតិយុត្ត ទាំងអស់ត្រូវស្របជាមួយនឹងស្មារតីរបស់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលធានានូវសិទ្ធិស្មើគ្នារវាងស្ត្រី និងបុរសនៅក្នុងសង្គម។

### ១.១.១.២. ច្បាប់ស្តីពីការងារ

ច្បាប់ការងារធានានូវសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រីក្នុងការធ្វើការងារនៅក្នុងវិស័យឯកជន។ ក្រុមហ៊ុន ឬអង្គភាពមួយមិនអាចប្រើប្រាស់បញ្ហាភេទ មកធ្វើជាលេសដើម្បីធ្វើសេចក្តីសម្រេចអំពីការជួល ការកំណត់ និងការបែងចែកការងារការបណ្តុះបណ្តាល ការតម្លើងថ្នាក់ និងឋានន្តរសក្តិ ការផ្តល់ប្រាក់កម្រៃ ការផ្តល់អត្ថប្រយោជន៍សង្គម និងវិន័យ ឬការផ្តាច់កិច្ចសន្យារើសអើងស្ត្រីបានទេ។[5] ប៉ុន្តែករណីការបែងចែក ការបដិសេធ ឬការព្រមទទួលដែលផ្អែកលើលក្ខណៈសម្បត្តិជាកំណត់សម្រាប់មុខងារណាមួយមិនត្រូវបានចាត់ទុកជាការរើសអើងឡើយ។

ច្បាប់ស្តីពីការងារក៏ធានា សុខមាលភាពរបស់ស្ត្រីនៅពេលសម្រាលកូន។ ស្ត្រីទាំងឡាយត្រូវមានសិទ្ធិឈប់សម្រាក ៩០ថ្ងៃ ឬច្រើនជាងនេះតាមការព្រមព្រៀងរបស់អង្គភាព ដើម្បីសម្រាកកូន។[6] និយោជកមិនអាចបញ្ឈប់ស្ត្រីសម្រាលកូន នៅពេលឈប់ឆ្លងទន្លេ ឬនៅក្នុងថ្ងៃណាមួយនៅពេលឈប់សម្រាក ទោះដោយវិធីឲ្យដំណឹងមុនក៏ដោយ។[7] ក្នុងកំឡុងពេលឈប់សម្រាលកូន ស្ត្រីមានសិទ្ធិទទួលបានប្រាក់ឈ្នួលពាក់កណ្តាល គិតទាំងប្រាក់បន្ទាប់បន្សំ និងវត្ថុអំណោយផ្សេងៗប្រសិនបើមាន។[8] ដូច្នេះ ដោយយោងទៅតាមច្បាប់ការងារ ក្រុមហ៊ុន ឬអង្គភាពមួយត្រូវឲ្យតម្លៃស្ត្រី ស្មើគ្នាទៅនឹងបុរស ក្នុងការធ្វើការ និងមិនអាចប្រើប្រាស់បញ្ហាភេទមកធ្វើជាលេស ដើម្បីធ្វើការសម្រេចចិត្តអ្វីមួយ និងជាពិសេសធ្វើការបញ្ឈប់ស្ត្រីនៅពេលសម្រាកសម្រាលកូន។

### ១.១.១.៣. ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

ស្ត្រី និងក្មេងស្រី ត្រូវបានគេទទួលស្គាល់ថាជាជន ដែលងាយគ្រោះបំផុតដោយសារអំពើហិង្សា ជាពិសេសអំពើហិង្សានៅក្នុងគ្រួសារ។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ មានគោលបំណងទប់ស្កាត់អំពើហិង្សានៅក្នុងគ្រួសារ ការពារជនរងគ្រោះនិង

[4] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា១៩៩៣, មាត្រា៤៦។

[5] ច្បាប់ស្តីពីការងារ, លេខជស/រកម/០៣៩៧/០១,១៣ មិនា ១៩៩៣,មាត្រា១២(ពីពេលនេះទៅហៅថាច្បាប់ស្តីពីការងារ)។

[6] ច្បាប់ស្តីពីកាងារ, មាត្រា១៨២ វាក្យខណ្ឌ១។

[7] ច្បាប់ស្តីពីការងារ, មាត្រា១៨២ វាក្យខណ្ឌ២។

[8] ច្បាប់ស្តីពីការងារ, មាត្រា១៨៣។

ពង្រឹងវប្បធម៌អហិង្សា រួមទាំងសុខុដុមរមនាក្នុងគ្រួសារនៅព្រះរាជាណាចក្រកម្ពុជា។[9] ច្បាប់នេះផ្តល់ឱកាសដល់ស្រ្តី ក្នុងការស្វែងរកនូវយុត្តិធម៌ និងដាក់ទោសដល់អ្នកប្រព្រឹត្តិបទល្មើស ក៏ដូចជាការកាត់បន្ថយអំពើហិង្សា ដែលក្នុងនោះរួមមានអំពើហិង្សាដែលប៉ះពាល់ដល់ជីវិត បូរណភាពរូបកាយ ការធ្វើទារុណកម្ម ឬការធ្វើអំពើឃោឃៅ និងការឃ្លានពានខាងផ្លូវភេទ។ ទិសដៅនៃច្បាប់នេះគឺបង្កើតយន្តការនីត្យានុកូលភាព ដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងថែរក្សាសុខដុមរមនា ក្នុងគ្រួសារតាមទំនៀមទម្លាប់ច្បាប់ និងប្រពៃណីល្អរបស់ជាតិ។[10]

### ១.១.១.៤. ច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើផ្លូវភេទ គឺជាអំពើខុសច្បាប់ និងខុសក្រមសីលធម៌របស់សង្គម។ អំពើនេះភាគច្រើនកើតទៅលើស្រ្តី និងក្មេងស្រី ដែលជាភេទទន់ខ្សោយ និងងាយរងគ្រោះ។ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានគោលបំណងបង្ក្រាបរាល់អំពើទាំងឡាយដែលពាក់ពន្ធ័នឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើផ្លូវភេទ ដើម្បីរក្សាការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងបង្កើននូវសុខភាព និងសុខមាលភាពរបស់ប្រជាពលរដ្ឋ និងរក្សាការពារ លើកកម្ពស់នូវទំនៀមទម្លាប់ប្រពៃណីដ៏ល្អរបស់ជាតិ។ បន្ថែមពីលើនេះក៏មានគោលបំណង អនុម័តឲ្យសមស្របផងដែរតាមពិធីសារអង្គការសហប្រជាជាតិ ស្តីពីការទប់ស្កាត់ ការបង្ក្រាប និងផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្រ្តី និងក្មេងស្រី បន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ឬឧបករណ៍ ឬកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗទៀត ដែលទាក់ទងនឹងការជួញដូរមនុស្ស ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន និងចុះហត្ថលេខា។[11]

### ១.១.១.៥. ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ

ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ត្រូវអនុវត្តតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ បេក្ខជនទាំងពីរភេទ តំណាងឲ្យគណៈបក្សនយោបាយមានសិទ្ធិឈរឈ្មោះជាតំណាងរាស្ត្រ ឲ្យគេបោះឆ្នោតឲ្យ ប្រសិនបើបំពេញទៅតាមលក្ខខណ្ឌ ដែលមានចែងនៅក្នុងច្បាប់

---

[9] ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, លេខនស/រកម/១០០៥/០៣១, ២១ តុលា ២០០៥, មាត្រា១ វាក្យខណ្ឌ១ (ពីពេលនេះហៅថា ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ)។

[10] ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ, មាត្រា១ វាក្យខណ្ឌ២។

[11] ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ,លេខនស/រកត/០២០៨/០០៥, ១៥ កុម្ភៈ ២០០៨, មាត្រា១។

ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ។ គណៈបក្សនយោបាយណាមួយ មិនអាចប្រើប្រាស់បញ្ហាភេទ មកធ្វើជាលេសដើម្បីហាមឃាត់មិនឲ្យ សមាជិកគណៈបក្សដែលជាស្ត្រីឈរឈ្មោះឡើយ។ ប៉ុន្តែប្រសិនបើការជ្រើសរើសបេក្ខជនឈរឈ្មោះជាតំណាងរាស្ត្រ ដោយផ្អែកទៅលើគុណសម្បត្តិ សមត្ថភាព និងចំណេះដឹង មិនត្រូវបានចាត់ទុកជាការរើសអើងឡើយ។ ជារួមមកបេក្ខជនទាំងពីររបស់គណៈបក្សនយោបាយ មានសិទ្ធិស្មើគ្នាក្នុងការឈរឈ្មោះជាតំណាងរាស្ត្រឲ្យគេបោះឆ្នោតឲ្យ ប្រសិនបើអាចបំពេញលក្ខខណ្ឌដែលមានចែង។[12] លើសពីនេះផងដែរ ច្បាប់នេះមានគោលបំណងលើកកម្ពស់ការចូលរួមរបស់ស្ត្រីជាតំណាងរបស់ប្រទេសផងដែរ។

## ១.១.២. ច្បាប់អន្តរជាតិ

### ១.១.២.១. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

កតិកាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ត្រូវបានអនុម័តនៅថ្ងៃទី១៦ ធ្នូ ១៩៦៦ ដោយមហាសន្និបាទអង្គការសហប្រជាជាតិនិងចូលជាធរមាននៅថ្ងៃទី០៣ មករា ១៩៧៦។ កម្ពុជាបានផ្តល់សច្ចាប័នទៅលើកតិកាសញ្ញានេះ នៅថ្ងៃទី២៦ សីហា ១៩៩២។ កតិកាសញ្ញានេះផ្តល់នូវសេចក្តីពិស្តារអំពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលបានរៀបរាប់ដំបូងនៅក្នុង សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស ដែលមានខ្លឹមសារសរុប៣១មាត្រា។

នៅក្នុងកតិកាសញ្ញាអន្តរជាតិនេះ បានបញ្ចូលនូវគោលគំនិតសំខាន់ៗមួយចំនួន។ ក្នុងនេះមានការផ្តល់នូវសិទ្ធិ និងតម្លៃស្មើគ្នារវាងបុរស និងស្ត្រីក្នុងធ្វើការងារ និងហាមនូវអំពើទាសភាព និងការបង្ខិតបង្ខំឲ្យជននរណាម្នាក់ធ្វើការ។[13] ការធានានូវសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ក្នុងប្រើប្រាស់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងការទទួលខុសត្រូវនៅចំពោះមុខច្បាប់។[14] ម្យ៉ាងទៀតក៏ផ្តល់នូវសមភាព ក្នុងចូលរួមជាសហាគមដោយសេរី ជាមួយអ្នកដទៃ រាប់បញ្ចូលទាំងសិទ្ធិបង្កើតសហជីពនិងសិទ្ធិចូលជាសមាជិកសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន។[15] លើសពីនេះផង

[12]ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ, លេខនស/រកម/០៧១១/០១៣, ០៤ កក្កដា ២០១១, មាត្រា៥។

[13] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(បកប្រែដោយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា), ០៣ មករា១៩៧៦, មាត្រា៨។

[14] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, មាត្រា២៦។

[15] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, មាត្រា២២។

ដែរក៏ផ្តល់នូវសេរីភាពដល់ប្រជាជននៅក្នុងរដ្ឋក្នុងការទទួលបានភាពស្មើគ្នាក្នុងការអប់រំ ការចូលរួមក្នុងសកម្មភាពវប្បធម៌ និងសេរីភាពខាងការគិត សតិសម្បជញ្ញៈ និងសាសនា។[16]

រដ្ឋភាគីនៃកតិកាសញ្ញា ត្រូវធានានូវថា ជនដែលត្រូវគេរំលោភសិទ្ធិ និងសេរីភាព ត្រូវបានដោះស្រាយដោយសក្តិសិទ្ធិ ដោយមិនប្រកាន់នូវ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ដើមកំណើតជាតិ និងសង្គម ទ្រព្យសម្បត្តិ ឬស្ថានភាពដទៃផ្សេងទៀត។ តាមការស្នើសុំរបស់គណៈកម្មាធិការសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ រដ្ឋភាគីត្រូវបង្ហាញរបាយការណ៍ស្តីពីវិធានការណ៍ដែលបានអនុម័តអនុវត្ត និងរបាយការណ៍ស្តីពីការរីកចម្រើនដែលសម្រេចពីអនុវត្តនូវកតិកាសញ្ញានេះ។ របាយការណ៍ទាំងនេះត្រូវដាក់ជូនទៅ អគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការនឹងបញ្ជូនរបាយការណ៍ទាំងនោះ ទៅគណៈកម្មាធិការដើម្បីត្រួតពិនិត្យ ។ គួរឲ្យកត់សម្គាល់ថា របាយការណ៍ត្រូវ មានបញ្ជាក់ប្រសិនបើមាននូវកត្តា និងឧបសគ្គ ដែលនាំឲ្យមានការប៉ះពាល់ដល់ការអនុវត្តនៃកតិកាសញ្ញានេះ។

### ១.១.២.២. អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ

អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសប្រឆាំងស្ត្រីភេទ Convention on the Elimination of all forms of Discrimination against women (CEDAW) ត្រូវបានអនុម័តនៅថ្ងៃទី ១៨ វិច្ឆិកា ឆ្នាំ១៩៧៩ដោយមហាសន្និបាទអង្គការសហប្រជាជាតិ និងចូលជាធរមាននៅថ្ងៃទី០៣ កញ្ញា ឆ្នាំ១៩៨១។ កម្ពុជាក្លាយជាសមាជិកនៃអនុសញ្ញានេះ នៅថ្ងៃទី២២តុលា ឆ្នាំ១៩៩២។ អនុសញ្ញានេះមានខ្លឹមសារសរុបចំនួន ៣០មាត្រា។

CEDAW គឺជាអនុសញ្ញាអន្តរជាតិដែល កំណត់នូវសមភាពរវាងបុរស និងស្ត្រី តាមរយៈការធានាឲ្យស្ត្រីមានសិទ្ធិ និងឱកាសស្មើគ្នាទៅនឹងបុរសចូលរួមនៅក្នុងវិស័យ នយោបាយ (សិទ្ធិបោះឆ្នោត និងឈរឈ្មោះឲ្យគេបោះឆ្នោត) ក៏ដូចជាវិស័យសេដ្ឋកិច្ច ការអប់រំ សង្គមកិច្ច និងវប្បធម៌ រួមទាំងការធ្វើច្បាប់ផងដើម្បីធានាការអភិវឌ្ឍន៍ និងការរីចម្រើនពេញលេញរបស់ស្ត្រី ដើម្បីឲ្យស្ត្រីប្រើប្រាស់ និងអាស្រ័យផល សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដោយសមភាពជាមួយបុរស។[17] រដ្ឋភាគីត្រូវប្រកាន់យកវិធានការសមស្រប កែប្រែផ្នត់គំនិត និងវប្បធម៌របស់បុរស និងស្ត្រី។ [18] ក្នុងគោលបំណងដើម្បីសម្រេចឲ្យបាននូវការលុបបំបាត់ចោលសេចក្តីលម្អៀងនិង

---

[16] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, មាត្រា១៨។

[17] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ (បកប្រែដោយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា), ០៣ កញ្ញា ១៩៨១, មាត្រា៣។

ទម្លាប់ផ្អែកលើគំនិតស្តីពីភាពទាបជាង ឬភាពខ្ពស់ជាងរបស់ភេទណាមួយ ឬលើតួនាទីលើទម្លាប់សម្រាប់បុរស និងស្ត្រី។

ការទទួលយកនូវអនុសញ្ញានេះរដ្ឋភាគី ត្រូវមានកាតព្វកិច្ចអនុវត្តទៅតាមខ្លឹមសារ នៃអនុសញ្ញានិងត្រូវប្រកាន់យកវិធានការសមស្របមួយចំនួន ដើម្បីបញ្ឈប់នូវការរើសអើងប្រឆាំងនឹងស្ត្រី តាមគ្រប់រូបភាពទាំងអស់។ ក្នុងនោះមានការបញ្ចូលគោលការណ៍សមភាពរវាងបុរស និងស្ត្រី ទៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាតិ រួមទាំងការកែប្រែ និងដាក់ឲ្យនិរាករ នូវច្បាប់ បទបញ្ជា ទម្លាប់ និងការអនុវត្តណាដែលអនុវត្តបង្កើតការរើងអើងដល់ស្ត្រី។[19] បង្កើតកិច្ចការពារស្ត្រីតាមផ្លូវច្បាប់ ផ្អែកលើមូលដ្ឋានសមភាពជាមួយបុរសនិងធានាការពារដល់ស្ត្រី ដោយប្រឆាំងនឹងអំពើរើសអើង តាមរយះតុលាការ និងស្ថាប័នរដ្ឋផ្សេងទៀត។[20] ដើម្បីបញ្ជាក់ពីប្រសិទ្ធភាពនៃការអនុវត្តអនុសញ្ញានេះរបស់អាជ្ញាធរ និងស្ថាប័នសាធារណៈ ជារៀងរាល់បួនឆ្នាំម្តង រដ្ឋភាគីត្រូវធ្វើរបាយការណ៍ជាតិស្តីពីការអនុវត្តអនុសញ្ញានេះ ទៅកាន់គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី របស់អង្គការសហប្រជាជាតិ។[21]

### ១.១.២.៣. សេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងប៉េកាំង

សេចក្តីប្រកាសផែនការសកម្មភាពទីក្រុងប៉កាំង ត្រូវបានអនុម័តនៅក្នុងសន្និសិទ្ធិពិភពលោកស្តីពីស្ត្រីលើកទី៤ ក្នុងទីក្រុងប៉កាំង នៅថ្ងៃទី០៥ កញ្ញា ១៩៩៥ ។ សេចក្តីប្រកាស និងផែនការសកម្មភាពនេះបានដាក់ចេញនូវក្តីបារម្ភសំខាន់ៗ ចំនួន១២ ពាក់ពន្ធ័នឹងការសម្រេចនូវសមភាពយេនឌ័រ និងសិទ្ធិស្ត្រី។[22] វាមានគោលបំណងលុបបំបាត់នូវ ឧបសគ្គរបស់ស្ត្រី ក្នុងការចូលរួមនៅក្នុងវិស័យសាធារណៈ និងឯកជននិងដោយពេញលេញ និងស្មើភាពគ្នា នៅក្នុងសេដ្ឋកិច្ច សង្គម វប្បធម៌ និងសេចក្តីសម្រេចផ្នែកនយោបាយ។[23] បន្ថែមពីនេះផងដែរ វាក៏មានគោលបំណងពន្លឿនវឌ្ឍនភាពនៃការអនុវត្តក្របខណ្ឌច្បាប់ដោយដាក់ចេញដោយអនុសញ្ញា ស្តីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ ដោយកំណត់នូវគោលនយោបាយជាក់លាក់ ដែលរដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិអនុវត្តដើម្បីលើកកម្ពស់សមភាពយេនឌ័រ។

[18] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ, មាត្រា៥។

[19] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ, មាត្រា២។

[20] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ, មាត្រា២។

[21] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ, មាត្រា១៨។

[22] សេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងប៉េកាំង, ១៥ កញ្ញា ១៩៩៥, ប្រការ៤៦។

[23] សេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងប៉េកាំង, ប្រការ១។

ផែនការសកម្មភាពនេះ បង្កើតនូវយន្តការអន្តរជាតិដ៏សំខាន់សម្រាប់ត្រួតពិនិត្យតាមដានស្ថានភាពរបស់ស្ត្រី ដែលជំរុញកិច្ចខំប្រឹងប្រែងរួមគ្នា ពីសំណាក់រដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីដោះស្រាយបញ្ហានៃការរើសអើងស្ត្រី។ គណៈកម្មាធិការអនុសញ្ញាសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ ធ្វើការពិនិត្យតាមដានពីរបៀបដែលរដ្ឋហត្ថលេខី ដាក់បញ្ចូលផែនការសកម្មភាពទីក្រុងប៉េកាំងទៅក្នុងគោលនយោបាយនានារបស់ពួកគេ។[24] ដំណើរការនៃការត្រួតពិនិត្យឡើងវិញមានលក្ខណៈទូលំទូលាយនៅថ្នាក់ជាតិ និងនៅថ្នាក់តំបន់ លើវឌ្ឍនការនៃការអនុវត្តសេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងប៉េកាំង ធ្វើឡើងជារៀងរាល់៥ឆ្នាំម្តង។ ឆ្នាំ២០១៥ គឺជាខួបទី២០ នៃសេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងប៉េកាំង ហើយមានការត្រួតពិនិត្យឡើងវិញជាសកលនៃវឌ្ឍនភាពនានា ដែលសម្រេចបានដោយរដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ នៅក្នុងការឆ្ពោះទៅសម្រេចនូវសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី។

## ១.២. បរិបទគោលនយោបាយ

### ១.២.១. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣

យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធិភាពនៅកម្ពុជា ដំណាក់ទី៣ នៃរបស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា បានទទួលស្គាល់ថាសមភាពយេនឌ័រ ជាគន្លឹះមួយក្នុងការអភិវឌ្ឍន៍ជាតិ និងធនធានមនុស្ស។ រដ្ឋាភិបាលបានបញ្ជាក់ពីភាពចាំបាច់ក្នុងការកែលម្អ និងលើកស្ទួយស្ថានភាពស្ត្រី ដែលជាឆ្អឹងខ្នងនៃសង្គម និងសេដ្ឋកិច្ច ដើម្បីសម្រេចឲ្យបាននូវសមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ជាពិសេសលើការអប់រំ ការអភិវឌ្ឍន៍សេដ្ឋកិច្ច សេវាសាធារណៈ និងការទប់ស្កាត់អំពើហិង្សាលើស្ត្រី។

ដើម្បីសម្រេចឲ្យបានសមិទ្ធផលនេះ រដ្ឋាភិបាលនឹងបន្ត លើកកម្ពស់តួនារីរបស់ស្ត្រីរបស់ស្ត្រី នៅក្នុងវិស័យសេដ្ឋកិច្ច តាមរយៈការពង្រឹងកម្មវិធីបណ្តុះបណ្តាល ការបំប៉នជំនាញបច្ចេកទេស និងសហគ្រិន និង លើកកម្ពស់តួនាទីរបស់ស្ត្រីនៅក្នុងវិស័យសាធារណៈ តាមរយៈការបង្កើនសមាមាត្រ និងពង្រឹងសមត្ថភាពស្ត្រី នៅក្នុងជួរដឹកនាំក្រសួងស្ថាប័នទាំងកម្រិតនយោបាយ និងជំនាញ។[25] ជំរុញការអនុវត្តផែនការជាតិទប់ស្កាត់អំពើហិង្សាលើស្ត្រី និងពង្រឹងការអនុវត្តច្បាប់ឲ្យមានប្រសិទ្ធ

[24] សេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងប៉េកាំង, ប្រការ៣២២។

[25] រាជរដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្រចតុកោណ៖ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធិភាពកម្ពុជា ដំណាក់កាលទី៣*, ២០១៣, ១១០ (ពីពេលនេះទៅហៅថាយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣)។

ភាពដើម្បីលុបបំបាត់ឥរិយាបថប្រើអំពើហិង្សាលើស្ត្រី និងដើម្បីបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទទៅលើស្ត្រី។[26] លើសពីនេះផងដែរ នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣នេះក៏បង្ហាញនូវការខិតខំប្រឹងប្រែងសម្រេចឲ្យបានគោលដៅខាងលើតាមរយៈការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយនិងផែនការអភិវឌ្ឍន៍ជាតិគ្រប់វិស័យនិងគ្រប់កម្រិត។[27]

### ១.២.២. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨ គឺជាផែនការជាក់លាក់ របស់ជាតិដែលបានបង្ហាញថា ការបញ្ជ្រាបយេនឌ័រជាបញ្ហាអន្តរវិស័យ ក្នុងគោលនយោបាយ កម្មវិធី និងវិស័យនានា។នៅក្នុងផែនការយុទ្ធសាស្ត្រនេះ ក៏បង្ហាញនូវការបន្ត កិច្ចខំប្រឹងប្រែងបង្កើនភាពអង់អាចដល់ស្ត្រីក្នុងវិស័យអប់រំ សេដ្ឋកិច្ច ការការពារតាមផ្លូវច្បាប់ សុខភាព មេរោគអេដស៍ និងអាហាររូបត្ថម្ភ។ រួមបញ្ចូលទាំងការបង្កើនសម្លេង និងការធ្វើសេចក្តីសម្រេចរបស់ស្ត្រីនៅក្នុងវិស័យសាធារណៈនិងនយោបាយ។[28] រដ្ឋាភិបាលកំពុងយកចិត្តទុកដាក់បង្កើនចំនួនស្ត្រីក្នុងជួរថ្នាក់ដឹកនាំតាមរយៈការលើកទឹកចិត្ត និងតែងតាំងស្ត្រីជាថ្នាក់ដឹកនាំនៅតាមគ្រប់ក្រសួងស្ថាប័ន។[29] លើសពីនេះផងដែលរដ្ឋាភិបាលក៏យកចិត្តទុកដាក់ទៅលើការពារស្ត្រីតាមរយៈចលនា ប្រណាំងអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ដែលចូលរួមចំណែលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី ជាពិសេសគ្មានអំពើ អនាចារ ការជួញដូរស្ត្រី និងកុមារនិងអំពើហិង្សាក្នុងគ្រួសារ។[30]

### ១.២.៣. ផែនការយុទ្ធសាស្ត្រនារីរតនៈ

ចាប់តាំងពីឆ្នាំ១៩៩៩ ក្រសួងកិច្ចការនារី បានរៀបចំ និងអនុវត្តនូវផែនការយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំ ដែលហៅថា នារីរតនៈ។[31] គិតមកដល់ពេលនេះ ផែនការយុទ្ធសាស្ត្រនារីរតនៈ បានអនុវត្តដល់ដំណាក់កាលទី៤ ដែលដំណាក់កាលនីមួយៗ ចូលរួមដល់កិច្ចខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការលើកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីកម្ពុជា។ នៅក្នុងឆ្នាំ

[26] យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣, ១១០។

[27] យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣, ១១១។

[28] រាជរដ្ឋាភិបាលកម្ពុជា, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨*, ២០១៥, ១៣១(ពីពេលនេះទៅហៅថា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ) ។

[29] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ១៣១។

[30] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ១៣០។

[31] ក្រសួងកិច្ចការនារី, *នារីរតនៈទី៤៖ ផែនការយុទ្ធសាស្ត្រដើម្បីសមភាពយេនឌ័រ និងការបង្កើតភាពអង់អាចដល់ស្ត្រី ឆ្នាំ ២០១៤-២០១៨*, ២០១៤, ១ (ពីពេលនេះហៅថានារីរតនៈទី៤)។

២០១៣ក្រសួងកិច្ចការនារី ក្នុងភាពជាដៃគូជាមួយក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានពិនិត្យទៅលើប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៣ និង បានរៀបចំផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ ដែលជាផ្នែកមួយនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភានិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឆ្នាំ ២០១៤-២០១៨។

នារីរតនៈទី៤ផ្តោតសំខាន់ទៅលើការពង្រឹង និងពង្រីកមុខងាររបស់ ក្រសួងកិច្ចការនារីពី របៀបនៃការអនុវត្តការងារ ដើម្បីឈានទៅរកការអនុវត្តការងារតាមអភិក្រមគ្រប់គ្រងទូទាំងកម្ម វិធីនិងឈានជាបណ្តើរៗ ពីភ្នាក់ងារអនុវត្តផ្ទាល់ ទៅជាអ្នកលើកកម្ពស់គណនេយ្យភាពសង្គម សម្រាប់ស្ត្រី និងអ្នកផ្តល់សេវាពិគ្រោះយោបល់ផ្នែកគោលនយោបាយ ដល់ស្ថាប័នពាក់ពន្ធ័ ក្នុង ការលើកកម្ពស់សមភាពយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រី។[32] ផែនការយុទ្ធសាស្ត្រនេះ បង្ហាញសកម្មភាពលម្អិតក្នុងការគាំទ្រនៃការឈានទៅរករបៀបធ្វើការងារលក្ខណៈជាអភិក្រមគ្រប់ ទូទាំងកម្មវិធីដែលផ្តោតសំខាន់លើការអភិវឌ្ឍន៍សមត្ថភាពក្រសួង និងស្ថាប័នពាក់ពន្ធ័ក្នុងការ លើកកម្ពស់សមភាពយេនឌ័រ។ នារីរតនៈក៏បង្ហាញអំពីចក្ខុវិស័យ បេសកកម្ម និងគោលបំណង រួមទាំងយុទ្ធសាស្ត្រដែលរៀបចំឡើងតាមវិស័យ និងកម្មវិធីអាទិភាពនិមួយៗ។

ក្នុងគោលដៅដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ក្នុងបរិបទ កំណើនសេដ្ឋកិច្ច ការអភិវឌ្ឍន៍សង្គម និងអភិបាលកិច្ចល្អ នារីរតនៈទី៤ មានគោលបំណងសំខាន់ៗ មួយចំនួន។ ជាចំបង ជំរុញឲ្យមានបរិយាកាសអំណោយផល ដើម្បីបង្កើនលទ្ធភាពដល់ស្ត្រីក្នុងការ ទទួលបាននូវជំនាញ ការងារ ធនធានផលិតកម្ម កិច្ចគាំពារសង្គម សម្លេង និងការធ្វើសេចក្តីសម្រេច នៅគ្រប់កម្រិត តាមរយៈការបង្កើនចំនួនមន្ត្រីរាជការជាស្ត្រី និងការពង្រឹងសមត្ថភាព។[33] បង្កើន លទ្ធភាពរបស់ស្ត្រីនិងកុមារក្នុង ការទទួលបាននូវការអប់រំតាមរយៈ ការលើកកម្ពស់ការចូលរួមការ លើកកម្ពស់ការយល់ដឹង និងបង្កលក្ខណៈងាយស្រួលដល់ស្ត្រី និងក្មេងស្រី ក្នុងការទទួលបាន សេវា។[34] ម្យ៉ាងទៀតគឺចូលរួមធានាសុវត្ថិភាពដល់ស្ត្រី និងក្មេងស្រីក្នុងគ្រួសារ និងសង្គម តាមរយៈ បង្កើនការយល់ដឹង និងការអនុវត្តផែនការសកម្មភាព និងច្បាប់ លិខិតបទដ្ឋានពាក់ពន្ធ័។[35]

[32] នារីរតនៈទី៤, ១។

[33] នារីរតនៈទី៤, ១៣។

[34] នារីរតនៈទី៤, ១៣។

[35] នារីរតនៈទី៤, ១៣។

### ១.២.៤. ក្របខណ្ឌពន្លឿនគោលដៅសហស្សវត្សរ៍

ក្របខណ្ឌពន្លឿនគោលដៅសហស្សវត្សរ៍ឆ្នាំ២០១២-២០១៥ មានគោលបំណងពន្លឿនសមិទ្ធផលគោលដៅទី៣ ដោយផ្តោតលើការផ្តល់ភាពអង់អាចដល់ស្ត្រីផ្នែកសេដ្ឋកិច្ច។ តាមរយៈបង្កើត ការកៀរគរស្ថាប័នរដ្ឋ វិស័យឯកជន ក៏ដូចជាដៃគូរអភិវឌ្ឍន៍ និងសង្គមស៊ីវិល។ក្របខណ្ឌនេះចូលរួមក្នុងការសម្រេចនូវគោលដៅជាក់លាក់បីគឺ៖ (១)ការពង្រឹងជំនាញវិជ្ជាជីវៈសម្រាប់ស្ត្រីដោយផ្អែកលើតម្រូវការទីផ្សារ (២)បង្កើនសហគ្រាសខ្នាតតូច និងមធ្យម និង(៣) កែលម្អជីវភាពរស់នៅតាមជនបទ។[36]

ការពង្រឹងជំនាញវិជ្ជាជីវៈសម្រាប់ស្ត្រី ក្រសួងកិច្ចការនារីមាន មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីនៅខេត្តចំនួន១៣។[37] មណ្ឌលអភិវឌ្ឍន៍ស្ត្រីជាមជ្ឈមណ្ឌលសម្របសម្រួល និងផ្តល់សេវាអភិវឌ្ឍន៍សហគ្រាសគ្រប់គ្រងកម្មវិធីអក្ខរកម្ម និងជំនាញបំនិនជីវិតដល់ស្ត្រី។ ស្ត្រីអាចចូលរួមសិក្សាវគ្គបណ្តុះបណ្តាលដើម្បីរៀនជំនាញទៅតាមតម្រូវការទីផ្សារដើម្បី យកទៅបើកអាជីវកម្មផ្ទាល់ខ្លួន ឬធ្វើការងារ។

ការបង្កើនសហគ្រាសខ្នាតតូច និងមធ្យម ជាប្រភពយ៉ាងសំខាន់ក្នុងការបង្កើននៅទីផ្សារការងារដល់ស្ត្រី។ ការលើកកម្ពស់ការអភិវឌ្ឍន៍ សហគ្រាសខ្នាតតូច និងមធ្យមគឺជាភារកិច្ចរបស់ក្រសួងពាក់ពន្ធ័។កិច្ចសន្ទនារវាងវិស័យសាធារណៈ និងវិស័យឯកជន គឺជាយុទ្ធសាស្ត្រមួយ ដើម្បីបង្កើតឲ្យមានបរិយាកាសអាជីវកម្មអំណោយផល សម្រាប់សហគ្រាសខ្នាតតូច និងមធ្យម និងការផ្តល់សេវាហិរញ្ញវត្ថុ ដល់ស្ត្រី។

ការអភិវឌ្ឍន៍ជីវភាពរស់នៅតាមទីជនបទ ពាក់ពន្ធ័ភាគច្រើនទៅលើហេដ្ឋារចនាសម្ពន្ធ័ នៅតាមមូលដ្ឋាន អាហាររូបត្ថម្ភ និងអនាម័យ។ការងារទាំងនេះភាគច្រើនជាបន្ទុករបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងអភិវឌ្ឍន៍ជនបទ។ គោលនយោបាយសម្រាប់ ការកែលម្អជីវភាពរស់នៅតាមសហគមន៍ជនបទជាពិសេសសម្រាប់ស្ត្រីក្រីក្រ ត្រូវបានបញ្ជាក់នៅក្នុងក្របខ័ណ្ឌអាទិភាពជាតិរយៈពេលមធ្យមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

[36] ក្រសួងកិច្ចការនារី, *សេចក្តីសង្ខេបគោលនយោបាយ១៖បរិបទគោលនយោបាយ ស្ថាប័ននិងភាពជាដៃគូ*, ២០១៤, ១( ពីពេលនេះទៅហៅថាសេចក្តីសង្ខេបគោលនយោបាយ១)។

[37] សេចក្តីសង្ខេបគោលនយោបាយ១, ១៥។

### ១.២.៥. គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព

ផ្អែកលើការអនុវត្តជោគជ័យរបស់ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ឆ្នាំ២០០០-២០១៥ អង្គការសហប្រជាជាតិក៏បានដាក់ចេញនូវគោលដៅថ្មីមួយទៀតដែលហៅថា គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃឆ្នាំ២០៣០( The Sustainable Development Goals of 2030)។ ក្នុងនោះមានគោលដៅសំខាន់ៗចំនួន១៧ [38] ដែលអនុម័តដោយកិច្ចប្រជុំកំពូលជាប្រវត្តិសាស្ត្ររបស់អង្គការសហប្រជាជាតិ នៅខែកញ្ញា ឆ្នាំ២០១៥ [39] ។ ក្នុងរយៈពេល១៥ឆ្នាំ ជាមួយនឹងគោលដៅថ្មីទាំង១៧នេះ ប្រទេសទាំងអស់នៅលើពិភពលោកត្រូវព្យាយាមសម្រេចឲ្យបាននូវ ការលុបបំបាត់ រាល់ទម្រង់នៃភាពក្រីក្រ វិសមភាពយេនឌ័រ និងការបម្រែបម្រួលនៃអាកាសធាតុ។[40]

គោលដៅទី៥ នៃគោលដៅអភិវឌ្ឍន៍ប្រកបនិរន្តរភាព បានផ្តោតសំខាន់ទៅលើការសម្រេចឲ្យបាននូវសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី និងក្មេងស្ត្រី។ [41] ដើម្បីសម្រេចឲ្យបានគោលដៅទី៥នេះ រាល់ទម្រង់នៃការរើសអើង និងហិង្សាប្រឆាំងស្ត្រី និងក្មេងស្រីត្រូវបានបញ្ឈប់ទាំងនូវក្នុងបរិបទសាធារណៈ និងឯកជន។ [42] លើសពីនេះផង ដោយយោងទៅតាមសេចក្តីលម្អិតនៅក្នុងគោលដៅទី៥ ក៏ផ្តល់សិទ្ធិស្មើគ្នាដល់ស្ត្រី ទៅលើធនធានសេដ្ឋកិច្ច ក៏ដូចជា ភាពជាម្ចាស់កម្មសិទ្ធិ ទៅលើដីធ្លី និងរាល់ទម្រង់ផ្សេងទៀតនៃទ្រព្យសម្បត្តិ សេវាហិរញ្ញវត្ថុ ការទទួលបានមរតក និងធនធានធម្មជាតិ ដោយយោងទៅតាមច្បាប់ជាតិ។ [43] គោលដៅនេះបានទទួលស្គាល់ និងឲ្យតម្លៃទៅលើការងារថែទាំ និងការងារផ្ទះសម្បែងរបស់ស្ត្រី និងធានាការចូលរួមពេញលេញ និងមានប្រសិទ្ធិភាព និងឱកាសស្មើគ្នា សម្រាប់ភាពជាអ្នកដឹកនាំ នៅគ្រប់កំរិតនៃការធ្វើសេចក្តីសម្រេចទាំងនៅក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងជីវិតសាធារណៈ។ ម្យ៉ាងវិញទៀត វាក៏ជំរុញឲ្យគ្រប់ប្រទេស អនុម័ត និងពង្រឹង ការអនុវត្តគោលនយោបាយ និងច្បាប់ សម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី និងក្មេងស្រី និងធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ

---

[38] អង្គសហប្រជាជាតិ, *Transforming Our World: The 2030 Agenda for Sustainable Development [ការផ្លាស់ប្តូរពិភពលោករបស់យើង៖ របៀបវារៈសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃឆ្នាំ២០៣០]*, (New York: United Nation, 2015), ៥។

[39] ដូច៣៨, ៣។

[40] ដូច៣៩។

[41] ដូច៣៨, ១២។

[42] ដូច៣៨, ១៥។

[43] ដូច៤២។

និងច្បាប់ទាំងនេះឲ្យមានភាពទូលំទូលាយ។ [44] គួរឲ្យកត់សម្គាល់ឃើញថាសេចក្តីលម្អិត នៅក្នុងគោលដៅទី៥នេះ ត្រូវបានបញ្ចូលទៅក្នុងគោលនយោបាយសាធារណៈនិងច្បាប់របស់កម្ពុជាផងដែរ។

## ១.៣. ស្ថាប័នចូលរួមលើកកម្ពស់សិទ្ធិ និងស្ថានភាពស្រ្តីកម្ពុជា

បើនិយាយពីស្ថាប័នដែលចូលរួមលើកកម្ពស់សិទ្ធិ និងស្ថាភាពស្រ្តី ត្រូវគិតទៅដល់ស្ថាប័នពីរសំខាន់ៗ គឺទីមួយ ស្ថាប័នរាជារដ្ឋាបាលភិបាល ដែលក្នុងនោះរួមបញ្ចូលទាំងស្ថាប័នថ្នាក់ជាតិ និងស្ថាប័នថ្នាក់ក្រោមជាតិ។ និងស្ថាប័នមួយទៀតគឺស្ថាប័នសង្គមស៊ីវិល។

### ១.៣.១. ស្ថាប័នថ្នាក់ជាតិ

#### ១.៣.១.១. ក្រសួងកិច្ចការនារី

ក្រសួងកិច្ចការនារី គឺជាស្ថាប័នចំរុះឲ្យរាជារដ្ឋាភិបាលកម្ពុជាដែលមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យកិច្ចការនារីនៃព្រះរាជាណាចក្រកម្ពុជា។[45] ដំបូងនៅក្នុងឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលបានបង្កើតនូវរដ្ឋលេខាធិការដ្ឋានកិច្ចការនារី និងបានតម្លើងជាក្រសួងកិច្ចការនារី និងអតីតយុទ្ធជននៅក្នុងឆ្នាំ១៩៩៩[46] និងផ្លាស់មកជាក្រសួងកិច្ចការនារីក្នុងឆ្នាំ២០០៥ [47]។

ក្រសួងកិច្ចការនារី មានតួនាទី និងភារកិច្ចជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ស្ថានភាព និងការពារសិទ្ធិស្រ្តីតាមរយៈការអនុវត្តផែនការយុទ្ធសាស្រ្តជាតិផ្សេងៗស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្រ្តី។ ក្រសួងដើរតួនាទីក្នុងការលើកកម្ពស់សមភាពយេនឌ័រ ក្នុងច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្រ្ត និងកម្មវិធីជាតិនានា។ ក្រៅពីកម្មវិធីបង្កើនភាពអង់អាចដល់ស្រ្តីផ្នែកសេដ្ឋកិច្ច អប់រំ ការលើកកម្ពស់សុខភាពស្រ្តី និងក្មេងស្រី កិច្ចការពារតាមផ្លូវច្បាប់ដល់ស្រ្តី និងក្មេងស្រ្តី រួមទាំងការលើកកម្ពស់ការចូលរួមរបស់ស្រ្តីនៅក្នុងវិស័យសាធារណៈ និងនយោបាយក្រសួងកំពុង នឹងជំរុញការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយសាធារណៈ ផែនការ និងកម្មវិធីកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល។ ដែលក្នុងនោះរួមមាន កំណែទម្រង់វិជ្ឈការ និងវិសហមជ្ឈការកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់

---

[44] ដូច៨៣។

[45] ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី, លេខនស/រកម/០១០៥/០០២, ២៤ មករា ២០០៥, មាត្រា២ (ពីពេលនេះហៅថាច្បាប់ស្តីពីបង្កើតក្រសួងកិច្ចការនារី។

[46] ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន, លេខនស/រកម/០៩៩៩/១០, ១៨ កញ្ញា ១៩៩៩, មាត្រា១។

[47] ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី, មាត្រា១។

ច្បាប់ និងប្រពន្ធ័យុត្តិធម៌ កម្មវិធី និងការបញ្ជ្រាបយេនឌ័រតាមវិស័យ រួមទាំងផែនការអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពកម្ពុជា។ តាំងពីឆ្នាំ១៩៩៣ក្រសួងកិច្ចការនារីបានបង្កើត និងអនុវត្តផែនការយុទ្ធសាស្ត្ររយៈ៥ឆ្នាំ ដែលហៅថា នារីរតនៈ។បច្ចុប្បន្ននេះក្រសួងកិច្ចនារីកំពុងអនុវត្តផែនការយុទ្ធនារីរតនៈទី៤ ដើម្បីសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី។ ក្រសួងកិច្ចការនារីដឹកនាំ និងសម្របសម្រួល ក្រុមការងារ និងគណៈកម្មាធិការមួយចំនួនដែលចូលរួមពីស្ថាប័នពាក់ពន្ធ័ដើម្បីអនុវត្តការងារលើកកម្ពស់សមភាពយេនឌ័រ និងដោះស្រាយបញ្ហាទាក់ទងនឹងស្ត្រី ដែលក្នុងនោះរួមមានដូចជា៖ (ក) ក្រុមការងារបច្ចេកទេសយេនឌ័រ (ខ) គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ (គ) គណៈកម្មាធិការដឹកនាំ និងសម្របសម្រួលអភិក្រមទូទាំងកម្មវិធី និង(ឃ) គណៈកម្មាធិការយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។

**ក. ក្រុមការងារបច្ចេកទេសយេនឌ័រ**

ក្រុមការងារបច្ចេសទេសយេនឌ័រត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៥ ដែលដឹកនាំដោយក្រសួងកិច្ចការនារី និងមានកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការជប៉ុនជាសហអ្នកសម្របសម្រួល និងមានការចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ពន្ធ័ចំនួន៣១ ដៃគូអភិវឌ្ឍន៍ចំនួន១៤ ព្រមទាំងអង្គការសង្គមស៊ីវិលចំនួន១៥ ជាសមាជិក។[48] ចាប់តាំងពីការបង្កើតមកក្រុមការងារបច្ចេកទេសយេនឌ័រ បានផ្តល់ជាវេទិការសម្រាប់ការពិភាក្សា និងធាតុចូលក្នុងការបង្កើតគោលនយោបាយយុទ្ធសាស្ត្រ និងច្បាប់ដែលទាក់ទិញនឹងបញ្ហាយេនឌ័រ។ ដើម្បីសម្រេចឲ្យបានលទ្ធផលល្អប្រសើរឡើងក្រុមការងារបច្ចេសទេសយេនឌ័រ បានបង្កើតក្រុមការងារតូច ដើម្បីសម្របសម្រួលការអនុវត្តវិស័យសំខាន់ចំនួនពីររបស់ក្រសួងកិច្ចការនារី គឺការទប់ស្កាត់អំពើហិង្សានិងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ក្នុងក្របខណ្ឌអភិក្រមទូទាំងកម្មវិធី។[49]

**ខ. គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ**

គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងមានសមាជិកមកពីក្រសួង និងស្ថាប័នពាក់ពន្ធ័របស់រាជរដ្ឋាភិបាល។[50] គណៈកម្មាធិការនេះ បានបង្កើតឡើងក្នុងគោលបំណងថែរក្សាការពារវប្បធម៌ជាតិ ធានាដល់ការគោរពសីលធម៌សង្គម និងសុភមង្គលនៅក្នុងគ្រួសារ ដោយលើកកម្ពស់ស្ថានភាព តួនាទី និងសុខ

[48] សេចក្តីសង្ខេបគោលនយោបាយ១, ១៥។

[49] សេចក្តីសង្ខេបគោលនយោបាយ១, ១៥។

[50] សេចក្តីសង្ខេបគោលនយោបាយ១, ១០។

មាលភាពស្ត្រី។ បន្ថែមពីនេះផងដែរ គណៈកម្មធិការក៏ចូលរួមក្នុងការលើកកម្ពស់តម្លៃស្ត្រីខ្មែរ តាមរយៈការឲ្យតម្លៃ និងទទួលស្គាល់ទៅលើកិច្ចការងារថែទាំ និងការងារផ្ទះសម្បែងរបស់ស្ត្រី រួមទាំងការធ្វើសេចក្តីសម្រេចក្នុងគ្រួសារ។

**គ. គណៈកម្មាធិការដឹកនាំ និងសម្របសម្រួលអភិក្រមទូទាំងកម្មវិធី**

គណៈកម្មធិការដឹកនាំ និងសម្របសម្រួលអភិក្រមទូទាំងកម្មវិធី បានបង្កើតឡើងក្នុងខែតុលា ឆ្នាំ២០១២ ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងមានសមាជិកចំនួន១២រូប ជារដ្ឋលេខាធិការ និងជាអគ្គនាយក ព្រមទាំងមានលេខាធិការដ្ឋានមួយដើម្បីគាំទ្រការងាររបស់ខ្លួន។[51] គណៈកម្មាធិការនេះបង្កើតឡើងក្នុងគោលបំណង សម្របសម្រួល និងដឹកនាំការបង្កើត និងអនុវត្តអភិក្រមទូទាំងកម្មវិធីដើម្បីឆ្ពោះទៅរកសមភាពយេនឌ័រ។ គួរឲ្យកត់សម្គាល់ឃើញថា តួនាទីចម្បង និងការទទួលខុសត្រូវរបស់គណៈកម្មាធិការនេះ គឺ រៀបចំអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីសម្របសម្រួលកិច្ចសហប្រតិបត្តិការ ការកៀរគរធនធាន និងកាអភិវឌ្ឍន៍សមត្ថភាព។[52]

**ឃ. គណៈកម្មាធិការយេនឌ័រ និងការប្រែប្រួលអាកាសធាតុ**

គណៈកម្មាធិការយេនឌ័រ និងការប្រែប្រួលអាកាសធាតុ បានបង្កើតឡើងនៅក្នុងខែកញ្ញាឆ្នាំ២០១១។[53] គណៈកម្មាធិការនេះបានបង្កើតឡើងក្នុងគោលបំណងសម្របសម្រួលចែករំលែកពត៌មានបញ្ហាបយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ជាមួយស្ថាប័នពាក់ពន្ធ័ អង្គការមិនមែនរដ្ឋាភិបាលមន្ទីរកិច្ចការនារីរាជធានី ខេត្ត និងការិយាល័យកិច្ចការនារីស្រុក ខណ្ឌ។ បន្ថែមពីនេះផងដែលក៏មានគោលបំណងសិក្សាស្រាវជ្រាវអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយផ្សេងៗចំពោះមនុស្ស ជាពិសេសផលប៉ះពាល់មកលើស្ត្រី កុមារ និងក្រុមជនងាយរងគ្រោះ។ និងចូលរួមអភិវឌ្ឍន៍សមត្ថភាពក្រុមការងារមន្ត្រីក្រសួងកិច្ចការនារី និងក្រសួងស្ថាប័នពាក់ពន្ធ័ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីយល់ដឹងពីផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុ និងការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ។

[51] សេចក្តីសង្ខេបគោលនយោបាយ១, ១០។

[52] សេចក្តីសង្ខេបគោលនយោបាយ១, ១១។

[53] សេចក្តីសង្ខេបគោលនយោបាយ១, ១១។

### ១.៣.១.២. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ត្រូវបានបង្កើតឡើងយោងតាមព្រះរាជក្រឹត្យលេខនស/រកត ០២/០១/០៣៦ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០១ ។ ព្រះរាជក្រឹត្យនេះបានកំណត់ការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បី ស្ត្រី ដោយមានអក្សរ កាត់ ក.ជ.ក.ស ជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើបញ្ហា ដែលទាក់ទងដល់ការ លើកកំពស់ស្ថានភាព តួនាទីរបស់ស្ត្រី និងសុខមាលភាពសង្គមស្ត្រីកម្ពុជាសំដៅកាត់បន្ថយឈានទៅលុបបំបាត់រាល់ ទម្រង់នៃ ការរើសអើងប្រឆាំងនឹងស្ត្រី និងអំពើហិង្សាលើស្ត្រី។[54] ក.ជ.ក.ស. ដឹកនាំដោយសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាប្រធានកិត្តិយស សម្តេចនាយករដ្ឋមន្ត្រី ជាអនុប្រធានកិត្តិយស រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ជាប្រធានប្រតិបត្តិ និងរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ជាអនុប្រធានរួមទាំងតំណាងក្រសួងស្ថាប័នពាក់ពន្ធ័ជាសមាជិក សមាជិកា។[55] ក.ជ.ក.ស. មានផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ (២០១០-២០១៤) របស់ខ្លួន និង មានអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយជាសេនាធិការ ដែលមានទីតាំងនៅក្នុងទីស្តីការក្រសួងកិច្ចការនារី។[56]

ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី មានភារកិច្ច ជួយរាជរដ្ឋាភិបាលក្នុងការសម្របសម្រួល តាមដានវាយតម្លៃកាអនុវត្ត ការផ្តល់អនុសាសន៍ និងការជំរុញការអនុវត្តគោលនយោបាយជាតិ ច្បាប់ បទបញ្ញានិងវិធានការ ដែលទាក់ទងដល់ ការលើកកម្ពស់ស្ថានភាព តួនាទី និងសុខមាលភាពសង្គមស្ត្រីកម្ពុជា។បន្ថែមពីនេះផងដែរ ក៏មានតួនាទីជួយរាជរដ្ឋាភិបាល ក្នុងការតាមដានការអនុវត្តសន្ធិសញ្ញាអន្តរជាតិនានាពាក់ពន្ធ័នឹងការលើកកម្ពស់សិទ្ធិ និងស្ថានភាពស្ត្រី និងសម្របសម្រួលការរៀបចំរបាយការណ៍ជាតិ ស្តីពីការអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ ដើម្បីដាក់ជូនឲ្យរាជរដ្ឋាភិបាលពិនិត្យមុននឹងបញ្ជូនទៅអង្គការសហប្រជាតិ។ [57]

រួមបញ្ចូលភារកិច្ច ការតាមដាន នឹងការជំរុញការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយជាតិ និងក្នុងកម្មវិធីអភិវឌ្ឍន៍ជាតិ។ ម្យ៉ាងវិញទៀត ក.ជ.ក.ស.មានភារកិច្ចរៀបចំរបាយការណ៍

[54] ព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី, លេខនស/រកត០២/០១/០៣៦, ១៤ កុម្ភៈ ២០០១, មាត្រា១ (ពីពេលនេះទៅហៅថាព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី)។

[55] ព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី, មាត្រា២។

[56] ព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី, មាត្រា៥។

[57] ព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី, មាត្រា៤។

ជារៀងរាល់ឆ្នាំ ស្តីពីសកម្មភាពរបស់ខ្លួនបានបំពេញ ដាក់ជូនរាជរដ្ឋាបាលត្រួតពិនិត្យនិងទទួលនូវភារកិច្ចផ្សេងៗតាមសំនូមពររបស់រាជរដ្ឋាភិបាល។[58]

### ១.៣.១.៣. ក្រុមការងារបញ្ជ្រាបយេនឌ័រតាមក្រសួង ស្ថាប័ន

ក្រសួងកិច្ចការនារីលើកទឹកចិត្តនិងជំរុញឲ្យមានការបញ្ជ្រាបយេនឌ័រតាមក្រសួងនិងស្ថាប័ន។ ក្រុមការងារបញ្ជ្រាបយេនឌ័រតាមក្រសួង ស្ថាប័នបានបង្កើតឡើងតាំងពីឆ្នាំ២០០៥ ដែលដឹកនាំដោយរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ អគ្គនាយក ឬអគ្គនាយករង និងមានសមាជិកមកពីនាយកដ្ឋានចំណុះឲ្យក្រសួង និងស្ថាប័ននីមួយៗ។[59]

ក្រុមការងារនេះមានតួនាទី និងការទទួលខុសត្រូវមួយចំនួនក្នុងការបញ្ជ្រាបយេនឌ័រ ទៅក្នុងក្រសួង និងស្ថាប័នរបស់ខ្លួនតាមរយៈ ការពិនិត្យ និងវិភាគ ទស្សនៈយេនឌ័រគ្រប់គោលនយោបាយផែនការ និងកម្មវិធីរបស់វិស័យនីមួយៗ។ ការស្វែងរកការគាំទ្រមតិ និងផ្តល់នូវអនុសាសន៍ដល់ថ្នាក់ដឹកនាំស្តីពីបញ្ហាយេនឌ័រនៅក្នុងគ្រប់កម្មវិធី របស់ក្រសួង ស្ថាប័ន។ ការកៀរគរធនធានសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ និងការអភិវឌ្ឍន៍សមត្ថភាពលើការបញ្ជ្រាបយេនឌ័រ។ បន្ថែមពីលើនេះគឺការចូលរួមក្នុងដំណើរការកសាងកម្មវិធី និងការធ្វើផែនការក្រសួងនិងស្ថាប័ន ដើម្បីធានាថាផែនការទាំងនោះឆ្លើយតបទៅនឹងយេនឌ័រ។ តាមរយៈការបញ្ជ្រាបយេនឌ័រតាមក្រសួង ស្ថាប័ន មានក្រសួងស្ថាប័នចំនួន២៤ បានបង្កើត និងកំពុងអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យ។[60]

## ១.៣.២. ស្ថាប័នថ្នាក់ក្រោមជាតិ

### ១.៣.២.១. មន្ទីរកិច្ចការនារីរាជធានី ខេត្ត និងការិយាល័យកិច្ចការនារីក្រុង ស្រុក ខណ្ឌ

មន្ទីរកិច្ចការនារីរាជធានី ខេត្ត និងការិយាល័យកិច្ចការនារីក្រុង ស្រុក ខណ្ឌ គឺជារចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ និងអង្គភាពចំណុះរបស់ក្រសួងកិច្ចការនារី។ នៅក្នុងការអនុវត្តការងារ មានអង្គភាពមួយចំនួនដូចជា៖ (ក) គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ថ្នាក់រាជធានី ខេត្ត ក្រុង ខណ្ឌ (ខ) គណៈកម្មធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ) អ្នកទទួលបន្ទុកកិច្ចការនារី ឃុំ សង្កាត់ និង(ឃ) មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ធ្វើការជាមួយមន្ទីរ ការិយាល័យកិច្ចការនារី

[58] ព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី, មាត្រា៥។

[59] សេចក្តីសង្ខេបគោលនយោបាយ១, ១៧។

[60] សេចក្តីសង្ខេបគោលនយោបាយ១, ១៧។

និងអង្គភាពពាក់ពន្ធ័ផ្សេងៗ ដែលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន មានតួនាទីគាំទ្រ សម្របសម្រួល និងធ្វើការស្រាវជ្រាវ ដើម្បីផ្តល់ពត៌មាន លើបញ្ហាទាក់ទងស្ត្រី និងកុមារ ក្នុងមូលដ្ឋាន។[61]

**ក. គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារថ្នាក់រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ (គ.ក.ស.ក) គឺជាយន្តការថ្នាក់ក្រោមជាតិដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងកុមារ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ គ.ក.ស.ក មានមុខងារ និងភារកិច្ចក្នុងការផ្តល់យោបល់ និងអនុសាសន៍ជូនក្រុមប្រឹក្សា គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការផ្សេងទៀតលើបញ្ហាទាក់ទងនឹងសមភាពយេនឌ័រ និងបញ្ហារបស់ស្ត្រី យុវវ័យ និងកុមារ។ គ.ក.ស.ក នីមួយៗ ដឹកនាំដោយប្រធានមួយរូបដែលជាសមាជីកាក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមានអនុប្រធានជាអភិបាលរងនៃគណៈអភិបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុប្រធានបីរូបទៀតមកពីសមាជិកក្រុមប្រឹក្សារាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ តំណាងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងតំណាងមន្ទីរកិច្ចការនារី។[62]

**ខ. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់**

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់(គ.ក.ន.ក) ជាគណៈកម្មាធិការទទួលបន្ទុកលើបញ្ហាស្ត្រី និងកុមារ ដែលទទួលខុសត្រូវលើបញ្ហាដែលទាក់ទងនឹងកិច្ចអភិវឌ្ឍន៍សង្គម។កិច្ចការទាំនោះមានដូចជា បញ្ហាសុខភាពមាតា មតេយ្យសិក្សាសហគមន៍ អនាម័យ ទឹកស្អាត សមភាពយេនឌ័រ និងកិច្ចការពារកុមារ។ សមភាពនៃគណៈកម្មាធិការនេះមាន មេឃុំឬចៅសង្កាត់ជាប្រធាន ជំទប់ទី២ឬចៅសង្កាត់រងទី២ ជាអនុប្រធាន និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ជាសមាជិកអចិន្ត្រៃយ៍ រួមទាំងតំណាងនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ តំណាងសាលារៀន តំណាងមណ្ឌលសុខភាព និងថ្នាក់ដឹកនាំភូមិជាសមាជិក។ [63]

គួរកត់សម្គាល់ថាអ្នកទទួលបន្ទុកកិច្ចការនារីឃុំ សង្កាត់(អ.ក.ន.ក) ជាប្រតិបត្តិករ និងអ្នកតំណាង កិច្ចការស្ត្រី និងកុមារឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ តែងតាំងសមាជិកក្រុមប្រឹក្សាឃុំ

[61] សេចក្តីសង្ខេបគោលនយោបាយ១, ១១។

[62] សេចក្តីសង្ខេបគោលនយោបាយ១, ១២។

[63] សេចក្តីសង្ខេបគោលនយោបាយ១, ១២។

សង្កាត់ ម្នាក់ជានារី ឲ្យទទួលបន្ទុកកិច្ចការនារី និងកុមារ។ ករណីគ្មាននារីជាសមាជិកាក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវជ្រើសតាំងនារីមួយរូបធ្វើជាជំនួយការទទួលបន្ទុកកិច្ចការនារី និងកុមារ។[64]

**គ. មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី**

មជ្ឈមណ្ឌលអភិវឌ្ឍន៍(ម.អ.ស) បានបង្កើតនៅក្នុងខេត្តចំនួន១៣ ដើម្បីគាំទ្រដល់ការបង្កើនភាពអង់អាចដល់ស្ត្រីផ្នែកសេដ្ឋកិច្ច នៅតាមមូលដ្ឋាន។[65] ម.អ.ស ជាមជ្ឈមណ្ឌលសម្របសម្រួល និងផ្តល់សេវាអភិវឌ្ឍន៍សហគ្រាស ជំនាញបច្ចេសទេស គ្រប់គ្រងកម្មវិធីអក្ខរកម្ម និងជំនាញបំនិនជីវិតដល់ស្ត្រី។បច្ចុប្បន្ន ម.អ.ស ផ្តល់វគ្គបណ្តុះបណ្តាលជំនាញមួយចំនួន ដូចជា កាត់ដេរ តម្បាញ អ៊ុតសក់ និងការកែច្នៃម្ហូបអាហារ ជាដើម។ មជ្ឈមណ្ឌលនេះមានមួយចំនួនដំណើរការយ៉ាងសកម្ម និងមួយចំនួនមិនសូវមានដំណើរការ។ បច្ចុប្បន្នក្រសួងកិច្ចការនារីកំពុងសិក្សា និងស្វែងរកជំរើសនានា ដើម្បីធ្វើឲ្យប្រសើរឡើងនូវដំណើរការនៃ ម.អ.ស ដូចជាកម្មវិធីភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន ជាដើម។

### ១.៣.៣. ស្ថាប័នសង្គមស៊ីវិល

ព្រះរាជាណាចក្រកម្ពុជា មានអង្គការសង្គមស៊ីវិលជាច្រើន ដែលបំពេញការងារក្នុងលើកកម្ពស់សមភាពយេនឌ័រ ក្នុងនោះមានអង្គការសង្គមស៊ីវិលចំនួន១៥ ដែលជាសមាជិកក្រុមការងារបច្ចេកទេសយេនឌ័រ។[66] លើសពីនេះផងដែលក៏មានអង្គការអន្តរជាតិមួយចំនួនដូចជា (ក)ស្ថាប័នអង្គការសហប្រជាជាតិគាំទ្រសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី (ខ)គណៈកម្មាធិការទទួលបន្ទុកស្ថានភាពស្ត្រី និង(គ) គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងស្ត្រី ដែលចូលរួមយ៉ាងសំខាន់ក្នុងការលើកសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រីជាសកល ជាពិសេសក្នុងការតាមដាននូវការអនុវត្តច្បាប់ជាតិ ច្បាប់អន្តរជាតិ និងគោលនយោបាយសាធារណៈទាក់ទងនឹងយេនឌ័ររបស់ប្រទេសនិមួយៗ។

[64] សេចក្តីសង្ខេបគោលនយោបាយ១, ១២។

[65] សេចក្តីសង្ខេបគោលនយោបាយ១, ១៣។

[66] សេចក្តីសង្ខេបគោលនយោបាយ១, ១៤។

### ១.៣.៣.១. គណៈកម្មាធិការទទួលបន្ទុកស្ថានភាពស្ត្រី

គណៈកម្មាធិការទទួលបន្ទុកស្ថានភាពស្ត្រី ត្រូវបានបង្កើតឡើងនៅថ្ងៃទី២១ មិថុនា ១៩៤៦ ដោយមហាសន្និបាទអង្គការសហប្រជាជាតិ។[67] សមាសភាពនៃគណៈកម្មាធិការនេះមានចំនួន១៥រូប ដោយជ្រើសតាំងដោយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច ពីតំណាងប្រទេសនៃសមាជិកអង្គការសហប្រជាជាតិ។[68] វាគឺជាអង្គការអន្តររដ្ឋាភិបាលសំខាន់មួយ ដែលបំពេញការងារដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី។ គណៈកម្មាធិការនេះមានភារកិច្ចរៀបចំនូវអនុសាសន៍ និងរបាយការណ៍ទៅកាន់ក្រុមប្រឹក្សាសន្តិសុខ និងសង្គមកិច្ច ក្នុងការលើកកម្ពស់នូវសិទ្ធិស្ត្រី ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម និងអប់រំ។ គណៈកម្មាធិការនេះក៏មានភារកិច្ច ផ្តល់នូវអនុសាសន៍ដល់ក្រុមប្រឹក្សា ក្នុងការដោះស្រាយបញ្ហាបន្ទាន់តម្រូវឲ្យមានការដោះស្រាយជាប្រញាប់ នៅក្នុងវិស័យដែលពាក់ពន្ធ័នឹងសិទ្ធិស្ត្រី។ [69]

សមិទ្ធផលមួយ ក្នុងចំណោមសមិទ្ធផលធំៗរបស់គណៈកម្មាធិការទទួលបន្ទុកស្ថានភាពស្ត្រីគឺការរៀបចំសន្និសិទ្ធិពិភពលោកលើកទី៤ស្តីពីស្ត្រីដែលធ្វើឡើងនៅទីក្រុងប៉េកាំងឆ្នាំ១៩៩៥ ដែលបានបញ្ចាប់ទៅជាមួយការអនុម័តសេចក្តីប្រក និងផែនការសកម្មភាពទីក្រុងប៉ាកាំង។ដូច្នេះគណៈកម្មាធិការនេះមានតួនាទីក្នុងការពិនិត្យតាមដាន និងពិនិត្យឡើងវិញនូវវឌ្ឍនភាព និងបញ្ហានានា ក្នុងការអនុវត្តសេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងប៉ាកាំង។ បន្ថែមពីលើនេះគណៈកម្មាធិការទទួលបន្ទុកស្ថានភាពស្ត្រី ក៏ជាស្ថាប័នដ៏សំខាន់មួយដែលមានភារកិច្ចពិនិត្យឡើងវិញទៅលើ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ផ្នែកខាងការផ្តល់ភាពអង់អាចដល់ស្ត្រី និងការកំណត់របៀបវីរៈក្រោយឆ្នាំ២០១៥ ដែលពាក់ពន្ធ័ជាមួយនឹងយេនឌ័រនៅក្នុងក្របខណ្ឌ គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។

### ១.៣.៣.២. គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី

ក្នុងគោលបំណងត្រួតពិនិត្យវឌ្ឍនភាព នៃការអនុវត្តអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីមួយត្រូវបានបង្កើតឡើង ដោយអង្គការសហប្រជាជាតិ។ គណៈកម្មាធិការនេះ មាន

[67] អង្គកាសហប្រជាតិ, "គណៈកម្មាធិការទទួលបន្ទុកស្ថានភាពស្ត្រី", *Journal of the Economic and Social council 29* (១៣ កក្កដា ១៩៤៦):525។

[68] ដូច៦៧។

[69] ដូច៦៧។

អ្នកជំនាញការ១៨រូប នៅពេលអនុសញ្ញានេះចូលជាធរមាន។[70] បន្ទាប់ពីរដ្ឋទី៣៥បានផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញាCEDAW គណៈកម្មាធិការនេះនឹងមានជំនាញការចំនួន២៣រូប ដែលមានសីលធម៌ និងមានសមត្ថកិច្ចខ្ពស់ក្នុងវិស័យដែលត្រូវអនុវត្តសិទ្ធិសញ្ញានេះ។[71] អ្នកជំនាញត្រូវជ្រើសរើសតាមការបោះឆ្នោតសម្ងាត់ ពីបញ្ជីបេក្ខជនដោយស្នើដោយរដ្ឋភាគី ហើយរដ្ឋភាគីនីមួយៗអាចដាក់ស្នើបេក្ខជនម្នាក់ក្នុងចំណោមជនជាតិរបស់ខ្លួន។[72]

គណៈកម្មាធិការនេះមានភារកិច្ច ធ្វើរបាយការណ៍ប្រចាំឆ្នាំជូនមហាសន្និបាទអង្គការសហប្រជាជាតិតាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច អំពីសកម្មភាពរបស់ខ្លួន។[73] បន្ថែមពីនេះផងដែរ ក៏ធ្វើការផ្តល់យោបល់ និងអនុសាសន៍ ផ្អែកលើការពិនិត្យរបាយកាណ៍ជាតិ ស្តីពីការអនុវត្តអនុសញ្ញាCEDAW និងពត៌មានដែលទទួលបានមកពីរដ្ឋភាគី។[74] ការផ្តល់យោបល់ និងអនុសាសន៍នឹងត្រូវដាក់បញ្ចូលក្នុងរបាយការណ៍របស់គណៈកម្មាធិការ អមដោយមូលវិចារណ៍របស់រដ្ឋជាភាគីប្រសិនបើមាន។ គួរឲ្យកត់សម្គាល់ឃើញថា នៅក្នុងឆ្នាំ២០១៣ គណៈកម្មាធិការនេះបានត្រួតពិនិត្យសារឡើងវិញលើរបាយការណ៍លើកទី៤និងទី៥ របស់កម្ពុជានិងអង្គការមិនមែនរដ្ឋាភិបាល។ក្រោយពីការពិនិត្យនេះ គណៈកម្មាធិការផ្តល់យោបល់សន្និដ្ឋាន ដែលដាក់ចេញនូវអនុសាសន៍ជាក់លាក់សម្រាប់ប្រទេសកម្ពុជាក្នុ ការសម្រេចឲ្យបាននូវការលុបបំបាត់ការរើសអើងប្រឆាំងស្រ្តីភេទ។

### ១.៣.៣.៣. អង្គការសហប្រជាជាតិគាំទ្រសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្រ្តី

អង្គការសហប្រជាជាតិគាំទ្រសមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្រ្តី ឬហៅកាត់ថា UN Womenគឺជាស្ថាប័នមួយរបស់អង្គការសហប្រជាជាតិ បង្កើតឡើងសម្រាប់លើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្រ្តីលើពិភពលោក។[75] ស្ថាប័ននេះ ត្រូវបានបង្កើតឡើងដើម្បីពន្លឿនវឌ្ឍនភាពក្នុងការបំពេញ នូវសេចក្តីត្រូវការរបស់ស្រ្តី និងក្មេងស្រី តាមរយៈយុទ្ធនាការ

[70] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្រ្តីភេទ, មាត្រា១៧។

[71] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្រ្តីភេទ, មាត្រា១៧។

[72] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្រ្តីភេទ, មាត្រា១៧។

[73] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្រ្តីភេទ, មាត្រា២១។

[74] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្រ្តីភេទ, មាត្រា២១។

[75] អង្គការសហប្រជាជាតិ, *Comprehensive proposal for the composite entity for gender equality and the empowerment of women*[សេចក្តីស្នើសុំលម្អិតស្តីពីការបង្កើតអង្គភាពសម្រាប់គាំទ្រសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្រ្តី], Report of the Secretary General (New York: UN, 2010), ទំព័រ១។

ជាសកលមួយ។[76] UN Women គាំទ្ររដ្ឋជាសមាជិកអង្គការសហប្រជាជាតិតាមរយៈ ការកំណត់នូវបទដ្ឋានជាសកល សម្រាប់ការសម្រេចឲ្យបាននូវសមភាពយេនឌ័រ និងធ្វើការជាមួយរដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីបង្កើតគោលនយោបាយ កម្មវិធី និងសេវា សម្រាប់ការអនុវត្តបទដ្ឋានទាំងនោះ។វាឈរនៅក្នុងគោលការណ៍ ការចូលរួមស្មើគ្នារបស់ស្ត្រីនៅគ្រប់ទិដ្ឋភាពនៃជីវិត ដែលផ្តោតសំខាន់លើចំនុចអាទិភាពចំនួន៥ ដូចជា (១) ការបង្កើនការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី (២) ការបញ្ឈប់នូវអំពើហិង្សាប្រឆាំងស្ត្រី (៣) ការជំរុញការចូលរួមរបស់ស្ត្រី នៅរាល់ទិដ្ឋភាពនៃវឌ្ឍនភាពសន្តិសុខ និងស្ថេរភាព (៤)ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និង(៥) ការផ្តោតលើសមភាពយេនឌ័រក្នុងការបង្កើតផែនការថវិកា និងផែនការអភិវឌ្ឍន៍ជាតិ។[77] ស្ថាប័នអង្គការសហប្រជាជាតិមួយនេះ ក៏ធ្វើសហប្រតិបត្តិការ និងលើកកម្ពស់ប្រពន្ធ័ការងាររបស់អង្គការសហប្រជាជាតិដើម្បីពន្លឿនសមភាពយេនឌ័រ។

ចំពោះស្ថាប័នUN Women ប្រចាំកម្ពុជា ចូលរួមធ្វើកិច្ចការងារមួយចំនួនធំក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រីកម្ពុជា។ កិច្ចការទាំងនោះមានដូចជា ការបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យនយោបាយ និងដំណើរការនៃការធ្វើសេចក្តីសម្រេច វិស័យសេដ្ឋកិច្ច និងឱកាសរស់នៅ រួមទាំងការផ្តល់ចំណេះដឹងឲ្យពួកគេស្គាល់ និងចេះទាមទារសិទ្ធិរបស់ខ្លួន។ដើម្បីសម្រេចឲ្យបានកិច្ចការងារទាំងនេះ UN Women ប្រចាំកម្ពុជាបានបង្កើតនូវកិច្ចខំប្រឹងប្រែងដូចជា ៖[78]

- ពង្រឹកនូវអភិបាលកិច្ចប្រជាធិបតេយ្យ តាមរយៈការបង្កើនការចូលរួមរបស់ស្ត្រី នៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចទាំងក្នុង និងក្រៅផ្លូវការ។ UN Women គាំទ្រអង្គការក្រៅរដ្ឋាភិបាល ក្នុងការលើកកម្ពស់ការចូលរួមរបស់ស្ត្រី នៅក្នុងការបោះឆ្នោត។ តាមរយៈការសហការជាមួយអង្គការក្រៅរដ្ឋាភិបាលដែលគាំទ្រស្ត្រី ដើម្បីផ្តល់នូវការបណ្តុះបណ្តាល ដល់បេក្ខជនជាស្ត្រីក្នុងការបោះឆ្នោតឃុំ សង្កាត់នូវយុទ្ធនាការស្តីពីការបោះឆ្នោត និងអភិបាលកិច្ច។ ជាមួយនឹងការ

---

[76] ដូច៧៥, ២។

[77] ដូច៧៥, ៥។

[78]គេហទំព័រ UN Women: UN Women in Cambodia, អាចស្វែងរកបាននូវៈ http://asiapacific.unwomen.org/en/countries/cambodia/about-un-women-in-cambodia(ចូលមើលចុងក្រោយនៅថ្ងៃទី ០២ មិថុនា ២០១៦)។

ផ្សព្វផ្សាយជាសាធារណៈ អំពីសារៈសំខាន់នៃការមានជាតំណាងក្នុងវិស័យនយោបាយដើម្បីស្វែករកសំឡេងឆ្នោតគាំទ្រ។

- ការបញ្ជ្រាបយេនឌ័រក្នុងផែនការជាតិ និងគោលនយោបាយ។ UN women ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ស្ថាប័នរាជរដ្ឋាភិបាល ដូចជាក្រសួងកិច្ចការនារី និងស្ថាប័នដទៃទៀតដើម្បីបញ្ចូលគោលការណ៍យេនឌ័រទៅក្នុងការអភិវឌ្ឍន៍ ការអនុវត្ត និងការត្រួតពិនិត្យផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ថវិកា និងផែនការផ្សេងទៀត។ ការគាំទ្រនេះក៏ធ្វើឡើងតាមរយៈការត្រួតពិនិត្យកិច្ចខំប្រឹងប្រែង ទៅការអនុវត្តអនុសញ្ញាស្តីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងផែនការយុទ្ធសាស្ត្រនារីរតនៈ។

- ការលើកកម្ពស់ការផ្តល់ភាពអង់អាចដល់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច។ UN Women គាំទ្រនូវគម្រោងថវិកា ទាំងក្នុងចំណោមរាជរដ្ឋាភិបាល និងសង្គមស៊ីវិលដើម្បីត្រួតពិនិត្យលើការបែងចែកធនធាន ដើម្បីធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសេដ្ឋកិច្ចរបស់ស្ត្រី។ UN Women ក៏ចូលរួមដោះស្រាយនូវបញ្ហាការរំលោភបំពានទៅសិទ្ធិពលករចំណាកស្រុក និងបង្កើនការប្រុងប្រយត្ន័របស់ពួកគេ និងសហការជាមួយរាជរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហា។

- ការលើកកម្ពស់ភាពជាអ្នកដឹកនាំ និងការចូលរួមរបស់អង្គការគាំទ្រស្ត្រីដែលមានផ្ទុកមេរោគ HIV និងស្ត្រីដែលរងគ្រោះដោយHIV/AIDS។ UN Women សហការជាមួយរាជរដ្ឋាភិបាលក្នុងការបង្កើតនូវគោលនយោបាយ កម្មវិធី និងការបែងចែកធនធាន ដើម្បីដោះស្រាយបញ្ហាការរីករាលដាលនៃ HIV/AIDS។

- ការកំណត់នូវស្ថានភាពស្ត្រីពិការ នៅកម្ពុជាដោយប្រើប្រាស់ក្របខណ្ឌនៃCEDAW។ UN Women គាំទ្រនយោបាយជាតិសម្រាប់សមភាពយេនឌ័ (ផែនការយុទ្ធសាស្ត្រនារីរតនៈ)គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងផែនការសកម្មភាពជាតិសម្រាប់ជនពិការ។

- ការដោះស្រាយបញ្ហាអំពើហិង្សាប្រឆាំសងស្ត្រី។ UN Women គាំទ្ររាជរដ្ឋាភិបាលក្នុងការប្រមូល និងវិភាគទិន្នន័យ សម្រាប់ការពារ និងឆ្លើយតបនឹងអំពើហិង្សាលើយេនឌ័រ។ សហការជាមួយក្រសួងកិច្ចការនារី បានជួយនូវការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរក្រសួង ក្នុងការអនុវត្ត និងត្រួតពិនិត្យផែនការជាតិការពារនូវអំពើហិង្សាប្រឆាំងស្ត្រី។

កិច្ចការងាររបស់UN Women ប្រចាំនៅកម្ពុជាដើម្បីសម្រេចឲ្យបាននូវសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រីគឺផ្តោតទៅគ្រប់វិស័យ និងគ្រប់ទិដ្ឋភាពនៃជីវិតរបស់ស្ត្រី។ប៉ុន្តែគួរឲ្យកត់សម្គាល់ឃើញថា ស្ថាប័ននេះគាំទ្រច្រើននូវគម្រោងថវិកា ដែលផ្តោតលើការលើកស្ទួយស្ថានភាពស្ត្រីកម្ពុជានៅក្នុងវិស័យសេដ្ឋកិច្ច ដើម្បីឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ពួកគាត់។ បន្ថែមពី

នេះទៀត ក៏ធ្វើការសិក្សាស្រាវជ្រាវទៅលើបញ្ហាប្រឈមរបស់ស្ត្រីនៅក្នុងវិស័យនេះ ដើម្បីផ្តល់អនុសាសន៍ ដល់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍន៍នូវគោលនយោបាយដោះស្រាយបញ្ហា។

# ជំពូក២
# ស្ថានភាពបច្ចុប្បន្នរបស់ស្ត្រីកម្ពុជាក្នុងវិស័យសេដ្ឋកិច្ច

បើនិយាយពីស្ថានភាពរបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច មានចំនុចបីសំខាន់ៗដែលត្រូវយកមកពិនិត្យ ក្នុងនោះគឺការចូលរួមរបស់ស្ត្រីនៅក្នុងសកម្មភាពសេដ្ឋកិច្ច អត្ថប្រយោជន៍ដែលស្ត្រីទទួលបានពីការអភិវឌ្ឍន៍សេដ្ឋកិច្ច និងស្ត្រីនៅក្នុងតួនាទីក្នុងការធ្វើសេចក្តីសម្រេច។[79] ទាំងតំណាងរាជរដ្ឋាភិបាលនិងសង្គមស៊ីវិលបានទទួលស្គាល់ថាស្ថានភាពសេដ្ឋកិច្ចរបស់ស្ត្រីកម្ពុជាមានលក្ខណៈល្អប្រសើរជាងមុន។ កម្ពុជាទទួលបានសមិទ្ធផលក្នុងការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ។ នៅមួយរយៈពេលចុងក្រោយនេះ ស្ត្រីកម្ពុជាបានចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពសេដ្ឋកិច្ច ហើយគម្លាតយេនឌ័រនៅក្នុងវិស័យនេះក៏ត្រូវបានកាត់បន្ថយមួយចំនួន ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយគម្លាតយេនឌ័រនៅតែមានលក្ខណៈធំនៅក្នុងផ្នែកមួយចំនួននៅក្នុងសេដ្ឋកិច្ច។

## ២.១. ការចូលរួមរបស់ស្ត្រីនៅក្នុងសកម្មភាពសេដ្ឋកិច្ច

ស្ត្រីកម្ពុជាភាគច្រើន បានចូលរួមនៅក្នុងកម្លាំងពលកម្មទីផ្សារ នៅរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ការចូលរួមរបស់ស្ត្រីនៅក្នុងកម្លាំងពលកម្មសរុបចន្លោះអាយុ១៥ឆ្នាំ-៦៤ឆ្នាំ បានធ្លាក់ចុះបន្តិចពី៨០.៤% នៅក្នុងឆ្នាំ២០០៩ មក៧៧.៥% នៅក្នុងឆ្នាំ២០១៤។[80] ប៉ុន្តែគម្លាតយេនឌ័រនៃកម្លាំងពលកម្មសរុបរវាងបុរស និងស្ត្រីបានធ្លាក់ចុះពី៩.៤%នៅក្នុងឆ្នាំ២០១២ មកត្រឹម៦.៦%នៅក្នុងឆ្នាំ២០១៤។[81] នៅក្នុងឆ្នាំ២០០៩ ការចូលរួមរបស់ស្ត្រីនៅក្នុងកំលាំងពលកម្មសរុប មានកំរិតខ្ពស់គឺដោយសារការបើកទ្វារឡើងវិញនូវរោងចក្រសហគ្រាស ដែលបានបិទមួយរយៈក្នុងឆ្នាំ២០០៧ និង២០០៨ ដោយសារតែវិបត្តិសេដ្ឋកិច្ចពិភពលោក។ តាមរយៈការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា បានបង្ហាញឲ្យឃើញថា ភាគរយនៃស្ត្រី និងបុរស ចូលរួមនៅក្នុងកំលាំងពលកម្មមានប្រហាក់ប្រហែលគ្នានៅក្នុងចន្លោះអាយុ១៥ឆ្នាំ ដល់១៩ឆ្នាំ ដែលបុរសមាន៦០.៥% និងស្ត្រី៦០.១%នៅក្នុងឆ្នាំ២០១៤

---

[79] ធនាគារអភិវឌ្ឍន៍អាស៊ី(ADB), Promoting women's economic empowerment in Cambodia[ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៅកម្ពុជា],( Mandaluyong: ADB, 2015), ៧។

[80] វិទ្យាស្ថានជាតិស្ថិតិ,ក្រសួងផែនការ, Cambodia Socio-economic Survey 2014[អង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា២០១៤], ២០១៥, ៦៧។

[81] ដូច៨០។

ៗ[82] ជាការពិតណាស់តួរលេខនេះ បង្ហាញពីការកើនឡើងនៃឱកាស និងសកម្មភាពក្នុងការចូលរួមរបស់ស្ត្រី និងក្មេងស្រីនៅក្នុងការអប់រំ។

ការចូលរួមក្នុងកំលាំងពលកម្មរបស់ស្ត្រីកម្ពុជា មានកម្រិតខ្ពស់ជាងគេនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។[83] ឱកាសការងារមានច្រើនសម្រាប់ស្ត្រី ប៉ុន្តែការងារទាំងនោះភាគច្រើនជាការងារកម្រិតទាបនិងងាយរងគ្រោះ។ នៅក្នុងឆ្នាំ២០០៩ ភាគរយនៃការងាររងគ្រោះសម្រាប់ស្ត្រីមាន៥២.៤% ខណៈបុរស៤៦.១% ហើយភាគរយនេះបានកើនឡើងដល់៥៤.២%សម្រាប់ស្ត្រី ខណៈពេលដែលការងាររងគ្រោះសម្រាប់បុរសមានការថយចុះមកត្រឹម៤៥.៤%នៅក្នុងឆ្នាំ២០១៤។[84]

*តារាងទី១៖ កម្លាំងពលកម្មជាភាគរយចន្លោះអាយុ(១៥-៦៤ឆ្នាំ) បែងចែកទៅតាមវិស័យ និងភេទ ឆ្នាំ២០០៩ និង ២០១៤*[85]

| ប្រភេទវិស័យ | ២០០៩ | | ២០១៤ | |
|---|---|---|---|---|
| | ស្ត្រី | បុរស | ស្ត្រី | បុរស |
| កសិកម្ម | ៥៧.៨% | ៥៧.៤% | ៤៦.៧% | ៤៣.៩% |
| ឧស្សាហកម្ម | ១៦.២% | ១៥.៥% | ២៤.១% | ២៤.៥% |
| សេវាកម្ម | ២៦.០% | ២៧.០% | ២៩.២% | ៣១.៥% |

*(ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ សង្កេតសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ២០១៤)*

នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ផលិតកម្មនៅកម្ពុជាបានធ្វើការផ្លាស់ប្តូរពីវិស័យកសិកម្មមកវិស័យឧស្សាហកម្ម និងសេវាកម្ម។ ការផ្លាស់ប្តូរនេះគឺមានទំនាក់ទំនងជាមួយនឹងការចូលរួមរបស់បុរស និងស្ត្រីនៅក្នុងវិស័យទាំងបី។ ការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យកសិកម្មបានធ្លាក់ចុះ ខណៈបានកើនឡើងនៅក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម។ ភាគរយនៃការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យកសិកម្មខ្ពស់ជាងបុរស គឺ៤៦.៧% និង៤៣.៩% ប៉ុន្តែចំពោះវិស័យផ្សេងៗទៀត គឺនៅមានកម្រិតទាបជាងនៅឡើយ។[86]

[82] ដូច៨០។

[83] ដូច៧៩, ៧។

[84] ដូច៨០, ៧០។

[85] ដូច៨០។

[86] ដូច៨០, ៧៣។

## ២.២. អត្ថប្រយោជន៍របស់ស្ត្រីពីការអភិវឌ្ឍន៍សេដ្ឋកិច្ច

ផ្ទុយពីការចូលរួមយ៉ាងសកម្មរបស់ស្ត្រីកម្ពុជានៅក្នុងសេដ្ឋកិច្ច ស្ត្រីទទួលបានអត្ថប្រយោជន៍តិចជាងការចូលរួមរបស់ពួកគេ ប្រសិនសិនប្រៀបធៀបនឹងបុរស ប៉ុន្តែមានការកើនឡើងបើធៀបនឹងពេលពីមុន។ បើពិនិត្យទៅលើអត្ថប្រយោជន៍ដែលស្ត្រីទទួលបានពីការអភិវឌ្ឍន៍សេដ្ឋកិច្ចគេត្រូវពិនិត្យទៅវិស័យបីសំខាន់ៗដូចជាៈ (១) ស្ត្រីនៅក្នុងវិស័យកសិកម្ម (២) ស្ត្រីនៅក្នុងការងារអាជីវកម្ម និង(៣) ស្ត្រីនៅក្នុងកាងារមានប្រាក់កម្រៃ។

### ២.២.១. ស្ត្រីនៅក្នុងវិស័យកសិកម្ម

នៅក្នុងឆ្នាំ២០១៤ ស្ត្រីប្រហែលជិត៥០%ក្នុងចន្លោះអាយុ១៥ឆ្នាំ ដល់៦៤ឆ្នាំ នៅក្នុងប្រទេស ហើយចំនួននេះកាន់តែខ្ពស់ថែមទៀតសម្រាប់ស្ត្រី នៅជនបទដែលធ្វើការនៅក្នុងវិស័យចម្បងឬវិស័យទី១(មានកសិកម្ម រុក្ខប្រមាញ់ និងនេសាទ)។[87] នេះបញ្ជាក់ពីសារៈសំខាន់នៃវិស័យកសិកម្មក្នុងការប្រកបមុខរបរចិញ្ចឹមជីវិតសម្រាប់ស្ត្រី ជាពិសេសស្ត្រីនៅជនបទ។ នៅលើទីផ្សារផលិតផលកសិកម្មមានតម្លៃទាប ហើយការធ្វើកសិកម្មក៏ងាយប្រមុខមុខនឹងបញ្ហាគ្រោះធម្មជាតិ ដែលមានគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតជាដើម។ បញ្ហានេះកាន់តែធ្វើអត្ថប្រយោជន៍របស់ស្ត្រីដែលទទួលបានពីវិស័យនេះកាន់តែទាបថែមទៀត។ នៅក្នុងឆ្នាំ២០១២ ស្ត្រីអាចរកប្រាក់ចំណូលជាមធ្យមប្រហែល$១០៣ ក្នុង១ខែ ដែលស្មើនឹង៩១%នៃប្រាក់ចំណូលរបស់បុរសដែលទទួលបាន$១១៤ ពីការងារកសិកម្ម។ [88] ការចូលរួមរបស់ស្ត្រីច្រើនជាងបុរសនៅក្នុងវិស័យកសិកម្មជាពិសេសនៅទីជនបទប៉ុន្តែអត្ថប្រយោជន៍ដែលស្ត្រីទទួលបាននៅតែតិចជាងបុរស។

### ២.២.២. ស្ត្រីនៅក្នុងការងារអាជីវកម្ម

នៅក្នុងឆ្នាំ២០១១ កម្ពុជាមានអាជីវកម្មសរុបប្រហែល ៥០៥,១៣៤អាជីវកម្ម ដែលក្នុងនោះអាជីវកម្មប្រហែល៣២៩,០០៦ ដែលស្មើនឹង៦៥.១នៃអាជីវកម្មសរុបគ្រប់គ្រងដោយស្ត្រី ខណៈអាជីវកម្មគ្រប់គ្រងដោយបុរសមានប្រហែល៣៤.៩%។ [89] ភាគច្រើននៃអាជីវកម្មរបស់ស្ត្រីគឺសហគ្រាស

---

[87] ដូច៨០, ៧៩។

[88]វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ និងអង្គការពលកម្មពិភពលោក, *អង្កេតកម្លាំងពលកម្ម និងពលកម្មកុមារកម្ពុជា ២០១២៖ របាយការណ៍ស្តីពីកម្លាំងពលកម្ម*,(ភ្នំពេញ៖វិទ្យាស្ថានជាតិស្ថិតិ, ២០១៣), ៥៩។

[89] វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ, *Economic Census of Cambodia2011: Analysis of census results[ជំរឿនសេដ្ឋកិច្ចកម្ពុជា២០១១៖ ការវិភាគទៅលើលទ្ធផលជំរឿន], Women in Business report No9*,(ភ្នំពេញ៖វិទ្យាស្ថានជាតិស្ថិតិ , ២០១៣), ១។

ខ្នាតមីក្រូ ដែល៥០.៨% នៃជីវកម្មគ្រប់គ្រងដោយមនុស្ស១នាក់ ៣៣.៥% គ្រប់គ្រងដោយមនុស្ស២នាក់ ៨.២%គ្រប់គ្រងដោយមនុស្ស៣នាក់ និងមាន៣.៣% តែប៉ុណ្ណោះដែលគ្រប់គ្រងដោយមនុស្សពី៤ដល់៩នាក់។[90]

*តារាងទី២៖ ភាគរយនៃការគ្រប់គ្រងអាជីវកម្ម បែងចែកទៅតាមប្រភេទនិងភេទ, ឆ្នាំ២០១១*[91]

| ប្រភេទអាជីវកម្ម | ចំនួនអាជីវកម្ម | | |
|---|---|---|---|
| | សរុប | ស្ត្រីជាម្ចាស់ | បុរសជាម្ចាស់ |
| ចំនួនអាជីវកម្មសរុប | ១០០% | ៦៥.១% | ៣៤.៩% |
| លក់ដុំ និងរាយ ជួសជុលយានយន្ត | ៥៧.២% | ៤២.៧% | ១៤.៦% |
| សណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋាន | ១៣.៨% | ១០.៩% | ២.៩% |
| កមន្តសាល | ១៤.៩% | ៦.៩% | ៧.៩% |
| សេវាផ្សេងៗ | ១៤.១% | ៤.៦% | ៩.៥% |

*(ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ របាយការណ៍ជាតិស្តីពីលទ្ធផលជំរឿនសេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០១១)*

ស្ត្រីកម្ពុជាគ្រប់គ្រងមួយភាគធំនៃអាជីវកម្ម តែអាជីវកម្មរបស់ស្ត្រីភាគច្រើនផ្តោតតែទៅលើវិស័យមួយចំនួនតូចនៃឧស្សាហកម្ម ដូចជា៖ ផ្នែកលក់ដុំ និងលក់រាយ ផ្ទះសំណាក់ឬសណ្ឋាគារ និងភោជនីយដ្ឋាន កមន្តសាល និងសេវាកម្មផ្សេងៗទៀត ដែលចំនួនសរុបស្មើនឹង៩៧%នៃអាជីវកម្មសរុបគ្រប់គ្រងដោយស្ត្រី។ ថ្វីត្បិតតែស្ត្រីគ្រប់គ្រងនូវអាជីវកម្មភាគច្រើននៃប្រទេស ប៉ុន្តែអាជីវកម្មរបស់ស្ត្រីអាចរកប្រាក់ចំណូលប្រហែលតែ៤០% នៃអាជីវកម្មសរុប និង៥១% នៃប្រាក់ចំណេញអាជីវកម្មសរុបក្នុងប្រទេស។[92] ចំណែកឯប្រាក់ចំណេញដែលស្ត្រីម្នាក់ៗ អាចរកបានពី

[90] ដូច៨៩, ៨។

[91] វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ, Economic census of Cambodia 2011: National report on census result[ជំរឿនសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១១៖ របាយការណ៍ជាតិស្តីពីលទ្ធផលជំរឿន],(ភ្នំពេញ៖វិទ្យាស្ថានជាតិស្ថិតិ, ២០១២)។

[92] ដូច៨៩, ២៩។

អាជីវកម្មរបស់ខ្លួនមានចំនួន$៨៥៤ ប្រចាំឆ្នាំ នៅពេលដែលបុរសអាចរកបានដល់$១,២៨៧។ [93] ដូច្នេះអាជីវកម្មរបស់ស្ត្រីជាមធ្យមមានលក្ខណៈតូចជាង និងអាចរកប្រាក់ចំណេញតិចជាងបុរស។

### ២.២.៣. ស្ត្រីនៅក្នុងការងារដែលមានប្រាក់កម្រៃ

នៅក្នុងឆ្នាំ២០១២ ស្ត្រីចំនួន៣០% ធ្វើការងារដែលមានប្រាក់កម្រៃ ហើយតួរលេខបានកើនឡើងជាបន្តបន្ទាប់ដល់៣៩.៣% នៅក្នុងឆ្នាំ២០១៤(ចន្លោះអាយុ១៥-៦៤ឆ្នាំ)។[94] ប្រាក់ឈ្នួលជាមធ្យមប្រចាំខែរបស់ស្ត្រី គឺប្រហែល$១០៤ ដែលស្មើនឹង៨០.៨% នៃប្រាក់ជាមធ្យមរបស់បុរស ($១២៨)។[95] ការងារមានប្រាក់កម្រៃរបស់ស្ត្រី មួយភាគធំប្រមូលផ្តុំនៅក្នុងវិស័យកាត់ដេរដែលមានចំនួន៤៥% នៃការងារមានប្រាក់កម្រៃសរុបក្រៅពីនោះមាន៥.៥%នៅក្នុងវិស័យរដ្ឋបាលសាធារណៈ និង៧.៧% នៅក្នុងវិស័យអប់រំ។ [96]

នៅក្នុងវិស័យកាត់ដេរ ផលិតភាពពលកម្មកើនឡើងទ្វេរដងពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១២ ប៉ុន្តែប្រាក់ឈ្នួលអប្បរមានៅថេរដដែល រហូតដល់ខែមករា ឆ្នាំ២០១៤ទើបបានកើនឡើងដល់$១០០ក្នុងមួយខែ និងមួយរយៈបន្ទាប់មកបានកើនឡើងដល់$១២៨ ក្នុងមួយខែ។[97] ទោះបីជាមានការប្រសើរជាងមុន នូវការអនុលោមតាមច្បាប់ការងារ ដែលជំរុញដោយអង្គការពលកម្មអន្តរជាតិ(ILO) តាមរយៈគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ក៏ល័ក្ខខ័ណ្ឌការងារនៅក្នុងរោងចក្រមិនទាន់មានភាពល្អប្រសើរនៅឡើយ។[98] កាងារដែលមានប្រាក់កម្រៃក្នុងវិស័យកាត់ដេរ ផ្តល់ប្រាក់កម្រៃតិចសម្រាប់ស្ត្រីបើប្រៀបធៀប នឹងប្រាក់កម្រៃដែលរកបានដោយស្ត្រីនៅក្នុងវិស័យផ្សេងៗទៀត។

## ២.៣. សម្លេងរបស់ស្ត្រី និងតួនាទីក្នុងការធ្វើសេចក្តីសម្រេច

សម្លេង និងឱកាសរបស់ស្ត្រីនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចគឺជះឥទ្ធិពលទៅដល់ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។ ដោយសារស្ត្រីប្រមូលផ្តុំក្នុងការងារមានជំនាញទាប នៅក្នុងឆ្នាំ២០១៤មានស្ត្រីចំនួនតែ៣.៨%(ធៀបនឹងបុរស៥.៤%) បានបំរើការងារក្នុងមុខតំណែងខ្ពស់ចំនួនបី

[93] ដូច៨៩, ២៩។

[94] ដូច៨០, ៧០។

[95] ដូច៨៩, ១៤។

[96] ដូច៧៩, ១៣។

[97] ដូច៧៩, ១៤។

[98] ដូច៧៩, ១៣។

នៅក្នុងវិស័យឯកជនដូចជា៖ អ្នកគ្រប់គ្រង អ្នកជំនាញការ និងអ្នកជំនាញបច្ចេកទេស។[99] ចំណែកនៅក្នុងរដ្ឋបាលសាធារណៈវិញមានស្ត្រីមានចំនួនប្រហែលជា៥.៥%ក្នុងឆ្នាំ២០១៣។[100] ជាក់ស្តែងស្ត្រីតំណាងក្នុងថ្នាក់ធ្វើសេចក្តីសម្រេចនៅក្នុងវិស័យសាធារណៈមានការកើនឡើង ដែលលទ្ធផលជាវិជ្ជមានបានបង្ហាញពីប្រសិទ្ធភាពក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនតួនាទីស្ត្រីក្នុងការធ្វើសេចក្តីសម្រេច តាមរយៈការបញ្ចូលគោលការណ៍ទៅក្នុងគោលនយោបាយ និងកម្មវិធីផ្សេងៗ។ប្រសិនបើនិយាយពីសម្លេងនិងតួនាទីក្នុងការធ្វើសេចក្តីសម្រេច គេត្រូវក្រលេកទៅមើលតួនាទីក្នុងការធ្វើសេចក្តីសម្រេចរបស់ស្ត្រីនៅក្នុងស្ថាប័នសំខាន់ៗរបស់រដ្ឋ និងនៅក្នុងវិស័យមួយចំនួនដូចជា៖ (ក)ស្ថាប័ននីតិប្បញ្ញត្តិ (ខ)ស្ថាប័ននីតិប្រតិបត្តិ (គ)ស្ថាប័នតុលាការ និង(ឃ) ស្ត្រីនៅក្នុងមុខងារសាធារណៈ។

### ២.៣.១. ស្ថាប័ននីតិប្បញ្ញត្តិ

#### ២.៣.១.១. ស្ថាប័នព្រឹទ្ធសភា

នៅក្នុងស្ថាប័នព្រឹទ្ធសភា ស្ត្រីទទួលបានអាសនៈចំនួន១៤.៧៥% ក្នុងនោះមានសមាជិកជាស្ត្រីចំនួន៩រូប ក្នុងចំណោម៦២រូប។[101] ចំនួននេះមិនមានការប្រែប្រួលប្រសិនបើប្រៀបធៀបទៅនឹងអាណត្តិទី១ នៃព្រឹទ្ធសភាក្នុងឆ្នាំ១៩៩៩។ [102] ខណៈតួនាទីរបស់ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចមានការកើនឡើងនៅក្នុងស្ថាប័នផ្សេងៗរបស់រដ្ឋ តំណាងដែលជាស្ត្រីនៅក្នុងស្ថាប័នព្រឹទ្ធសភាមិនមានការផ្លាស់ប្តូរ គិតចាប់ពីឆ្នាំ១៩៩៩មក ហើយនៅតែមានអាត្រាក្រោម១៥%។ ចំនុចបង្ហាញថាតំណាងស្ត្រីនៅក្នុងស្ថាប័នមួយចំនួននៅមានកំរិត ទោះបីជាមានកើនឡើងច្រើននៅក្នុងស្ថាប័នផ្សេងទៀតក៏ដោយ។

[99] ដូច៨០, ៧១។

[100] ដូច៩៦។

[101] ក្រសួងកិច្ចការនារី, *សេចក្តីសង្ខេបគោលនយោបាយ៨៖ ភាពជាអ្នកដឹកនាំស្ត្រីក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ និងនយោបាយ*, ២០១៤, ៤ (ពីពេលនេះហៅថាសេចក្តីសង្ខេបគោលនយោបាយ៨)។

[102] សេក្តីសង្ខេបគោលនយោបាយ៨, ៤។

### ២.៣.១.២. ស្ថាប័នរដ្ឋសភា

តំណាងស្ត្រីនៅស្ថាប័នរដ្ឋសភាបានកើនឡើង៣ដងក្នុងរយៈពេល២ទសវត្សរ៍នេះ គឺពី៦%នៅក្នុងនីតិកាលទី១ ដល់២០.៣៣%នៅក្នុងនីតិកាលទី៥ ដោយមានការកើនឡើងជាមធ្យមចំនួន ៦.៨៤% សម្រាប់នីតិកាលនីមួយៗនៃរដ្ឋសភា។[103] ប៉ុន្តែចំនួនអាសនៈរបស់ស្ត្រីមានការថយចុះមួយអាសនៈពី២៦អាសនៈនៅក្នុងនីតិកាលទី៤ មក២៥អាសនៈក្នុងនីតិកាលទី៥ ដែលស្មើនឹង២១% មកត្រឹម២០.៣៣%។[104] ចំណែកឯនៅក្នុងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រក្នុងនីតិកាលទី៥ មានបេក្ខនារី១៦៨រូប ក្នុងចំណោមបេក្ខជន បេក្ខនារីសរុប៨៨៦រូប។ ចំនួននេះមានការកើនឡើង៤.១៦% ប្រៀបធៀបទៅនឹងនីតិកាលទី៤ ដែលមានតែ១៤.៨០% ដែលស្មើនឹងបេក្ខនារីចំនួន ១៧២រូបក្នុងចំនួនបេក្ខជន បេក្ខនារីចំនួន១,១៦២រូប។[105]

### ២.៣.២. ស្ថាប័ននីតិប្រតិបត្តិ

ចំនួនស្ត្រីមានតំណែងនៅក្នុងរាជរដ្ឋាភិបាលមានការកើនឡើងជាបន្តបន្ទាប់ ជាពិសេសក្នុងឆ្នាំ ២០១៣។ នៅក្នុងជួររាជរដ្ឋាភិបាលមានឧបនាយករដ្ឋមន្ត្រីស្ត្រី១រូប (ក្នុងចំណោម៩រូប ដែលស្មើនឹង ១១.១១%) ក៏ប៉ុន្តែមិនមានស្ត្រីនៅក្នុងមុខតំណែងជាទេសរដ្ឋមន្ត្រីទេ។[106] ក្នុងឆ្នាំ២០១៣ ស្ត្រីមានមុខតំណែងជារដ្ឋមន្ត្រីមានចំនួន១០.៧១%(៣រូបក្នុងចំណោម២៨រូប) ដែលមានចំនួនកើនឡើងប្រៀបនឹងឆ្នាំ២០០៨ ដែលមានចំនួនតែ៧.៤០%(២រូប ក្នុងចំណោទ២៧រូប)។[107] ចំពោះសមាមាត្រស្ត្រីជារដ្ឋលេខាធិការក៏មានការកើនឡើងពី៨.០៨% (ស្ត្រី១៩រូបក្នុងចំណោម១៩៨រូប) ក្នុងឆ្នាំ២០០៨ ទៅ ២០.៥៤%ក្នុងឆ្នាំ២០១៣ (ស្ត្រី៣៨រូប ក្នុងចំណោម១៨៥រូប) ចំនួននេះមានការកើនឡើងដល់ ១២.៤៥%។ ចំពោះស្ត្រីដែលមានតំណែងជាអនុរដ្ឋលេខាធិការ ក៏មានការឡើងគួរឲ្យកត់សម្គាល់ដែល ពោលពី១៦% ក្នុងឆ្នាំ២០០៨(ស្ត្រី៣៣រូប ក្នុងចំណោម១០៥រូប) ទៅ១៧.៦០% (ស្ត្រី៩៨ក្នុង

[103] សេក្តីសង្ខេបគោលនយោបាយ៨, ៤។

[104] រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា, *បញ្ជីរាយនាមតំណាងរាស្ត្រនីតិកាលទី៥*, លេខ៥២២ រ.ស, សីហា ២០១៣។

[105] សេចក្តីសង្ខេបគោលនយោបាយ៨, ៥។

[106] ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា, លេខនស/រកត/០៩១៣/៩០៣, ២៤ កញ្ញា ២០១៣ (ពីពេលនេះទៅហៅថាព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលឆ្នាំ២០១៣)។

[107] ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលឆ្នាំ២០១៣។

ចំណោម២៧៣រូប)ឆ្នាំ២០១៣។[108] តាមរយៈតួរលេខបានបង្ហាញ ឲ្យឃើញថានៅក្នុងជួររាជរដ្ឋាភិបាលតួនាទីស្ត្រីបានកើនឡើងនៅគ្រប់តំណែង លើសលែងតែនៅក្នុងតំណែងជាទេសរដ្ឋមន្ត្រី។

### ២.៣.៣. ស្ថាប័នតុលាការ

តួនាទីស្ត្រីក្នុងស្ថាប័នតុលាការមានការកើនឡើងចាប់ពីឆ្នាំ២០០៨ ប៉ុន្តែតំណាងស្ត្រីនៅមានចំនួនតិចក្នុងគ្រប់កម្រិតនៃស្ថាប័នតុលាការ។ នៅក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ចំនួនស្ត្រីមានការកើនឡើន ប៉ុន្តែបុរសនៅមានចំនួនច្រើនជាងក្នុងតួនាទីធ្វើសេចក្តីសម្រេចក្នុងស្ថាប័ននេះ។នៅឆ្នាំ២០១៣ ក្នុងស្ថាប័នតុលាការ មានចៅក្រមជាស្ត្រីចំនួន១៣.៩% ហើយចំនួននេះមានការកើនឡើងនៅក្នុងឆ្នាំ២០១៥ ដល់១៤.៣%(ស្ត្រី៤០រូប ក្នុងចំណោម២៧៨រូប)។[109] ចំណែកស្ត្រីជាព្រះរាជអាជ្ញាមានចំនួន១០.២% ក្នុងឆ្នាំ២០១៣ ដែលមានកើនឡើងដល់១២.៥%នៅក្នុងឆ្នាំ២០១៥ (២៣រូប ក្នុងចំណោម១៨៤រូប)។[110] ចំនួនក្រឡាបញ្ជីជាស្ត្រី ក៏មានការកើនឡើងផងដែរដល់២៤.២៨%នៅក្នុងឆ្នាំ២០១៥(១៥៣រូប ក្នុងចំណោម៦៣០រូប)។[111] ប៉ុន្តែគួរឲ្យកត់សម្គាលថាមិនទាន់មានតំណាងស្ត្រីជាប្រធានស្ថាប័នតុលាការទេ។ ដូច្នេះបើតាមតួលេខទាំងនេះ បានបង្ហាញឲ្យឃើញថាកម្ពុជាកំពុងជិតសម្រេចបាននូវគោលដៅផែនការយុទ្ធសាស្ត្រនារីតនៈទី៣ ដែលបានកំណត់ថាកម្ពុជាត្រូវសម្រេចឲ្យបាននូវចៅក្រមជាស្ត្រីឲ្យបានចំនួន១៥%។

### ២.៣.៤. ស្ត្រីនៅក្នុងមុខងារសាធារណៈ

ចំនួនស្ត្រី និងតួនាទីក្នុងការធ្វើសេចក្តីនៅក្នុងវិស័យសាធារណៈ មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ នៅថ្នាក់រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ។ ស្ត្រីមានតួនាទីជាអភិបាលរងរាជធានី/ខេត្តចំនួន១៦.៦៦% នៅក្នុងឆ្នាំ២០១៥(២៥រូប ក្នុងចំណោម១៥០រូប) ដែលសម្រេចបានលើសពីគោលដៅទី៣ នៃគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជាកម្រិត១៥%។[112] ចំពោះអភិបាលក្រុង ស្រុក ខណ្ឌជាស្ត្រី នៅតែមានចំនួនបន្តិចបន្តួចនៅឡើយនៅក្នុងឆ្នាំ២០១៥ គឺ១.៥៣%(៣រូប ក្នុងចំណោម

[108] ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលឆ្នាំ២០១៣។

[109] ក្រសួងមុខងារសាធារណៈ, *តារាងស្ថិតិមន្ត្រីរាជការស៊ីវិល ដែលមានមុខតំណែងចាប់ពីថ្នាក់ការិយាល័យតាមក្រុង/ស្រុក/ខណ្ឌ រហូតដល់អគ្គនាយក និងថ្នាក់ស្មើឆ្នាំ២០១៥*, ២៧ មករា ២០១៦។

[110] ដូច១០៩។

[111] ដូច១០៩។

[112] ដូច១០៩។

១៩៥)បើប្រៀបធៀបទៅនឹងឆ្នាំ២០១៤ មាន១.០២%។[113] ចំណែកឯស្ត្រីជាអភិបាលរងក្រុង ស្រុក ខណ្ឌ មានចំនួនខ្ពស់គួរសម នោះគឺ២៥.២១%ក្នុងឆ្នាំ២០១៥ (១៧៩រូប ក្នុងចំណោម៧១០)។ទោះបីជាយ៉ាងណាក៏ដោយមិនមានតំណាងស្ត្រីជាអភិបាលរាជធានី ខេត្ត នៅឡើយទេ។ ស្ត្រីជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត មានការកើនឡើងពី១០% (ស្មើនឹង៣៩រូប ក្នុងចំណោមសរុប ៣៧៩រូប ក្នុងឆ្នាំ២០០៩) ដល់១៣.២៣%(ស្មើនឹង៥២រូបក្នុងចំណោមសរុប៣៩៣រូបក្នុងឆ្នាំ២០១៤)។ ចំណែកស្ត្រីជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានការកើនឡើងពី១២.៦៨% ដល់ ១៣.៨៥%ក្នុងឆ្នាំ២០១៤។[114]

*តារាងទី៣៖ តំណាងមន្ត្រីរាជការស៊ីវិលនៅកម្ពុជា ឆ្នាំ២០០៧, ២០១៣ និង២០១៥(ជាភាគរយ)*[115]

| ២០០៧ | | ២០១៣ | | ២០១៥ | |
|---|---|---|---|---|---|
| មន្ត្រីរាជការជាស្ត្រី | មន្ត្រីរាជការជាបុរស | មន្ត្រីរាជការជាស្ត្រី | មន្ត្រីរាជការជាបុរស | មន្ត្រីរាជការជាស្ត្រី | មន្ត្រីរាជការជាបុរស |
| ៣២% | ៦៨% | ៣៧% | ៦៣% | ៣៩% | ៦១% |

*(ប្រភព៖ ក្រសួងមុខងារសាធារណៈ តារាងស្ថិតិមន្ត្រីរាជការស៊ីវិលនៅតាមក្រសួង ស្ថាប័ននានាឆ្នាំ២០១៥)*

ចាប់តាំពីឆ្នាំ២០០៨មក ក្រសួងស្ថាប័ននានាបានរាយការណ៍ថាចំនួនស្ត្រីជាមន្ត្រីរាជការមានការកើនឡើងជាលំដាប់។ សមាត្រស្ត្រីជាមន្ត្រីរាជការបានកើនឡើងពី៣២%នៅក្នុងឆ្នាំ២០០៧ ទៅ ៣៧%ក្នុងឆ្នាំ២០១៣ និង៣៩%ក្នុងឆ្នាំ២០១៥។[116] នេះបង្ហាញការកើននូវឡើងជាបន្តបន្ទាប់នូវចំនួនមន្ត្រីរាជការជាស្ត្រីដោយសារការលើកកម្ពស់យេនឌ័រនៅក្នុងវិស័យរដ្ឋបាលសាធារណៈប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយគម្លាតយេនឌ័រនៅក្នុងវិស័យសាធារណៈនៅតែមានគម្លាតធំ។

[113] ដូច១០៩

[114] សេចក្តីសង្ខេបគោលនយោបាយ៨, ៩។

[115] ក្រសួងមុខងារសាធារណៈ:, *តារាងស្ថិតិមន្ត្រីរាជការស៊ីវិលនៅតាមក្រសួង ស្ថាប័ននានាឆ្នាំ២០១៥*, ២៧ មករា ២០១៦។

[116] ដូច១១៥។

*តារាង៤៖ តំណាងមន្ត្រីរាជការស៊ីវិលជាស្ត្រី និងបុរស ក្នុងតួនាទីដឹកនាំវិស័យសាធារណៈថ្នាក់ជាតិនិងថ្នាក់ស្មើ ឆ្នាំ ២០១៣ និង២០១៥(ជាភាគរយ)*[117]

| តួនាទី | ២០១៣ | | ២០១៥ | |
|---|---|---|---|---|
| | ស្ត្រី | បុរស | ស្ត្រី | បុរស |
| អគ្គនាយក | ១១% | ៨៩% | ១១% | ៨៩% |
| អគ្គនាយករង | ១២% | ៨៨% | ១៤% | ៨៦% |
| ប្រធាននាយកដ្ឋាន | ១០% | ៩០% | ១១% | ៨៩% |
| អនុប្រធាននាយកដ្ឋាន | ១៨% | ៨២% | ១៩% | ៨១% |
| ប្រធានការិយាល័យ | ២០% | ៨០% | ២១% | ៧៩% |
| អនុប្រធានការិយាល័យ | ២៧% | ៧៣% | ២៨% | ៧២% |

*(ប្រភព៖ ក្រសួងមុខងារសាធារណៈ តារាងស្ថិតិមន្ត្រីរាជការស៊ីវិល ដែលមានមុខតំណែងចាប់ពីថ្នាក់ការិយាល័យតាមក្រុង/ស្រុក/ខណ្ឌ រហូតដល់អគ្គនាយក និងថ្នាក់ស្មើឆ្នាំ២០១៥)*

*តារាង៥៖ តំណាងមន្ត្រីរាជការជាស្ត្រី និងបុរសក្នុងតួនាទីដឹកនាំវិស័យសាធារណៈថ្នាក់ក្រោមជាតិឆ្នាំ២០១៣ និង២០១៥(ជាភាគរយ)*[118]

| តួនាទី | ២០១៣ | | ២០១៥ | |
|---|---|---|---|---|
| | ស្ត្រី | បុរស | ស្ត្រី | បុរស |
| ប្រធានមន្ទីរ | ៨,៦៩% | ៩១,៣១% | ៨% | ៩២% |
| អនុប្រធានមន្ទីរ | ១៤.៥% | ៨៥,៥% | ១៦% | ៨៤% |
| ប្រធានការិយាល័យ តាមមន្ទីរ | ១៩% | ៨១% | ១៨% | ៨២% |
| ប្រធានការិយាល័យ ក្រុង ស្រុក ខណ្ឌ | ១៤,៥២% | ៨៥,៨៨% | ១៦% | ៨៥% |

*(ប្រភព៖ ក្រសួងមុខងារសាធារណៈ តារាងស្ថិតិមន្ត្រីរាជការស៊ីវិល ដែលមានមុខតំណែងចាប់ពីថ្នាក់ការិយាល័យតាមក្រុង/ស្រុក/ខណ្ឌ រហូតដល់អគ្គនាយក និងថ្នាក់ស្មើឆ្នាំ២០១៥)*

ស្ត្រីភាគច្រើនមានមុខតំណែងទាបនៅក្នុងវិស័យសាធារណៈ។ ចំណែកឯក្នុងមុខងារគ្រប់គ្រង ស្ត្រីមានតួនាទីជាប្រធានអនុប្រធានស្ថាប័នមានច្រើនជាងស្ត្រីដែលមានតួនាទីជា ប្រធានស្ថាប័ន។ នៅក្នុងឆ្នាំ២០១៥ មានស្ត្រីជាអគ្គនាយកចំនួន១១% អគ្គនាយករង១៤% ប្រធាននាយកដ្ឋាន១១% អនុប្រធាននាយកដ្ឋាន១៩% ប្រធានការិយាល័យ២១% អនុប្រធានការិយាល័យ២៨% នៅក្នុងថ្នាក់

[117] ដូច ១០៩។

[118] ដូច១០៩។

ជាតិ និងថ្នាក់ស្មើ។ ចំនួននេះមានការកើនឡើងជាបន្តបន្ទាប់ ប៉ុន្តែនៅថ្នាក់ក្រោមជាតិវិញភាគរយនៃស្រ្តីបានធ្លាក់ចុះបន្តិចបន្តួចនៅក្នុងតួនាទីជាប្រធានមន្ទីរ និងប្រធានការិយាល័យតាមមន្ទីរ។

# ជំពូកទី៣
# បញ្ហាប្រឈមរបស់ស្ត្រីកម្ពុជាក្នុងវិស័យសេដ្ឋកិច្ច និងដំណោះស្រាយ

ទាំងសំណាក់រាជរដ្ឋាភិបាល និងសង្គមស៊ីវិលបានចូលរួមសហការគ្នា ក្នុងការចូលរួមលើកកម្ពស់ស្ថានភាពស្ត្រីកម្ពុជាក្នុងវិស័យសេដ្ឋកិច្ច។ ទោះបីជាយ៉ាងណាក៏ដោយស្ត្រីកម្ពុជានៅតែជួបបញ្ហាប្រឈមមួយចំនួននៅក្នុងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច ដែលធ្វើឲ្យមានវិសមភាពយេនឌ័រនៅក្នុងវិស័យនេះ។ ដូច្នេះនៅក្នុងជំពូកនេះនឹងពិនិត្យលម្អិតទៅលើ (១.១) បញ្ហាប្រឈមរបស់ស្ត្រីកម្ពុជាក្នុងវិស័យសេដ្ឋកិច្ច និង(២.២) ដំណោះស្រាយរបស់រាជរដ្ឋាភិបាល និងសង្គមស៊ីវិល ក្នុងការចូលរួមកាត់បន្ថយបញ្ហាប្រឈមរបស់ស្ត្រី។

## ៣.១. បញ្ហាប្រឈមរបស់ស្ត្រីកម្ពុជាក្នុងវិស័យសេដ្ឋកិច្ច

### ៣.១.១. កម្រិតអក្ខរកម្ម និងចំណេះដឹងទាប

ទោះបីជាមាននូវការអភិវឌ្ឍន៍សេដ្ឋកិច្ច កម្រិតអក្ខរកម្ម និងចំណេះដឹងទាប ជាមួយនឹងគម្លាតយេនឌ័រ គឺជាបញ្ហារារាំងក្នុងការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីកម្ពុជា។[119] កម្រិតអក្ខរកម្ម និងការអប់រំទាប ជាឧបសគ្គរបស់ស្ត្រីក្នុងការចូលរួមធ្វើការងារដែលប្រាក់កម្រៃ និងកាលានុវត្តភាពសេដ្ឋកិច្ចជាទូទៅ។ បញ្ហានេះក៏ជាកត្តា ដែលចូលរួមកាត់បន្ថយនូវអត្ថប្រយោជន៍ដែលស្ត្រីកម្ពុជាទទួលបានពីតម្លៃតមស្មងកម្លាំងពលកម្ម នៅក្នុងលក្ខ័ខណ្ឌប្រាក់ឈ្នួលពលកម្ម និងប្រាក់ចំណូលដែលរកបានពីការប្រកបអាជីវកម្ម។

*តារាងទី៦៖ អាត្រាអក្ខរកម្មរបស់បុរស និងស្ត្រីក្នុងឆ្នាំ២០១៣ និង២០១៤(គិតជា%)*[120]

| ស្ត្រី | | បុរស | |
|---|---|---|---|
| ២០១៣ | ២០១៤ | ២០១៣ | ២០១៤ |
| ៧៤.៥% | ៧១.៨% | ៨៧.៧% | ៨៤.៨% |

*(ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ អង្កេតសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ២០១៤)*

[119] ដូច៧៩, ២០។

[120] ដូច៨០, ៨៨។

អាត្រាអក្ខរកម្មស្ត្រីកម្ពុជា(អាយុ១៥ឆ្នាំឡើង)មានការកើនឡើងក្នុងឆ្នាំ២០១៣គឺ៧៤.៣% ប៉ុន្តែមានការធ្លាក់ចុះក្នុងឆ្នាំ២០១៤ មកត្រឹម៧១.៨% ខណៈអាត្រាអក្ខរកម្មបុរសមានដល់៨៤.៥%។[121] គម្លាតយេនឌ័រនៅក្នុងអាត្រាអក្ខរកម្មបានធ្លាក់ចុះបន្តិចពី១៣.៣% ក្នុងឆ្នាំ២០១៣ មក១៣% ក្នុងឆ្នាំ២០១៤ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយគម្លាតយេនឌ័រនៅតែមានកម្រិតខ្ពស់គួរសមពិសេសនៅទីជនបទដែលមានដល់១៥% បើធៀបនៅទីជនបទតែ១០.៧% នៅក្នុងឆ្នាំ២០១៤។[122] គម្លាតយេនឌ័របានបង្ហាញពីភាពលំបាកកាន់តែខ្លាំងសម្រាប់ស្ត្រីនៅទីជនបទ ក្នុងការទទួលបាននូវកាលានុវត្តភាពសេដ្ឋកិច្ច ប្រៀបធៀបជាមួយបុរស។

ចំពោះអាត្រាចូលរៀនរបស់ក្មេងស្ត្រីនៅកម្រិតអនុវិទ្យាល័យ និងវិទ្យាល័យ ក៏នៅមានកម្រិតទាបជាពិសេសសម្រាប់នៅទីជនបទ។ លើសពីនេះផងដែរអត្រាក្មេងស្ត្រីដែលបោះបង់ចោលការសិក្សាក៏មានកម្រិតខ្ពស់ជាងបុរស។[123] បញ្ហានេះហើយដែលជាឧបសគ្គសម្រាប់ស្ត្រីកម្ពុជាក្នុងការទទួលបាននូវអត្ថប្រយោជន៍ពីការអភិវឌ្ឍន៍សេដ្ឋកិច្ច និងកាលានុវត្តភាពសេដ្ឋកិច្ច។

### ៣.១.២. បញ្ហានៅក្នុងការអភិវឌ្ឍន៍អាជីវកម្ម

ខណៈពេលដែល៦៥%នៃអាជីវកម្មសរុបក្នុងកម្ពុជាគ្រប់គ្រងដោយស្ត្រី ប៉ុន្តែអាជីវកម្មទាំងនោះជាមធ្យមមានលក្ខណៈតូចជាង និងអាចរកប្រាក់ចំណេញបានតិចជាងរបស់បុរស។ អាជីវកម្មរបស់ស្ត្រីមួយផ្នែកធំផ្តោតទៅលើការលក់ដុំ លក់រាយ និងសេវាមួយចំនួន។ បើធៀបនឹងអាជីវកម្មរបស់បុរស អាចស្វែងរកប្រាក់ចំណេញបានច្រើនជាង និងមានលក្ខណៈផ្លូវការជាងរបស់ស្ត្រី។

*តារាងទី៧៖ ចំនួនអាជីវកម្មសរុប និងចំនួនអាជីវកម្មដែលបានចុះបញ្ជីរបស់ស្ត្រី និងបុរសឆ្នាំ២០១១(គិតជាភាគរយ)*[124]

| | ស្ត្រី | បុរស |
|---|---|---|
| **ចំនួនអាជីវកម្មសរុប** | ៦៥.១% | ៣៤.៩% |
| **ចំនួនអាជីវកម្មដែលបានចុះបញ្ជី** | ១.៧% | ៦.៦% |

*(ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ជំរឿនសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១១)*

121 ដូច១២០។

122 ដូច១២០។

123 ដូច៧៩, ២០។

124 ដូច៨៩។

ម៉្យាងវិញទៀតអាជីវកម្មរបស់ស្ត្រីបានធ្វើការចុះបញ្ជីតិចជាងរបស់បុរស។ ក្នុងចំណោមអាជីវកម្មសរុបរបស់ស្ត្រីមានតែ១.៧%ប៉ុណ្ណោះដែលបានធ្វើការចុះបញ្ជី នៅពេលដែលអាជីវកម្មរបស់បុរសមាន៦.៦%។[125] នេះបង្ហាញថាអាជីវកម្មរបស់ស្ត្រីភាគច្រើនជាអាជីវកម្មខ្នាតមីក្រូ និងតូច មានលក្ខណៈមិនផ្លូវការ ជាពិសេសស្ត្រីជាម្ចាស់អាជីវកម្មមានកង្វះខាតនូវចំណេះដឹងផ្នែកខាងច្បាប់ទាក់ទងនឹងវិស័យធុរកិច្ច។

ក្នុងនាមជាអ្នកគ្រប់គ្រងអាជីវកម្ម ស្ត្រីជួបប្រទះនូវបញ្ហាឧបសគ្គជាច្រើន ដូចជា បញ្ហាកម្រិតអក្ខរកម្មទាប និងខ្វះខាតការបណ្តុះបណ្តាល ជាពិសេសពាក់ពន្ធ័នឹងប្រពន្ធ័បច្ចេកវិទ្យា។ អ្វីដែលជាបញ្ហាទៀតនោះនៅក្នុងអាជីវកម្ម គឺភាគច្រើនកើតទៅលើស្ត្រីដែលជាអាជីវករតាមផ្សារ ដែលជួបប្រទះនូវការគំរាមគំហែងទារប្រាក់ពីអ្នកគ្រប់គ្រងផ្សារ និងមន្ត្រីសន្តិសុខ។ តាមការស្រាវជ្រាវបង្ហាញឲ្យឃើញថាអាជីវកម្មគ្រប់គ្រងដោយស្ត្រី រងការគំរាមគំហែងពីការទារនូវថ្លៃសេវាក្រៅការ និងការសូកប៉ាន់ដោយមន្ត្រីរដ្ឋាភិបាល ហើយស្ត្រីមានសមត្ថភាពតិចតួចជាងបុរស ក្នុងការចរចារទៅលើការបង់ថ្លៃសេវាទាំងនោះ។ [126] ស្ត្រីក៏ត្រូវបានរាយការណ៍ផងដែរថាបានជួបនូវការលំបាកក្នុងការដោះស្រាយវិវាទទាំងក្រៅផ្លូវការ និងក្នុងប្រពន្ធ័តុលាការ បើធៀបនឹងបុរស។[127] តាមការស្រាវជ្រាវរបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងឆ្នាំ២០១៤ ក៏បានកំនត់ផងដែរនូវឧបសគ្គ ដែលមាននៅក្នុងការគ្រប់គ្រងអាជីវកម្មរបស់ស្ត្រីដែលក្នុងនោះរួមបញ្ចូលៈ (ក) បញ្ហាការខ្វះខាតហេដ្ឋរចនាសម្ពន្ធ័ (ដូចជាផ្លូវ និងអគ្គីសនី) (ខ) វប្បធម៌រើសអើងដែលនាំឲ្យមានការមិនឲ្យតម្លៃស្ត្រីជាអ្នកជំនួញ (គ) ការខ្វះខាតនូវផ្នែកហិរញ្ញវត្ថុ(ជាពិសេសហិរញ្ញវត្ថុសម្រាប់រយៈពេលយូរ) ដែលជាលទ្ធផលនាំឲ្យមានកម្រិតនៃទ្រព្យបញ្ចាំ និងការទទួលបានការអប់រំជាផ្លូវការ។[128]

### ៣.១.៣. បញ្ហាកសិកម្ម និងជីវភាពរស់នៅជនបទ

ការអភិវឌ្ឍន៍វិស័យកសិកម្ម និងជីវភាពរស់នៅតាមជនបទរបស់ស្ត្រីត្រូវ ត្រូវជួបឧបសគ្គដោយសារកង្វះខាតលទ្ធភាព និងកម្មសិទ្ធិលើធនធាន និងឥទ្ធិពលនៃបម្រែបម្រួលអាកាសធាតុពិភពលោក (ទឹកជំនន់ គ្រោះរាំងស្ងួត និងការកើនឡើងនៃសីតុណ្ហភាព)។ លើសពីនេះស្ត្រីត្រូវធ្វើ

[125] ដូច៨៩។

[126] ដូច៧៩, ២៥។

[127] ដូច១២៦។

[128] ដូច១២៦។

ការងារមិនមានប្រាក់កម្រៃដូចជា ការងារថែរក្សា និងការងារផ្ទះសម្បែង ធ្វើឲ្យពួកគាត់មានពេលវេលាតិចតួចសម្រាប់ការងាររកប្រាក់ចំណូល។

កសិកម្មគឺនៅតែជាវិស័យមានការងារលេចធ្លោសម្រាប់ស្ត្រី ជាពិសេសស្ត្រីនៅទីជនបទក៏ប៉ុន្តែពួកគេទទួលបាននូវធនធានចាំបាច់សម្រាប់ផលិតផលកសិកម្ម នៅមានកម្រិតនៅឡើយ។ នៅក្នុងឆ្នាំ២០០៨ ស្ត្រីជាមេគ្រួសារចំនួន២០% នៃគ្រួសារកសិករសរុបមានដីកសិកម្មចំនួន១.១ហិកតា តិចជាងបុរសជាមេគ្រួសារ ដែលមានដីកសិកម្មចំនួន១.៥ហិកតា។[129] លើសពីនេះទៅទៀតស្ត្រីដែលរៀបការរួមប្រហែលជាមិនអាចគ្រប់គ្រងដីដែលបានចុះបញ្ជីរួមគ្នាជាមួយនឹងស្វាមីបាន ដោយសារតែស្ត្រីមិនចូលរួមជាមួយបុរសនៅក្នុងដំណើរការចុះបញ្ជីដីធ្លី ហើយអាចនឹងបាត់បង់កម្មសិទ្ធិកាន់កាប់ដីធ្លីផងដែរ នៅក្នុងករណីលែងលះគ្នា រស់នៅបែកគ្នា និងស្វាមីបោះបង់ចោល។[130] ការកើនឡើងនៃការគ្មានដី ជាមូលហេតុចម្បងនៃការងាយរងគ្រោះហើយ ស្ត្រីទទួលបានធនធានសំខាន់ៗតិចតួចសម្រាប់លើកម្ពស់ផលិតភាពកសិកម្ម។[131]

> អ្នកស្រីគង់ សាឡុន ដែលជាប្រធានមន្ទីរកិច្ចការនារីខេត្តព្រៃវែងបានមានប្រសាសន៍នៅក្នុងកិច្ចសម្ភាសថា៖ «ស្ត្រីតាមមូលដ្ឋានមានលទ្ធភាពក្នុងផលិតនូវផលិតកម្មកសិកម្ម និងផលិតផលផ្សេងទៀត ប៉ុន្តែជួបប្រទះនឹងបញ្ហាការស្វែងរកទីផ្សារ និងការទំលាក់តម្លៃរបស់ឈ្មួលកណ្តាល។ ចំណែកឯបញ្ហាជីវភាពរស់នៅទីជនបទបច្ចុប្បន្ន ស្ត្រីមានបន្ទុកការងារកាន់តែច្រើននៅក្នុងគ្រួសារ ដោយសារតែយុវជននៅក្នុងគ្រួសារភាគច្រើនធ្វើការចំណាកស្រុកស្វែងការងារធ្វើនៅក្នុងទីក្រុង ដូច្នេះមិនមានអ្នកក្នុងការជួយស្ត្រីក្នុងការងារ។» [132]

ស្ត្រីមានឧបសគ្គច្រើនជាងបុរស នៅក្នុងការរកទីផ្សារទំនិញផលិតផលកសិកម្ម។ បញ្ហានេះដោយសារតែការខ្វះខាតនូវពេលវេលាដោយសារតែការទទួលខុសត្រូវថែទាំគ្រួសារ ការព្រួយបារម្ភផ្នែកសុវត្ថិភាព និងសន្តិសុខនៅពេលធ្វើដំណើរទៅកន្លែងសាធារណៈ។ ម្យ៉ាងវិញទៀតការអប់រំផ្នែកហិរញ្ញវត្ថុរបស់ស្ត្រីនៅមានកម្រិតទាប ការបង់ថ្លៃសេវាក្រៅផ្លូវការ ក៏ដូចជាការលំបាកក្នុងការទទួល និងផ្តល់ពត៌មាន និងការទំនាក់ទំនងជាមួយអ្នកលក់ជាដើម។

---

129 វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ និងអង្គការកសិកម្ម និងម្ហូបអាហារ(FAO), *National Gender profile of agricultural households*[ប្រវត្តិយេនឌ័រជាតិស្តីពីគ្រួសារកសិកម្ម], Report bases on the 2008 CSES,(ភ្នំពេញ៖ វិទ្យាស្ថានជាតិស្ថិតិ, ២០១០)។

130 ដូច១២៩។

131 ដូច១២៩។

132 អ្នកស្រី គង់ សាឡុន(ប្រធានមន្ទីរកិច្ចការនារីខេត្តព្រៃវែង), បទសម្ភាសផ្ទាល់ខ្លួន, ០២ ឧសភា ២០១៦។

បម្រែបម្រួលអាកាសធាតុពិភពលោក ដូចជាគ្រោះទឹកជំនន់ក្នុងឆ្នាំ២០១១ និងឆ្នាំ២០១៣បានផ្តល់ផលអវិជ្ជមានយ៉ាងខ្លាំងទៅលើផលិតផលកសិកម្ម ការងារក្នុងវិស័យកសិកម្ម និងជីវភាពគ្រួសារនៅជនបទ។[133] គ្រួសារកសិករដែលពឹងផ្អែកលើទឹកភ្លៀង ងាយរងគ្រោះនឹងការផ្លាស់ប្តូរអាកាសធាតុ ដែលបណ្តាលឲ្យជីវភាពប្រជាជននៅជនបទមានការខ្វះខាត។ចំណុចនេះអាចបណ្តាលឲ្យមានកំណើននៃការធ្វើទេសន្តប្រទេសន៍ កំណើនប្រាក់កម្ចីសម្រាប់តម្រូវការចាំបាច់ អាត្រាពលកម្មកុមារកើនឡើង ព្រមទាំងការបង្កើនបន្ទុកការងារគ្មានប្រាក់កម្រៃដល់ស្ត្រីថែមទៀត។ មេគ្រួសារជាស្ត្រីអាចនឹងទទួលផលប៉ះពាល់ពីគ្រោះធម្មជាតិខ្លាំង ដោយសារពុំសូវទទួលបាននូវពត៌មានអំពីគ្រោះធម្មជាតិ និងការទទួលយោបល់ប្រឹក្សាតិចតួចពីសហគមន៍ និងលទ្ធភាពមានកម្រិតក្នុងការទទួលឥទាន និងការធ្វើបម្លាស់ទី។

ការងារថែទាំ និងការផ្ទះសម្បែងដែលគ្មានប្រាក់កម្រៃរបស់ស្ត្រី និងការអប់រំទាប គឺជាបញ្ហាដល់ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។ ស្ត្រី និងក្មេងស្ត្រីបានចូលរួមមួយភាគធំក្នុងការងារថែទាំ និងការងារផ្ទះសម្បែងដែលគ្មានប្រាក់កម្រៃនៅក្នុងគ្រួសារ និងសហគមន៍។ នេះគឺជាបញ្ហាប្រឈមសម្រាប់ពួកគេក្នុងការចូលរួមការងារមានប្រាក់កម្រៃក៏ដូចជាការអប់រំ និងការបណ្តុះបណ្តាលផ្សេងៗ។ មានការប៉ាន់ប្រមាណថាស្ត្រីចំណាយពេល៣ម៉ោង និង៣០នាទីជារៀងរាល់ថ្ងៃសម្រាប់ការងារគ្មានប្រាក់ចំណូល និងការងារថែទាំ។[134] ការងារឆ្លុះបញ្ចាំពីអតុល្យភាព និងវិសមភាពលើការបែងចែកការងារ និងការធ្វើឲ្យបន្ទុកការងាររបស់ស្ត្រី មានកម្រិតខ្ពស់បុរស។

ទោះបីជាអាត្រានៃភាពក្រីក្រផ្អែកលើប្រាក់ចំណូលមានការថយចុះ ក៏ប៉ុន្តែភាពក្រីក្ររបស់ប្រជាជន ជាពិសេសនៅទីជនបទនៅតែមានកម្រិតខ្ពស់ ហើយចំនួននៃជនរងគ្រោះកំពុងកើនឡើង។ ការធ្លាក់ចុះនៃអាត្រានៃភាពក្រីក្រ(ផ្អែកលើបន្ទាត់ក្រីក្រថ្នាក់ជាតិ) ពី២៩.៩% នៅក្នុងឆ្នាំ២០១២ មកត្រឹម១៩.៨%នៅក្នុងឆ្នាំ២០១១។[135] ចំនួនភាគរយនៃគ្រួសារជាច្រើនបានរំកិលចេញពីបន្ទាត់នៃភាពក្រីក្រ ប៉ុន្តែមិនទាន់ឃ្លាតឆ្ងាយពីភាពក្រីក្រនៅឡើយ មានន័យថាជាគ្រួសារងាយរងគ្រោះក្នុងវិបត្តិផ្សេងៗ។ អាត្រាភាពក្រីក្រលើប្រាក់ចំណូលមានការធ្លាក់ចុះ មិនធានាថាសុខមាលភាពរបស់ស្ត្រី និងក្មេងស្រីបានប្រសើរនោះទេ ប្រសិនបើធនធានទាំងនោះមិនបានបែងចែកឲ្យស្មើ

[133] ក្រសួងកិច្ចការនារី, សេចក្តីសង្ខេបគោលនយោបាយ៣, *សេដ្ឋកិច្ច៖ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី*, ២០១៤, ១២ (ពីពេលនេះទៅហៅថាសេចក្តីសង្ខេបគោលនយោបាយ៣)។

[134] សេចក្តីសង្ខេបគោលនយោបាយ៣, ១២។

[135] សេចក្តីសង្ខេបគោលនយោបាយ៣, ១៣។

គ្នានៅក្នុងគ្រួសារ។ ការកង្វះអាហាររូបត្ថម្ភ និងភាពស្លេកស្លាំងក្នុងចំណោមស្ត្រី រួមទាំងអំពើហិង្សាក្នុងគ្រួសារ ក៏បានបង្ហាញពីភាពរងគ្រោះរបស់ស្ត្រី និងភាពលំបាកក្នុងការទទួលបានធនធាន។

### ៣.១.៤. ស្ត្រីនៅក្នុងការងារមានប្រាក់កម្រៃ

ចំនួនការងារមានប្រាក់កម្រៃបានកើនឡើង ហើយផ្តល់ឱកាសច្រើនសម្រាប់ស្ត្រី ប៉ុន្តែការងារមានប្រាក់កម្រៃទាំងនោះភាគច្រើនជាការងាមានកម្រិតទាប លក្ខខណ្ឌការងារមិនល្អប្រសើរ ជាការងារងាយរងគ្រោះ និងនៅមានគម្លាតយេនឌ័រខ្ពស់ បើប្រៀបធៀបនឹងបុរស។ សម្រាប់ស្ត្រីកម្ពុជា វិស័យកាត់ដេរ គឺជាប្រភពការងារមានប្រាក់កម្រៃធំជាងនៅក្នុងវិស័យឧស្សាហកម្ម បើធៀបនឹងវិស័យផ្សេងទៀត។ ការងារមានប្រាក់កម្រៃសរុបសម្រាប់ស្ត្រី៤៥% គឺនៅក្នុងវិស័យកាត់ដេរ ជាពិសេសវិស័យកាត់ដេរសំលៀកបំពាក់ និងស្បែកជើង ដែលមានកម្មការនារីប្រហែល៣២៧,០០០នាក់នៅក្នុងឆ្នាំ២០១៣។[136] ផ្ទុយទៅវិញសម្រាប់បុរស ការងារដែលប្រាក់កម្រៃភាគច្រើនប្រមូលផ្តុំទៅលើវិស័យរដ្ឋបាលសាធារណៈ និងវិស័យការពារ (មាន២១%នៃការងារមានប្រាក់មានកម្រៃសរុបសម្រាប់បុរស ដែលប្រហែលជា២១៤,៩១៤នាក់)។[137]

ការងារនៅក្នុងវិស័យកាត់ដេរ មានកម្មការនារីប្រហែល៩០% ហើយកម្មការនារីទាំងនោះសុទ្ធសឹងជាស្ត្រីវ័យក្មេង ដែលធ្វើការចំណាកស្រុកពីទីជនបទ និងមានចំណេះដឹងទាប។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ លក្ខខណ្ឌការងារនៅក្នុងវិស័យកាត់ដេរមានភាពល្អប្រសើរជាងមុន ប៉ុន្តែបញ្ហាការអនុវត្តច្បាប់កាងារនៅតែមាន។ បុគ្គលិកជាស្ត្រីត្រូវបានគេរាយការណ៍ថា មានរងការបៀតបៀនផ្លូវភេទ និងរូបរាងកាយ ជាពិសេសការកម្រិតនូវយន្តការក្នុងការដោះស្រាយបញ្ហា។[138] លើសពីនេះទៅទៀតក៏មានបញ្ហា ការធ្វើការងារលើសម៉ោង សុវត្ថិភាព និងបញ្ហាសុខភាព។ តាមការស្រាវជ្រាវបានបង្ហាញឲ្យឃើញថា មានតែរោងចក្រមួយភាគបួនទេ ដែលកម្រិតការថែមម៉ោងធ្វើការតាមផ្លូវច្បាប់(២ម៉ោងក្នុង១ថ្ងៃ)។[139] ម៉្យាងវិញទៀតការងារនៅក្នុងរោងចក្រកាត់ដេរ មានការប្រឈមទៅនឹងគ្រោះថ្នាក់ ដោយសារការខ្វះខាតនូវបច្ចេកទេសក្នុងការសាងសង់។ ជាពិសេសការប្រឈមមុខនឹងបញ្ហាសុខភាព ដែលកើតឡើងពីសារធាតុគីមីក្នុងក្រណាត់ និងការខ្វះខាតខ្យល់ចេញចូលក្នុងអាគារដែលនាំឲ្យកម្មការនារីជាច្រើនដួលសន្លប់ ក្នុងពេលកំពុងធ្វើការ និងកើតជំងឺវិជ្ជាជីវៈ។

[136] ដូច៧៩, ២៤។

[137] ដូច១៣៦។

[138] ដូច៧៩, ២៥។

[139] ដូច១៣៨។

### ៣.១.៥. បញ្ហាស្ត្រីពលករទេសន្តប្រវេសន៍ក្នុង និងក្រៅប្រទេស

ចំនួនស្ត្រីកម្ពុជាមានការកើនឡើងក្នុងការធ្វើទេសន្តប្រវេសន៍ក្នុង និងក្រៅប្រទេស។នៅក្នុងឆ្នាំ ២០១៣ ប្រជាជនកម្ពុជាចំនួន២៩% (ប្រហែល៤.២លាននាក់) ប្រៀបធៀបនឹងឆ្នាំ២០០៨ចំនួន ២៧% បានចំណាកស្រុក ដែលក្នុងនោះមានប្រហែល៥០%ជាស្ត្រី។[140] ក្នុងចំណោមស្ត្រីពលករទេសន្តប្រវេសន៍មាន៧៤% ដែលធ្វើការចំណាកស្រុកពីជនបទមកទីក្រុង និង៣៦%ចំណាកស្រុកទៅក្រៅប្រទេស។[141] ប្រទេសគោលដៅនៃការធ្វើចំណាកស្រុកគឺប្រទេសម៉ាឡេស៊ី ថៃនិងកូរ៉េខាងត្បូង។

ការចំណាកស្រុករបស់ស្ត្រីពីជនបទមកទីក្រុង(ជាពិសេសភ្នំពេញ) ភាគច្រើនគឺធ្វើការងារនៅក្នុងរោងចក្រ សហគ្រាស ការងារបំរើតាមផ្ទះ និងភោជនីយដ្ឋាន។ ចំពោះការងារដែលទទួលបានពីការចំណាកស្រុកទៅក្រៅប្រទេស គឺការងារក្នុងវិស័យកសិកម្ម និងសំណង់ចំពោះបុរស និងស្ត្រីប៉ុន្តែភាគច្រើនការងារសម្រាប់ស្ត្រី គឺការងារនៅក្នុងផ្ទះ និងរោងចក្រ ខណៈបុរសភាគច្រើនធ្វើកាងារនេសាទ។[142] បើប្រៀបធៀបជាមួយការងារចំណាកស្រុកក្នុងប្រទេស ស្ត្រីពលករទេសន្តប្រទេសន៍ជួបហានិភ័យតិចជាងការចំណាកស្រុកទៅក្រៅប្រទេស។

> មារីគេន ប៊ី.ហាប៊ីត ដែលមន្ត្រីផ្នែកទំនាក់ទនងរបស់UN Womenប្រចាំកម្ពុជាបានកត់សម្គាល់ថា៖ «ដោយសារតែភាពក្រីក្រ ស្ត្រីកម្ពុជាជាច្រើនព្យាយាមស្វែងរកនូវឱកាសការងារ តាមរយៈការធ្វើចំណាកស្រុក ទៅកាន់ទីក្រុង និងប្រទេសក្រៅ។ ប៉ុន្តែស្ត្រីបានជួបប្រទះនឹងបញ្ហាការកេងប្រវញ្ចក៏កម្លាំងពលកម្ម និងអំពើហិង្សាជាដើម។»[143]

ការចំណាកស្រុករបស់ស្ត្រីកម្ពុជាអាចឲ្យគាត់ស្វែងរកនូវប្រាក់ចំណូលច្រើនជាង ប៉ុន្តែស្ត្រីជានិច្ចជាកាលអាចជួបប្រទះនូវហានិភ័យច្រើនជាងបុរស។ នៅក្នុងករណីខ្លះជាពិសេស ការជ្រើសរើសពលករឲ្យទៅបំរើការងារនៅប្រទេសម៉ាឡេស៊ី និងប្រទេសផ្សេងៗគឺជាបញ្ហាមួយដោយសារតែការក្លែងបន្លំឯកសារ និងអត្តសញ្ញាណរបស់ក្មេងស្រីមិនគ្រប់អាយុ និងពេលក្រោយ

[140] វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ, *Migration in Cambodia: Report of Cambodia Rural Urban migration Project (CRUM)*[ទេសន្តប្រវេសន៍នៅកម្ពុជា៖ របាយការណ៍ស្តីពីគម្រោងទេសន្តប្រទេសន៍ទីក្រុង ជនបទកម្ពុជា], (ភ្នំពេញ៖ វិទ្យាស្ថានជាតិស្ថិតិ,២០១២)។

[141] ដូច១៤០។

[142] ដូច៧៩, ៣០។

[143] ម៉ារីគេន ប៊ី.ហាប៊ីត, (មន្ត្រីផ្នែកទំនាក់ទំនងរបស់អង្គការសហប្រជាជាតិគាំទ្រសមភាពយេនឌ័រ និងការផ្ដល់ភាពអង់អាចដល់ស្ត្រី ប្រចាំកម្ពុជា), កិច្ចសម្ភាសផ្ទាល់ខ្លួន, ០២ មេសា ២០១៦។

អាចត្រូវបានឃាត់ខ្លួនដោយប៉ូលីសអន្តោប្រវេសន៍របស់ប្រទេសនោះ។ នៅក្នុងប្រទេសម៉ាឡេស៊ីត្រូវបានគេរាយការណ៍ថា មានការប្រើប្រាស់អំពើហិង្សាលើរូបរាងកាយ និងការកេងប្រវ័ញ្ចលើសេដ្ឋកិច្ច ការមិនបើកប្រាក់ឈ្នួល ឬបើកមិនគ្រប់ និងការប្រមូលលិខិតឆ្លងដែនរបស់ថៅកែពីពលករជាគំរាម ដែលនាំឲ្យពលករធ្វើក្នុងផ្ទះមិនមានសេរីភាពក្នុងការឈប់ធ្វើការ និងផ្លាស់ប្តូរការងារ។ [144] ចំណែកឯនៅក្នុងប្រទេសថៃវិញ ពលករខ្មែរភាគច្រើនធ្វើការនៅក្នុងកសិដ្ឋានរោងចក្រ និងការងារក្នុងផ្ទះ។ ស្ត្រីដែលធ្វើការងារនៅក្នុងកសិដ្ឋាន និងការដាំដុះ ជួបប្រទះនឹងបញ្ហាការស្រូបយកនូវសាធាតុគីមី ដែលប៉ះពាល់ដល់សុខភាពរយៈពេលយូរ។[145] សរុបមកការធ្វើចំណាកស្រុករបស់ស្ត្រីកម្ពុជាទៅកាន់ប្រទេសក្រៅ អាចរងនូវហានិភ័យដូចជា ការកេងប្រវ័ញ្ចលើកំលាំងពលកម្ម ការរំលោភនូវសិទ្ធិមនុស្ស ការបង្ខិតបង្ខំឲ្យធ្វើការងារ ការបៀតបៀនផ្លូវភេទ និងការជួញដូរមនុស្ស។ បញ្ហាទាំងអស់នេះភាគច្រើនកើតទៅលើពលករចំណាកស្រុកមិនស្របច្បាប់ និងជាពិសេសលើស្ត្រីភេទ ជាជាងបុរស។

### ៣.១.៦. បញ្ហាការអនុវត្តច្បាប់ គោលនយោបាយ ផែនការ និងកម្មវិធី

ស្របពេលវឌ្ឍនការនៃការបញ្ជ្រាបសមភាពយេនឌ័រទៅការអនុវត្តច្បាប់ គោលនយោបាយ ផែនការ និងកម្មវិធី មានដំណើរការល្អ ការអនុវត្តជាក់ស្តែងនូវគោលនយោបាយទាំងនោះនៅមានគម្លាតនៅឡើយ។ ជាការពិតមានគម្រោង និងកម្មវិធីជាច្រើន ដែលកំពុងបានយកចិត្តទុកដាក់ និងបញ្ជាក់អំពីការគាំទ្ររបស់ខ្លួន លើការលើកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី ប៉ុន្តែសកម្មភាព និងការងារទាំងនោះពុំទាន់បានប្រមូលផ្តុំជាលក្ខណៈអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីនៅឡើយ ជាពិសេសលទ្ធភាពរបស់រាជរដ្ឋាភិបាល និងដៃគូពាក់ពន្ធ័ក្នុងការសម្របសម្រួលនៅមានកម្រិត។ម៉្យាងវិញទៀត ការសម្របសម្រួលសកម្មភាពបញ្ជ្រាបយេនឌ័រនៅមិនទាន់មានប្រសិទ្ធិភាព ដោយសារតែទំនាក់ទំនងរវាងនាយកដ្ឋានជំនាញ របស់ក្រសួងកិច្ចការនារី ជាមួយក្រុមការងារបញ្ជ្រាបយេនឌ័រនៅតាមក្រសួងស្ថាប័ន និងជាមួយក្រុមការងារបច្ចេសទេសផ្សេងៗទៀតនៅមានកម្រិត។ជាពិសេសផ្នត់គំនិតរបស់ថ្នាក់ដឹកនាំក្រសួង បុគ្គល និងសង្គមមួយចំនួននៅតែបន្តយល់ថាការងារបញ្ជ្រាបយេនឌ័រ គឺជាការបន្ទុករបស់ក្រសួងកិច្ចការនារី ប៉ុន្តែវាគឺជាបន្ទុករបស់គ្រប់ក្រសួង និងស្ថាប័នពាក់ពន្ធ័។ [146]

---

[144] ដូច៧៩, ៣០។

[145] ដូច៧៩, ៣១។

[146] សេចក្តីសង្ខេបគោលយោបាយ១, ២២។

ចំនុចសំខាន់នោះគឺការខ្វះខាតនូវថវិការក្នុងការអនុវត្តផែនការ និងកម្មវិធី។ ប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ ដូច្នេះកញ្ចាប់ថវិការមានកម្រិតក្នុងការអនុវត្តផែនការ និងកម្មវិធីទាំងនោះ។នៅពេលការខ្វះអនុវត្តគម្រោង និងសកម្មភាពគឺពឹងផ្អែកទៅលើជំនួយរបស់ដៃគូអភិវឌ្ឍន៍និងអង្គការក្រៅរដ្ឋាភិបាលជាដើម។ ជារួមមកការខ្វះខាតនូវថវិការធ្វើឲ្យមានកម្រិតក្នុងការអនុវត្តនូវសកម្មភាពក្នុងការបញ្ជ្រាបយេនឌ័ររបស់ក្រសួងស្ថាប័ន ការអនុវត្តគម្រោង និងកម្មវិធី ក៏ដូចជាការបង្កើតនូវគម្រោង និងកម្មវិធីថ្មីៗ ក្នុងការលើកកម្ពស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច។

## ៣.២. ដំណោះស្រាយ

នៅក្នុងចំនុចនៃការដោះស្រាយបញ្ហាប្រឈមរបស់ស្ត្រីកម្ពុជានៅក្នុងវិស័យសេដ្ឋកិច្ច នឹងសិក្សាទាំងលើ (ក)ដំណោះស្រាយរបស់រាជរដ្ឋាភិបាល និង(ខ)ដំណោះស្រាយរបស់សង្គមស៊ីវិល។

### ៣.២.១. ដំណោះស្រាយរបស់រាជរដ្ឋាភិបាល

#### ៣.២.១.១. ការបង្កើត និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីស្តីពីការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

ក្រសួងកិច្ចការនារី សហការជាមួយស្ថាប័នពាក់ពន្ធ័ជំរុញការបង្កើតបន្ថែមទៀតនូវយុទ្ធសាស្ត្រស្តីពីការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ដោយស្របជាមួយនឹងក្របខណ្ឌពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ តាមរយះនេះក្រសួងកិច្ចការនារីធ្វើការសម្របសម្រួលរៀបចំផែនការយុទ្ធសាស្ត្រនៅតាមក្រសួងស្ថាប័នពាក់ពន្ធ័ ស្តីពីការបង្កើនភាពអង់អាចដល់ស្ត្រីផ្នែកសេដ្ឋកិច្ចដោយដាក់បញ្ចូលអនុសាសន៍នៃការប៉ាន់ប្រមាណស្ថានភាពយេនឌ័រនៅកម្ពុជាទៅក្នុងនោះ។[147] បន្ថែមពីនេះផងដែលក្រសួងកិច្ចការនារីក៏ព្យាយាមអភិវឌ្ឍន៍សមត្ថភាពរបស់ខ្លួន និងស្ថាប័នពាក់ពន្ធ័ ស្តីពីការវិភាគ និងបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធី និងគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច។ ជាពិសេសពង្រឹងភាពជាដៃគូ ក្នុងការរៀបចំគោលនយោបាយ និងកម្មវិធីនានាស្តីការអភិវឌ្ឍន៍សេដ្ឋកិច្ចជាមួយក្រសួងស្ថាប័ន និងដៃគូអភិវឌ្ឍន៍។

លើសពីនេះផងដែរ ដើម្បីធានានូវប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ ក្រសួងកិច្ចនារីការបានបង្កើតប្រពន្ធ័តាមដាន និងវាយតម្លៃ ការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។ ដោយផ្អែកលើផែនការសកម្មភាព និងរបាយការណ៍ប្រចាំឆ្នាំក្រសួងកិច្ចការនារី ក្នុងភាពជាដៃគូនឹងក្រសួង និងស្ថាប័ននានាដែលពាក់ពន្ធ័ នឹងធ្វើការត្រួតពិនិត្យ

[147] នារីរតនៈទី៤, ២៨។

ឡើងវិញនូវការរីកចម្រើននៃការអនុវត្តផែនការយុទ្ធសាស្ត្រ។ [148] ដើម្បីសម្រេចឲ្យបាននូវការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ក្រសួងកិច្ចការនារីមិនត្រឹមតែពិនិត្យទៅលើផែនការយុទ្ធសាស្ត្រស្តីពីការបង្កើតភាពអង់អាចដល់ស្ត្រី មួយមុខទេ តែថែមទាំងទៅលើការអនុវត្ត និងការត្រួតពិនិត្យក្របខណ្ឌពន្លឿនគោលដៅសហស្សវត្សរ៍ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពឆ្នាំ២០៣០ ដោយផ្តោតទៅលើគោលដៅទី៥ ស្តីពីការលើកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី និងក្មេងស្រី។

### ៣.២.១.២. ការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីកំណែទម្រង់សំខាន់ៗរបស់រដ្ឋាភិបាល

ក្រសួងកិច្ចការនារី បានធ្វើការងារបញ្ជ្រាបយេនឌ័រយ៉ាងសកម្មទៅក្នុងកម្មវិធីកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចជាកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ ជាដើម។[149]

#### ក. ផែនការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

នៅក្នុងឆ្នាំ២០១០ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យការអនុវត្តកំណែទម្រង់ការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ នៅក្នុងឆ្នាំ២០១០(គ.ជ.អ.ប) បានបង្កើតកម្មវិធីជាតិ១០ឆ្នាំសម្រាប់ការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឆ្នាំ២០១០-២០១៩។កម្មវិធីនេះផ្តល់ទិសដៅសម្រាប់ការអនុវត្តរបៀបវីរៈកំណែទម្រង់សម្រាប់រយៈពេល១០ឆ្នាំបន្ទាប់។ កម្មវិធីជាតិ១០ឆ្នាំបានរៀបចំចេញជាផែនការអនុវត្តបីឆ្នាំដំបូងដែលហៅកាត់ថា ផអ៣ ។ ផអ៣ មានអនុកម្មវិធីចំនួន៦ ដែលមានក្រសួង ស្ថាប័នពាក់ពន្ធ័ចំនួន៧អនុវត្តកម្មវិធីទាំងនេះ ក្នុងនោះក្រសួងកិច្ចការនារីដើរតួជាអ្នកសម្របសម្រួល និងបញ្ជ្រាបយេនឌ័រទៅក្នុង ផអ៣។[150]

យេនឌ័របានបញ្ជ្រាបទាំងនៅក្នុងកម្មវិធីជាតិ១០ឆ្នាំ និងផអ៣។កម្មវិធីជាតិ១០ឆ្នាំ និងផអ៣ បានផ្តោតការយកចិត្តទុកដាក់ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួម និងការទទួលបានសិទ្ធិស្មើគ្នាសម្រាប់ស្ត្រី និងបុរសដើម្បីទទួលបានតំណែងជាអ្នកដឹកនាំ និងការធ្វើសេចក្តីសម្រេចផ្នែកនយោបាយ ធនធាន និង

[148] នារីរតនៈទី៥, ៧៧។

[149] នារីរតនៈទី៥, ១៥។

[150] គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, *ផែនការអនុវត្តបីឆ្នាំដំបូង (២០១១-២០១៣) នៃផែនការជាតិសម្រាប់ការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ*, ២០១១។

សេវាកម្ម។[151] នៅខែកុម្ភៈឆ្នាំ២០១៤ គ.ជ.អ.ប. បានធ្វើសវនកម្មយេនឌ័រ ដែលបានត្រួតពិនិត្យឡើងវិញលើ ស្ថាប័នគោលនយោបាយសំខាន់ៗ និងសមិទ្ធិផលព្រមទាំងឧបសគ្គនានាក្នុងការបញ្ជ្រាបយេនឌ័រ។

**ខ. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងផែនការឆ្លើយតបនឹងយេនឌ័រ**

កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី២ បង្កើតឡើងនៅក្នុងឆ្នាំ២០០៨ ដោយមានចក្ខុវិស័យ រយៈពេលវែងដើម្បីបង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលមានលក្ខណៈបទដ្ឋានអន្តរជាតិ មួយនៅត្រឹមឆ្នាំ២០១៥។ យេនឌ័របានដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពរួមទី២៖«ការអភិវឌ្ឍន៍គោលនយោបាយ ស្តីពីសមាហរណកម្មថវិកាដើម្បីបន្តឲ្យប្រសើរឡើងនូវការធ្វើសមាហរណកម្មថវិការ ចរន្ត និងថវិកាមូលធន្តតាមរយៈការផ្តួមផ្តើមជាបន្តបន្ទាប់ ដូចជាក្របខណ្ឌចំណាយរយៈពេលមធ្យម ផែនការយុទ្ធសាស្ត្រថវិកា និងថវិកាតាមកម្មវិធី។គោលបំណងនេះក៏បានបញ្ចូលការកាត់បន្ថយភាពក្រីក្រ និងសេចក្តីថ្លែងការយេនឌ័រដែលទាក់ទងនឹងផែនការយុទ្ធសាស្ត្រថវិកា និងថវិកាតាមកម្មវិធី។» [152]

ក្រសួងកិច្ចការនារីបានបង្កើតឲ្យមានឧបករណ៍ និងវិធីសាស្ត្រនៃការរៀបចំផែនការថវិកា ដែលឆ្លើយតបនឹងយេនឌ័រ ដល់ក្រសួង និងស្ថាប័នពាក់ពន្ធ័ សម្រាប់ការអនុវត្តការប្រើប្រាស់ថវិកាតាមកម្មវិធី។ គោលដៅយេនឌ័រជាក់លាក់ត្រូវបានបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិកាក្រសួងចំនួនបី គឺក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងការងារ និងក្រសួងរៀបចំដែនដី។ ផែនការថវិកាដែលឆ្លើយតបនឹងយេនឌ័រ ក៏ត្រូវបានដាក់បញ្ចូលផងដែរទៅក្នុងអនុកម្មវិធីទី៤នៃផអ៣ របស់កម្មវិធីជាតិ ១០ឆ្នាំសម្រាប់ការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**គ. កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ**

កម្មវិធីកំណែទម្រង់រដ្ឋបាលសាធាណៈ មានគោលដៅប្រែក្លាយរដ្ឋបាលសាធារណៈឲ្យទៅជាអ្នកផ្តល់សេវាសាធារណៈដ៏សក្តិសិទ្ធ តាមរយៈការធ្វើឲ្យរដ្ឋបាលសាធារណៈកាន់តែមានតម្លាភាពឆ្លើយតប ប្រសិទ្ធភាព និងការលើកកម្ពស់ឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងផ្តោតលើសេវាសាធារណៈ។ ភាពជោគជ័យរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងវិស័យនេះ គឺការដាក់ចេញនូវសេចក្តីណែនាំរបស់ក្រសួងមុខងារសាធារណៈស្តីពីការជ្រើសរើស

[151] ដូច១៥០។

[152] សេចក្តីសង្ខេបគោលនយោបាយ១, ២០។

មន្ត្រីរាជការក្របខណ្ឌថ្មីដោយកំណត់កម្រិតចំនួនពី២០%-៥០%ជាស្ត្រី។[153] ជាលទ្ធផលចំនួនមន្ត្រីរាជការជាស្ត្រីបានកើនឡើងពី៣២%នៅក្នុងឆ្នាំ២០០៧ ដល់៣៧%នៅក្នុងឆ្នាំ២០១៣ និង៣៩%នៅក្នុងឆ្នាំ២០១៥។ លើសពីនេះទៀតរាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យស្តីពីការកែសម្រួលអាយុចូលនិវត្តរបស់មន្ត្រីរាជការជាស្ត្រី។

#### ៣.២.១.៣. ការលើកកម្ពស់ការសិក្សា និងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ស្ត្រី

ក្រសួងកិច្ចការនារីសហការជាមួយ និងក្រសួងអប់រំ យុវជន និងកីឡា ចូលរួមលើកកម្ពស់នូវសមភាពយេនឌ័រក្នុងវិស័យអប់រំ។ ជាពិសេសការបង្កើនការទទួលបាននូវសេវាអប់រំដល់ស្ត្រី និងក្មេងស្រីក្នុងក្រុមដែលងាយរងគ្រោះ[154] តាមរយៈការបង្កើនវិធានការយល់ដឹង គណៈនេយ្យភាពសង្គម អាហាររូបករណ៍ និងជំនួយហិរញ្ញវត្ថុផ្សេងទៀត និងបង្កើនការចូលរួមរបស់ស្ត្រីដែលជាអ្នកផ្តល់ និងគ្រប់គ្រងសេវាអប់រំនៅគ្រប់ផ្នែក។[155] និងតាមរយៈការបង្កើនសមត្ថភាពបច្ចេកទេស និងការប្តេជ្ញាចិត្តរបស់មន្ត្រីពាក់ពន្ធ័ក្នុងការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ កម្មវិធី និងផែនការពាក់ពន្ធ័នឹងវិស័យអប់រំ។ ជាពិសេសក្រសួងកិច្ចការនារីស្វែងរកមតិគាំទ្រជាមួយស្ថាប័នពាក់ពន្ធ័ក្នុងបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យអប់រំ និងធ្វើការសម្របសម្រួល និងគាំទ្របច្ចេសទេសការបញ្ចូលបញ្ហាយេនឌ័រទៅក្នុងគោលនយោបាយ កម្មវិធី ផែនការសកម្មភាព និងផែនការចិរការរយៈពេល៥ឆ្នាំ និងប្រចាំឆ្នាំរបស់ក្រសួងអប់រំយុវជន និងកីឡា។ បន្ថែមពីនេះផងដែរគឺធ្វើការស្រាវជ្រាវរកមូលហេតុ និងផលប៉ះពាល់អំពីបញ្ហាថ្មីៗទាក់ទងយេនឌ័រក្នុងវិស័យអប់រំ ព្រមទាំងលើកជាអនុសាសន៍ និងមធ្យោបាយឆ្លើយតបដ៏សមស្រប។ ជាក់ស្តែងនៅក្នុងឆ្នាំ២០១២ នៅកម្រិតថ្នាក់បឋមសិក្សា និងថ្នាក់មធ្យមសិក្សា ការចុះឈ្មោះចូលរួមសិស្សស្រីមានចំនួនប្រហាក់ប្រហែលនឹងសិស្សប្រុស។ ចំណែកឯនៅក្នុងថ្នាក់ឧត្តមសិក្សាសមាមាត្រសិស្សស្រីកំពុងមានការកើនឡើងជាបន្តៗពី៣៣% ក្នុងឆ្នាំ២០០៨ ដល់៣៧.៦% ក្នុងឆ្នាំ២០១១។[156]

ដើម្បីបង្កើនការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ស្ត្រី ក្រសួងកិច្ចការនារីព្យាយាមស្វែងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ពន្ធ័ ដែលមានក្រសួងការងារ និងវិជ្ជាជីវៈ និងបណ្តាដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល។ នៅក្នុងគោលបំណងការស្វែងរកនូវការគាំទ្រមតិ ថវិកា និងជំរុញឲ្យស្ថាប័ន

---

[153] ក្រសួងមុខងារសាធារណៈ, *ផែនការក្របខណ្ឌក្រសួងស្ថាប័នឆ្នាំ២០០៨*, ២០០៨។

[154] ក្រុមស្ត្រី និងក្មេងស្រីដែលងាយរងគ្រោះមាន៖ ស្ត្រីចាស់ជរា ស្ត្រីនិងក្មេងស្រីពិការ ស្ត្រីផ្ទុកមេរោគអេដស៍ ស្ត្រីក្រីក្រ ស្ត្រីជនជាតិដើមភាគតិចជាដើម។

[155] នារីរតនៈទី៤, ៣៦។

[156] នារីរតនៈទី៤, ៤។

ពាក់ពន្ធ័បង្កើតន្ថែមទៀតនូវកម្មវិធី ក៏ដូចជាវគ្គបណ្តុះបណ្តាលជំនាញផ្សេងៗដល់ស្ត្រី ជាពិសេសស្ត្រីដែលងាយរងគ្រោះ។ លើសពីនេះផងដែរ ក្រសួងកិច្ចការនារីពង្រឹងនូវការងាររបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីនៅតាមមូលដ្ឋាន ដើម្បីធានាឲ្យបាននូវការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ស្ត្រីដែលក្រីក្រ និងគ្មានមុខរបរ ដើម្បីបង្កើតជាជំនាញស្វែងរកចំណូល។ ជាពិសេសការបណ្តុះបណ្តាលនូវជំនាញថ្មីៗដែលឆ្លើយតបទៅនឹងតម្រូវការទៅផ្សារបច្ចុប្បន្ន។ ជាលទ្ធផលនៅក្នុងឆ្នាំ២០១៣ ស្ត្រីប្រមាណ១៣,១០២ ទទួលបានវគ្គបណ្តុះបណ្តាលពីមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី។[157]

### ៣.២.១.៤. ជំរុញការបង្កើត និងការអភិវឌ្ឍន៍សហគ្រាសខ្នាតមីក្រូ តូច និងមធ្យមរបស់ស្ត្រី

ស្ត្រីកម្ពុជាមានសកត្តានុភាពក្នុងការងារអាជីវកម្ម ប៉ុន្តែនៅជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូច្នេះដើម្បីចូលរួមលុបបំបាត់បញ្ហាប្រឈម ក៏ដូចជំរុញការបង្កើត និងការអភិវឌ្ឍន៍អាជីវកម្មរបស់ស្ត្រី ក្រសួងកិច្ចការនារីបានសហការជាមួយក្រសួង ស្ថាប័នពាក់ពន្ធ័ និងវិស័យឯកជន។ កិច្ចសហប្រតិបត្តិការរួមមាន ការបង្កើនការយល់ដឹងអំពីការបង្កើត និងការអភិវឌ្ឍន៍អាជីវកម្មដែលមានលក្ខណៈស្របច្បាប់ដល់អាជីវករជាស្ត្រី។ បន្ថែមពីលើនេះ ក៏ផ្តល់ការសម្របសម្រួលដល់ស្ត្រីដើម្បីទទួលសេវាអភិវឌ្ឍន៍អាជីវកម្មពាក់ពន្ធ័នឹងសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម និងការអភិវឌ្ឍន៍សមត្ថភាពក្នុងការបង្កើតបណ្តាញសហគ្រិនស្ត្រី។

ដើម្បីបង្កើនការយល់ដឹងរបស់ស្ត្រីអំពីការបង្កើតអាជីវកម្ម និងការអភិវឌ្ឍន៍អាជីវកម្មដែលមានលក្ខណៈស្របច្បាប់ ត្រូវផ្តល់ការយល់ដឹងអំពីច្បាប់ និងបទដ្ឋានគតិយុត្តទាក់ទងនឹងសហគ្រាសខ្នាតមីក្រូ តូច និងមធ្យមដល់ក្រុមអាជីវកម្ម និងសហគ្រិនជាស្ត្រី។ តាមរយៈនេះក្រសួងកិច្ចការនារីសហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសមាគមអាជីវកម្មសហគ្រិនស្ត្រី ចូលរួមបង្កើនការយល់ដឹងអំពីប្រធានបទ ដែលពាក់ពន្ធ័នឹងសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម ដូចជាការចុះបញ្ជីធុរៈកិច្ច ពន្ធគយ និងពន្ធអាករជាដើម។[158] ជាពិសេសការប្រមូលបញ្ហាចម្បងៗរបស់អាជីវករស្ត្រី ទៅវិភាគ និងដាក់បញ្ចូលក្នុងរបៀបវីរៈនៃវេទិការាជរដ្ឋាភិបាលរវាងវិស័យសាធារណៈ និងវិស័យឯកជន។ ម្យ៉ាងវិញទៀតគឺធ្វើការជំរុញ និងគាំទ្របច្ចេសទេសដើម្បីលើកទឹកចិត្តឲ្យស្ត្រីចូលរួមក្នុងក្រុមការងារនៃវេទិការនោះ។

អាជីវករជាស្ត្រីក៏នឹងទទួលបានការផ្តល់សេវាអភិវឌ្ឍន៍អាជីកម្ម។ ក្រសួងកិច្ចការនារី តាមរយៈកិច្ចសហការ និងភាពជាដៃគូជាមួយអ្នកផ្តល់សេវាអាជីវកម្ម ទាំងផ្នែកសាធារណៈ និងឯកជន

[157] នារីរតនៈទី៤, ៣។

[158] នារីរតនៈទី៤, ៣៣។

រួមទាំងស្ថាប័នមីក្រូហិរញ្ញវត្ថុ ចូលរួមរៀបចំព្រឹត្តិការណ៍ និងកម្មវិធីបង្កើនការយល់ដឹងពីសេវាអភិវឌ្ឍន៍អាជីវកម្មសំខាន់ៗដល់អាជីវករជាស្ត្រី។[159] បន្ថែមពីលើនេះ ការអភិវឌ្ឍន៍សមត្ថភាពស្ត្រីក្នុងការបង្កើតបណ្តាញសហគ្រិន ក៏ត្រូវបានជំរុញ និងគាំទ្រលើកចិត្តតាមរយៈការសម្របសម្រួលជាមួយនឹងសមាគមអាជីវកម្ម ក្នុងការបង្កើនសមាជិកជាស្ត្រី។ ហេតុនេះហើយទើបមានចំនួនស្ត្រីកើនឡើងនៅក្នុងសមាគមសហគ្រិនស្ត្រី នៅក្នុងឆ្នាំ២០១២ដល់១៥០ រូប។

### ៣.២.១.៥. ការបង្កើនកាលានុវត្តភាពការងារ និងលក្ខខណ្ឌការងារសម្រាប់ស្ត្រី

រាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងកិច្ចការនារី ព្យាយាមបង្កើនកាលានុវត្តភាព និងលក្ខខណ្ឌការងារ កាន់តែប្រសើរឡើងជាងមុនសម្រាប់ស្ត្រី ជាពិសេសសម្រាប់ក្រុមស្ត្រីដែលងាយរងគ្រោះ។ដើម្បីសម្រេចឲ្យបានកិច្ចការនេះក្រសួងកិច្ចការនារី ព្យាយាមលើកកម្ពស់ការតាក់តែង និងអនុវត្តគោលនយោបាយជាតិស្តីពីការងារ ដែលមានបញ្ចូលការផ្តល់កាលានុវត្តភាពដល់ស្ត្រី។ ជាមួយនឹងការពង្រឹងលទ្ធភាព របស់ស្ត្រីក្នុងការទទួលបានផលប្រយោជន៍ពីលក្ខខណ្ឌការងារកិច្ចគាំពារសង្គម និងបទដ្ឋានការងារឲ្យកាន់តែមានភាពប្រសើរឡើង។អ្វីដែលសំខាន់នោះ គឺផ្តល់ឲ្យស្ត្រីនូវលទ្ធភាពដោះស្រាយវិវាទការងារស្មើគ្នានឹងបុរស។ [160]

នៅក្នុងការងារលើកកម្ពស់ការតាក់តែង និងអនុវត្តគោលនយោបាយ ស្តីពីការងារដែលមានបញ្ចូលការផ្តល់កាលានុភាពដល់ស្ត្រី ក្រសួងកិច្ចការនារីសហការជាមួយនឹងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបណ្តាដៃគូអភិវឌ្ឍន៍ ក្នុងការពង្រីកការដាក់បញ្ចូល និងតាមដានចំណុចដៅនៃការងារដែលមានសមភាពយេនឌ័រ។ [161] បន្ថែមពីនេះផងដែរក្រសួងកិច្ចការនារី ក៏យកចិត្តទុកដាក់ និងឆ្លើយតបនឹងការពង្រីកកាលានុភាពការងារសម្រាប់ស្ត្រី តាមរយៈការផ្តល់ការសម្របសម្រួលផ្នែកបច្ចេកទេសដល់ក្រសួងស្ថាប័នពាក់ពន្ធ័ ដើម្បីថាស្ត្រីនឹងទទួលបានកាលានុវត្តភាពការងារល្អប្រសើរជាងមុន។

ស្ត្រីកម្ពុជា ក៏នឹងធានាទទួលបានការដោះស្រាយវិវាទការងារ ដោយស្មើភាពគ្នានឹងបុរស និងកិច្ចគាំពារស្ត្រីទេសន្តប្រវេស៍។ក្រសួងកិច្ចការនារី ជាមួយនឹងក្រសួងការងារ អង្គការពលកម្មអន្តរជាតិ សហពន្ធ័និយោជិក និងសមាគមអាជីវកម្ម ចូលរួមជាមួយគ្នាក្នុងការបង្កើនចំណែករបស់ស្ត្រីក្នុងការស្វែងរកដំណោះស្រាយវិវាទការងារ តាមរយៈការផ្តល់នូវការប្រឹក្សាច្បាប់ ការជួយដាក់ពាក្យ

[159] នារីរតនៈទី៤, ៣៣។

[160] នារីរតនៈទី៤, ៣១។

[161] នារីរតនៈទី៤, ៣១។

បណ្ដឹង និងការតាមដានដំណើរការរឿងក្ដីទាក់ទងនឹងវិវាទការងារ និងបទល្មើសលើពលករចំណាកស្រុកជាស្ត្រី។ កិច្ចការងារនេះ នឹងអាចជួយកាត់បន្ថយវិវាទការងាររបស់ស្ត្រី និងជាពិសេសការស្វែងនូវដំណោះស្រាយដ៏ល្អប្រសើរសម្រាប់ស្ត្រី។ ជាពិសេសចូលរួមកកាត់បន្ថយ ការការបៀតបៀនខាងផ្លូវភេទ និងរូបរាងកាយ ការប្រើប្រាស់អំពើហិង្សា ការជួយដូរស្ត្រី និងការកេងប្រវញ្ច័កម្លាំងពលកម្មស្ត្រីជាដើម។ ម៉្យាងវិញទៀត ការពង្រីកនូវកលានុវត្តភាព និងឱកាសការងារសម្រាប់ស្ត្រីនឹងចូលរួមកាត់បន្ថយការធ្វើទេសន្តប្រវេសន៍របស់ស្ត្រី ក៏ដូចជាបញ្ហាហានិភ័យរបស់ស្ត្រីទេសន្តប្រវេសន៍ ដូច្នេះស្ត្រីអាចទទួលបានអត្ថប្រយោជន៍ច្រើនជាងមុនពីការធ្វើទេសន្តប្រវេសន៍ក្នុង និងក្រៅប្រទេស។

### ៣.២.១.៦. ការកាត់បន្ថយបញ្ហាប្រឈមរបស់ស្ត្រីនៅក្នុងវិស័យកសិកម្ម និងការអភិវឌ្ឍន៍ជីវភាពរស់ជនបទ

កាផ្លាស់ប្ដូរអាកាសធាតុពិភពលោក និងការកើនឡើងនៃកំដៅផែនដីជះឥទ្ធិពលទៅដល់ការងារកសិករជាពិសេសចំពោះស្ត្រីនៅក្នុងក្រុមងាយរងគ្រោះ។ វិស័យកសិកម្មគឺជាប្រភពចំណូលមួយសំខាន់សម្រាប់ស្ត្រីនៅជនបទ ដូច្នេះបញ្ហាគ្រោះធម្មជាតិដូចជា គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងគ្រោះមហន្តរាយផ្សេងទៀត គឺផ្ដល់ផលប៉ះពាល់ខ្លាំងដល់ការងារកសិកម្មរបស់ស្ត្រី។ដើម្បីកាត់បន្ថយបញ្ហាប្រឈមនេះ ក្រសួងកិច្ចការនារី ជាមួយនឹងគណៈកម្មាធិការគ្រប់គ្រងបម្រែបម្រួលអាកាសធាតុ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ព្យាយាមបង្កើនសមត្ថភាពមន្ត្រីបច្ចេកទេស និងការគាំទ្រពីថ្នាក់ដឹកនាំ និងមន្ត្រីពាក់ពន្ធ័ ស្ដីពីយេនឌ័រ និងបម្រែបម្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ។[162]

> លោកស្រីគង់សាឡួន បានមានប្រសាសន៍ទាក់ទងនឹងចំនុចនេះថា៖ «ប្រសិនបើមានបញ្ហាទាក់ទិននឹងបញ្ហាគ្រោះធម្មជាតិរដ្ឋបាលថ្នាក់ខេត្តនឹងជម្រាមដល់រដ្ឋបាលថ្នាក់ស្រុកដើម្បីឲ្យផ្ដល់ដំណឹងនេះដល់ប្រជាជនដើម្បីត្រៀមលក្ខណៈ ដោះស្រាយបញ្ហាជាពិសេសចំពោះស្ត្រីនៅតាមមូលដ្ឋាន។ តាមរយៈគម្រោងអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ច ចាប់តាំងពីឆ្នាំ ២០១២ របស់រាជរដ្ឋាភិបាល បានជំរុញនូវជីវភាពរបស់ស្ត្រីល្អប្រសើរ។ វាផ្ដល់ជាវេទិកាដល់ស្ត្រីក្នុងនិយាយអំពីបញ្ហាក្នុងវិស័យកសិកម្ម និងការងារក្រៅកសិកម្ម ដើម្បីពិភាក្សាស្វែងរកដំណោះស្រាយ រាល់២ខែម្ដងនៅក្នុងកិច្ចប្រជុំថ្នាក់ឃុំ។ ស្ត្រីនៅមូលដ្ឋានបច្ចុប្បន្នមានការចេះដឹង

[162] នារីរតនៈទី៤, ៦២។

ច្រើនជាងមុន និងមានភាពស្វាហាប់ក្នុងបញ្ចេញមតិ និងចូលរួមនៅក្នុងកិច្ចប្រជុំផ្សេងៗ។ [163]

ដូច្នេះ ដោយយោងទៅតាមប្រសាសន៍របស់អ្នកស្រី ស្ត្រីដែលធ្វើកសិកម្មអាចនឹងត្រៀមលក្ខណៈទុកជាមុន និងទទួលបានដំណោះស្រាយពីសំណាក់រាជរដ្ឋាភិបាល។ ចំណែកឯបញ្ហាទាក់ទងនឹងជីវភាពរស់នៅជនបទ ស្ត្រីក៏ទទួលបាននូវគឺទទួលបានការបណ្តុះបណ្តាលនូវជំនាញបំណិនជីវិតបន្ថែម ដែលអាចឲ្យស្ត្រីស្វែងរកនូវប្រាក់ចំណូលក្រៅពីការងារកសិកម្មដើម្បីធ្វើឲ្យជីវភាពរស់នៅកាន់តែប្រសើរឡើង។ នៅពេលបច្ចុប្បន្នស្ត្រីមួយចំនួនធំមានការងារបន្ទាប់បន្សំក្រៅពីការងារកសិកម្ម ដូចជា ការចិញ្ចឹមសត្វ តម្បាញ និងការកែច្នៃម្ហូបអាហារជាដើម។ ដើម្បីអភិវឌ្ឍន៍ជីវភាពរស់នៅរបស់ស្ត្រីនៅតាមជនបទ ក្រសួងកិច្ចការនារី ក្រសួងកសិកម្ម និងបណ្តាអង្គការក្រៅរដ្ឋាភិបាលសហការបង្កើតនូវគម្រោងផ្សេងៗ ក្នុងការគាំទ្រស្ត្រី នៅក្នុងវិស័យកសិកម្ម និងការងារក្រៅកសិកម្ម តាមរយៈការផ្តល់នូវវគ្គបណ្តុះបណ្តាលជំនាញមួយចំនួន និងការណែនាំស្ត្រីពីការធ្វើកសិកម្មឲ្យទទួលបានផលល្អ បូករួមទាំងការគាំទ្រផ្នែកហិរញ្ញវត្ថុផងដែរ។បន្ថែមពីនេះផងដែរ គឺការបញ្ជ្រាបយេនឌ័រក្នុងយុទ្ធសាស្ត្រជាតិឆ្លើយតបទៅនឹងបម្រែបម្រួលអាកាសធាតុ ការគ្រប់គ្រងគ្រោះមហន្តរាយ និងការកាត់បន្ថយហានិភ័យក៏ដូចជាការយុទ្ធនាការផ្តល់ពត៌មានគ្រលប់ប្រកបដោយប្រសិទ្ធិភាព ក្នុងការឆ្លើយតបនឹងគ្រោះមហន្តរាយឲ្យបានដល់ស្ត្រីនិងក្រុមស្ត្រីងាយរងគ្រោះ។

### ៣.២.២. ដំណោះស្រាយរបស់សង្គមស៊ីវិល

#### ៣.២.២.១. ការគាំទ្រមតិ និងមូលនិធិ

សង្គមស៊ីវិល និងអង្គការអន្តរជាតិដើរតួយ៉ាងសំខាន់ នៅក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី ជាពិសេសផ្នែកសេដ្ឋកិច្ច ដែលជាវិស័យស្នូលនៃការអភិវឌ្ឍន៍ជាតិ។ ប្រទេសកំពុងអភិវឌ្ឍន៍ និងមានការអភិវឌ្ឍន៍តិចតួចភាគច្រើន គឺពឹងផ្អែកទៅលើការគាំទ្រមតិ និងថវិការបស់បណ្តាសង្គមស៊ីវិល និងអង្គការអន្តរជាតិ ដើម្បីធ្វើការលើកកម្ពស់សមភាពយេនឌ័រ ប្រទេសកម្ពុជាក៏ជាប្រទេសមួយក្នុងចំណោមប្រទេសទាំងនោះដែរ។ ដើម្បីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីកម្ពុជា បណ្តាអង្គការសង្គមស៊ីវិល និងអង្គការអន្តរជាតិមួយចំនួនចូលរួមជួយជ្រុំជ្រែងតាមរយៈការគាំទ្រមតិ និងមូលនិធិ។

ស្ថាប័នទាំងនេះព្យាយាមជំរុញ និងលើកទឹកចិត្តរាជរដ្ឋាភិបាលឲ្យបង្កើននូវការបង្កើតច្បាប់គោលនយោបាយ ផែនការ និងកម្មវិធី ដែលមានបញ្ចូលសមភាពយេនឌ័រ ជាពិសេសការលើក

[163] អ្នកស្រី គង់ សាឡុន(ប្រធានមន្ទីរកិច្ចការនារីខេត្តព្រៃវែង), បទសម្ភាសផ្ទាល់ខ្លួន, ០២ ឧសភា ២០១៦។

កម្ពស់ស្ថានភាពស្ត្រីក្នុងវិស័យសេដ្ឋកិច្ច។ បន្ថែមពីនេះផងដែរគឺការផ្តល់នូវជំនួយផ្នែកហិរញ្ញវត្ថុដល់រាជរដ្ឋាភិបាល ដើម្បីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីទាំងនោះ។ ឧទាហរណ៍ដូចជា ការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ ពឹងផ្អែកលើប្រភពធនធានពីរសំខាន់គឺថវិការរដ្ឋ និងការចូលរួមពីដៃគូពាក់ពន្ធ័។ តម្លៃប៉ាន់ស្មាននៃតម្រូវការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ ប្រមាណ ៣១,១០០,០០០ ដុល្លាអាមេរិច ខណៈការប៉ាន់ប្រមាណចំណាយក្នុងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី មានចំនួន ៤,៩០០,០០០ ដុល្លាអាមេរិច។[164] ប្រភពមូលនិធិនេះគឺបានមកពីថវិការដ្ឋ រួមជាមួយនឹងថវិការបស់ UN Women, ADB, UNDP, JICA, ILO, European Unionនិងដៃគូដទៃទៀត។[165] បន្ថែមពីនេះផងដែរបណ្តាអង្គការអន្តររដ្ឋាភិបាល ដូចជាUN Women និងអង្គការអន្តរជាតិដូចជា ធនាគារអភិវឌ្ឍន៍អាស៊ីអង្គការពលកម្មពិភពលោកជាដើម ក៏ផ្តល់នូវជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដល់អង្គការសង្គមស៊ីវិលមួយចំនួន ដែលធ្វើការលើកកម្ពស់សមភាពយេនឌ័រ ដំណើរការនូវគម្រោងរបស់ខ្លួនក្នុងការលើកកម្ពស់ស្ថានភាពស្ត្រីកម្ពុជានៅក្នុងវិស័យសេដ្ឋកិច្ច។ ជារួមមកអង្គការអន្តរជាតិ គឺមិនត្រឹមតែគាំទ្រមតិ និងមូលនិធិដល់តែរាជរដ្ឋាភិបាលទេ តែថែមដល់អង្គការសង្គមស៊ីវិលមួយចំនួនផងដែរ ដើម្បីចូលរួមលើកកម្ពស់ស្ថានភាពស្ត្រីកម្ពុជាឲ្យមានភាពប្រសើរឡើងនៅក្នុងវិស័យនេះ។

### ៣.២.២.២. ការបង្កើតគម្រោង និងកម្មវិធីលើកស្ទួយស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច

ដើម្បីសម្រេចឲ្យបាននូវការលើកកម្ពស់ស្ថានភាពស្ត្រីកម្ពុជា ឲ្យមានភាពប្រសើរឡើងនៅក្នុងវិស័យសេដ្ឋកិច្ច គម្រោង និងកម្មវិធីផ្សេងៗត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ ដោយអង្គការសង្គមស៊ីវិល និងអង្គការអន្តរជាតិ។ គម្រោង និងកម្មវិធីទាំងនេះផ្តោតទៅលើផ្នែកផ្សេងៗគ្នានៃវិស័យសេដ្ឋកិច្ច និងឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលបានធ្វើការសិក្សាស្រាវជ្រាវដូចជា ការផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងចំណេះដឹងមូលដ្ឋាន (ដូចជា ភាសាអង់គ្លេស និងជំនាញកុំព្យូទ័រ) ការបំប៉នស្ត្រីពីភាពជាសហគ្រិន ជំនាញក្នុងការធ្វើកសិកម្ម និងការជួយអភិវឌ្ឍន៍ជីវភាពរស់នៅជនបទរបស់ស្ត្រី ជាពិសេសក្រុមស្ត្រីដែលងាយរងគ្រោះ។

កាលពីឆ្នាំ២០១១ នៅក្រោមជំនួញផ្នែកហិរញ្ញវត្ថុរបស់UN Women ប្រចាំនៅកម្ពុជា គម្រោងទ្រង់ទ្រាយធំមួយត្រូវបានប្រគល់ទៅឲ្យអង្គការពីរ ជាអ្នកប្រតិបត្តិ គឺអង្គការផ្សព្វផ្សាយសេវាសុខភាពអប់រំកម្ពុជា និងអង្គការកម្ពុជាអប់រំ និងថែទាំជំងឺអេដស៍។ គម្រោងនេះមានឈ្មោះថា ការពង្រីកា

---

[164] នារីរតនៈទី៤, ១៧៦។

[165] នារីរតនៈទី៤, ១៧៦។

លានុវត្តភាព សេដ្ឋកិច្ចរស់នៅរបស់ស្ត្រីក្រីក្រ និងស្ត្រីមានផ្ទុកមេរោគអេដស៍ ឬហៅថាកម្មវិធីសេត្ថ។ គម្រោងនេះចាប់ផ្តើមនៅខែមករា ឆ្នាំ២០១១ ដែលមានរយៈពេល២ឆ្នាំ និងបានចំណាយថវិកាអស់ ១,១៧១,៧៥៤ ដុល្លាអាមេរិច និងបានជួយដល់ស្ត្រីដែលមានផ្ទុកមេរោគអេដស៍ចំនួន១,៣០០នាក់ និងស្ត្រីក្រីក្រចំនួន៣១០នាក់។ [166] គម្រោងនេះគឺចូលរួមចំណែកក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ នារីរតនៈទី៣ ដែលផ្តោតទៅលើយុទ្ធសាស្ត្រទី១ ស្តីអំពី ការផ្តល់អំណាចក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច។ គោលបំណងនៃគម្រោងនេះគឺធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសេដ្ឋកិច្ចរបស់ស្ត្រីជាពិសេសក្រុមស្ត្រី ដែលងាយរងគ្រោះ។ គួរឲ្យកត់សម្គាល់ឃើញថា នៅពេលចាប់ផ្តើមគម្រោង៣២%នៃស្ត្រីដែលបាន ចូលរួមនៅក្នុងគម្រោងគឺរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រជាតិ ប៉ុន្តែនៅពេលគម្រោងបានបញ្ចប់ស្ត្រី ចំនួនធំមានជីវភាពល្អប្រសើរជាងមុន ជាពិសេសការធ្លាក់ចុះនូវភាគរយនៃស្ត្រីដែលរស់នៅក្រោម បន្ទាត់នៃភាពក្រីក្រមកត្រឹម៣០%។[167]

> ដោយយោងទៅតាម មារីគេន ប៊ី. ហាប៊ីត បាននិយាយថាៈ «នាពេលថ្មីៗនេះUN Women ប្រចាំកម្ពុជាកំពុងធ្វើការលើគម្រោងពីរនៅក្នុងការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីកម្ពុជា។ គម្រោងទី១ស្តីអំពីការផ្តល់ការគាំទ្រផ្នែកចិត្តសាស្ត្រដល់កម្មករធ្វើការតាមផ្ទះ និងគម្រោងមួយទៀតស្តីអំពីការធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ស្ត្រីនៅតាមជនបទ។ នៅក្នុងគម្រោងទី ២ UN Womenកំពុងធ្វើការជាមួយអង្គការបន្ទាយស្ត្រីដែលនឹងចាប់អនុវត្តនៅក្នុងខែកក្កដា ឆ្នាំ ២០១៦ ខាងមុខនេះ។ គម្រោងនេះមានគោលបំណងធ្វើប្រសើរឡើងនូវជីវភាពរស់នៅរបស់ស្ត្រីនៅជនបទ តាមរយៈការបណ្តុះបណ្តាលជំនាញសហគ្រិនភាព ដើម្បីអភិវឌ្ឍន៍សមត្ថភាពស្ត្រី និងសកម្មភាពសេដ្ឋកិច្ចមួយចំនួនឲ្យស្ត្រី។»[168]

គម្រោងដែលបានលើកឡើងខាងលើនេះគឺជាឧទាហរណ៍អំពីគម្រោងដែលបានអនុវត្ត និង គ្រោងនឹងអនុវត្តរបស់UN Women ប្រចាំនៅកម្ពុជា ប៉ុន្តែនៅមានគម្រោងជាច្រើនទៀតរបស់បណ្តា អង្គការអន្តរជាតិ និងសង្គមស៊ីវិល ក្នុងការលើកកម្ពស់ស្ថានភាពស្ត្រីកម្ពុជានៅក្នុងវិស័យសេដ្ឋ

[166] អង្គការផ្សព្វផ្សាយសេវាសុខភាពអប់រំកម្ពុជា(CHEM) និងអង្គការកម្ពុជាអប់រំ និងថែទាំជំងឺអេដស៍(CHEC), *ការពង្រីកកាលានុវត្តភាពសេដ្ឋកិច្ចជីវភាពរស់នៅរបស់ស្ត្រីក្រីក្រ និងស្រីមានផ្ទុកមេរោគអេដស៍ ឬហៅកាត់ថាគម្រោងសេត្ថ ៖ មត្តទេសរបស់គម្រោងសេត្ថ*,( ភ្នំពេញៈCHEM and CHEC, សីហា ២០១១), ៨។

[167]អង្គការកម្ពុជាអប់រំ និងថែទាំជំងឺអេដស៍(CHEC), *របាយការណ៍ប្រចាំឆ្នាំខែកក្កដា ២០១២ - មិថុនា ២០១៣*, (ភ្នំពេញៈ CHEC, ២០១៣), ១១។

[168] ម៉ារីគែន ប៊ី.ហាប៊ីត, (មន្ត្រីផ្នែកទំនាក់ទំនងរបស់អង្គការសហប្រជាជាតិគាំទ្រសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី ប្រចាំកម្ពុជា), កិច្ចសម្ភាសផ្ទាល់ខ្លួន, ០២ មេសា ២០១៦។

កិច្ច។ ឧទាហរណ៍ដូចជាផែនការរបស់ ADB ក្នុងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីកម្ពុជា នៅក្នុងចន្លោះឆ្នាំ ២០១៤-២០១៨ ដែលក្នុងនោះមានគម្រោងតូចៗជាច្រើននៅក្នុងនោះទៀត។[169] ទោះបីជាគម្រោង និងកម្មវិធីទាំងនេះមិនជួយស្ត្រីកម្ពុជាទូទាំងប្រទេសឲ្យមានជីវភាពល្អប្រសើរ និងមានសកត្តានុភាពនៅក្នុងវិស័យសេដ្ឋកិច្ចក៏ដោយ ប៉ុន្តែវាក៏ចូលរួមចំណែកមួយភាគធំក្នុងការកាត់បន្ថយបញ្ហាប្រឈមរបស់ស្ត្រី ដើម្បីជួយឲ្យស្ត្រីកម្ពុជាមួយចំនួនមានជីវភាពរស់នៅល្អប្រសើរជាងមុន ជាពិសេសស្ត្រីនៅជនបទ និងក្រុមស្ត្រីដែលងាយរងគ្រោះ។

### ៣.២.២.៣. ការសិក្សាស្រាវជ្រាវពីបញ្ហាប្រឈមរបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច

ក្រសួងកិច្ចការនារីសហការជាមួយអង្គការអន្តរជាតិ និងសង្គមស៊ីវិល ធ្វើការសិក្សាស្រាវជ្រាវទៅលើបញ្ហាប្រឈមរបស់ស្ត្រីកម្ពុជាជួបប្រទះនៅក្នុងវិស័យសេដ្ឋកិច្ច។ ការសិក្សាស្រាវជ្រាវនេះមានគោលបំណងស្វែងយល់ឲ្យដឹងច្បាស់ពីឧបសគ្គដែលស្ត្រីជួបប្រទះ ដើម្បីស្វែងរកដំណោះស្រាយជាក់លាក់ និងដាក់បញ្ចូលបញ្ហា និងដំណោះស្រាយទៅក្នុងផែនការយុទ្ធសាស្ត្រ និងកម្មវិធីផ្សេងៗ។ ម្យ៉ាងវិញទៀតគឺដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់រាជរដ្ឋាភិបាលក៏ដូចជាសាធារណៈជនប្រុងប្រយត្ន័ទៅលើបញ្ហា និងទប់ស្កាត់បញ្ហាកុំឲ្យមានសភាពកាន់តែខ្លាំងឡើង។

ជាក់ស្តែងនាពេលបច្ចុប្បន្នប្រហែលជាមិនសូវអ្នកមានការចាប់អារម្មណ៍ និងព្រួយបារម្ភពីបញ្ហាកម្មករធ្វើការតាមផ្ទះទេ។ ប៉ុន្តែUN Women ប្រចាំនៅកម្ពុជាបានធ្វើការស្រាវជ្រាវឃើញថាស្ត្រីកម្ពុជាដែលជាកម្មករធ្វើការតាមផ្ទះ បានជួបប្រទះនឹងបញ្ហាងាយរងគ្រោះ។ អត្ថបទស្រាវជ្រាវមួយមានឈ្មោះថា «ក្រៅពីទ្វារដែលបានបិទ» ដែលបានបោះពុម្ពនៅក្នុងឆ្នាំ២០១៥ របស់ស្ថាប័ននេះមានគោលបំណងសិក្សាស្រាវជ្រាវពីស្ថានភាពរបស់កម្មករធ្វើការងារតាមផ្ទះដើម្បីទាក់ទាញនូវយោបល់ និងការចាប់អារម្មណ៍ពីសាធារណៈទៅលើបញ្ហារបស់ពួកគាត់ដែលកំពុងតែជួបប្រទះ។ [170] ជាពិសេសដោយសារតែការខ្វះខាតនូវទិន្នន័យជាផ្លូវការ ដូច្នេះការសិក្សាស្រាវជ្រាវនេះនឹងបំពេញនូវចន្លោះខ្វះខាតនៃចំណេះដឹង និងដើម្បីការពារ និងលើកកម្ពស់សិទ្ធិកម្មករធ្វើការងារតាមផ្ទះពីការកេងប្រវញ្ច័លើកំលាំងពលកម្ម និងការរំលោភបំពានទៅលើសិទ្ធិ។

នៅក្នុងឆ្នាំ២០១៥ ADBបានបោះពុម្ពផ្សាយអត្ថបទសិក្សាមួយដែលមានឈ្មោះថា«ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីកម្ពុជា» ដែលការស្រាវជ្រាវនេះទាក់ទងទៅនឹងបញ្ហាប្រឈម

[169] ដូច៧៩, ៥៩។

[170] UN Women, Out from behind closed doors: A study on domestic workers in Cambodia [នៅខាងក្រោយទ្វារដែលបានបិទ៖ ការសិក្សាទៅលើកម្មករធ្វើការតាមផ្ទះនៅកម្ពុជា], Research paper. (ភ្នំពេញ៖ UN Women, ២០១៥), ៣។

របស់ស្ត្រីកម្ពុជានៅក្នុងវិស័យសេដ្ឋកិច្ច។ ការសិក្សាស្រាវជ្រាវនេះគឺផ្តោតទៅលើបញ្ហាយេនឌ័រសំខាន់ៗនៅក្នុងសេដ្ឋកិច្ចកម្ពុជាដែលក្នុងនោះមានដូចជា ការចូលរួមរបស់ស្ត្រីកម្ពុជានៅក្នុងសកម្មភាពសេដ្ឋកិច្ច អត្ថប្រយោជន៍ដែលស្ត្រីទទួលបានពីការអភិវឌ្ឍន៍សេដ្ឋកិច្ច និងស្ត្រីនៅក្នុងតួនាទីក្នុងការធ្វើសេចក្តីសម្រេច។[171] គួរឲ្យកត់សម្គាល់ឃើញ ការសិក្សារបស់ADBនេះគឺបានផ្តល់ជាប្រភពពត៌មានដ៏សំខាន់នៅក្នុង ការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជាដែលរៀបចំដោយក្រសួងកិច្ចការនារី។

ការសិក្សាស្រាវជ្រាវទៅលើបញ្ហាប្រឈមរបស់ស្ត្រីកម្ពុជានៅក្នុងវិស័យសេដ្ឋកិច្ច គឺចូលរួមមួយចំណែកនៅក្នុងការកាត់បន្ថយឧបសគ្គរបស់ស្ត្រី ដើម្បីធ្វើឲ្យប្រសើរឡើងនូវស្ថានភាពស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច។ ម្យ៉ាងវិញទៀតដោយសារតែប្រទេសកម្ពុជាជាប្រទេសកម្ពុជាអភិវឌ្ឍន៍ គឺមានការខ្វះខាតទាំងផ្នែកថវិកា និងបច្ចេកទេសក្នុងការស្រាវជ្រាវ។ដូច្នេះការសិក្សាស្រាវជ្រាវរបស់បណ្តាអង្គការក្រៅរាជរដ្ឋាភិបាល និងសង្គមស៊ីវិលមានសារៈសំខាន់ក្នុងការចង្អុលប្រាប់រាជរដ្ឋាភិបាលតាមរយៈការផ្តល់ជាអនុសាសន៍ ក្នុងការយកបញ្ហាទៅដោះស្រាយដោយមានប្រសិទ្ធភាព និងបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រ និងកម្មវិធីផ្សេងៗរបស់រាជរដ្ឋាភិបាល។

### ៣.២.២.៤. ការចូលរួមបង្កើតច្បាប់ និងគោលនយោបាយ និងតាមដានការអនុវត្ត

សង្គមស៊ីវិលតែងតែចូលរួមក្នុងក្នុងការបង្កើតច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រដែលការពារ និងលើកកម្ពស់សិទ្ធិសេដ្ឋកិច្ចស្ត្រីកម្ពុជាតាមរយៈការគាំទ្រនូវផ្នែកបច្ចេសទេសដល់ក្រសួងកិច្ចការនារី ក៏ដូចជារាជរដ្ឋាភិបាល។ បន្ថែមពីនេះផងដែរ ស្ថាប័នទាំងនេះជំរុញឲ្យស្ត្រីជាកម្មករ សហជីព និងបណ្តាស្ថាប័នពាក់ពន្ធ័ សហការគ្នាដើម្បីការអភិវឌ្ឍន៍ឲ្យប្រសើរឡើងនូវកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការគោលនយោបាយ។ ជាពិសេសគឺការតាមដានវឌ្ឍនភាពនៃអនុវត្តច្បាប់ ផែនការយុទ្ធសាស្ត្រ បន្ថែមជាមួយនឹងសទ្ធិសញ្ញាអន្តរជាតិផ្សេងៗពាក់ពន្ធ័នឹងសិទ្ធិស្ត្រី ដែលកម្ពុជាបានផ្តល់សច្ចាប័ន ដើម្បីធានានូវប្រសិទ្ធភាពនៃការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងវិស័យសេដ្ឋកិច្ច។

ជាក់ស្តែងដូចជាការបង្កើតផែនការយុទ្ធសាស្ត្រនារីរតនៈត្រូវបានដឹកនាំ និងសម្របសម្រួលដោយក្រសួងកិច្ចការនារីដោយមានការគាំទ្រ និងចូលរួមចំណែកពីស្ថាប័នពាក់ពន្ធ័ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល។ នៅក្នុងឆ្នាំ២០១៤ ក្រសួងកិច្ចការនារីបានដាក់ចេញនូវការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា។សេចក្តីសង្ខេបគោលនយោបាយស្តីពីប៉ាន់ប្រម៉ាណយេនឌ័រនៅកម្ពុជា ជំពូកទី៣ ដែលនិយាយអំពីការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ត្រូវបានត្រួតពិនិត្យខ្លឹមសារជាមួយ និងកែ

[171] ដូច៧៩, ១។

សម្រួលផ្នែកបច្ចេកទេសដោយធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារអភិវឌ្ឍន៍ពិភពលោក និងUN Women ប្រចាំនៅកម្ពុជា។ [172]

កម្ពុជា បានផ្ដល់សច្ចាប័នទៅ លើអនុសញ្ញាស្ដីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទនៅថ្ងៃទី២២ កញ្ញា ឆ្នាំ១៩៩២ និងក្លាយទៅជារដ្ឋភាគីនៃអនុសញ្ញានៅថ្ងៃទី២២ តុលា ១៩៩២។[173] អនុសញ្ញានេះរួមបញ្ចូលវិធានការលើកកម្ពស់ស្ថានភាពស្ត្រី និងសិទ្ធិតាមយរយៈដំណើរការច្បាប់ និងការអនុវត្តរបស់កម្ពុជា។ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ជារៀងរាល់៤ឆ្នាំកម្ពុជាត្រូវធ្វើរបាយជាតិស្ដីពីការអនុវត្តអនុសញ្ញាCEDAW ទៅតាមកាន់គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងស្ត្រីភេទ របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ។ គណៈកម្មាធិការនេះមានភារៈកិច្ចត្រួតពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុសញ្ញានេះ និងផ្ដល់មកវិញនូវសេចក្ដីអង្កេតសន្និដ្ឋាន និងអនុសាសន៍ដល់រដ្ឋជាសមាជិក។នៅក្នុងឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើរបាយការណ៍ជាតិលើកទី៤ និងទី៥ ហើយបានទទួលមកវិញនូវសេចក្ដីអង្កេតសន្និដ្ឋានចំនួន៤២ចំនុចនៅក្នុងឆ្នាំ២០១៣។ [174] នៅក្នុងផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ របស់ក្រសួងកិច្ចការនារីបានបញ្ចូលនូវសេចក្ដីសន្និដ្ឋាននោះផងដែរ។

គេអាចនិយាយបានថា ស្ថាប័នសង្គមស៊ីវិល និងអង្គការអន្តរជាតិ ក៏ដូចជាអង្គការអន្តររដ្ឋាភិបាល ចូលរួមចំណែកយ៉ាងសំខាន់ក្នុងការគាំទ្រផ្នែកបច្ចេកទេសដល់រាជរដ្ឋាភិបាល ពិសេសក្រសួងកិច្ចការនារីក្នុងការបង្កើតច្បាប់នូវគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីផ្សេងៗក្នុងការលើកកម្ពស់ស្ថានភាពស្ត្រីកម្ពុជានៅក្នុងវិស័យសេដ្ឋកិច្ច។ ម៉្យាងវិញគឺការតាមដាននូវវឌ្ឍនភាពក្នុងការអនុវត្តសកម្មភាពទាំងនោះរួមបញ្ចូលទាំងសន្និសញ្ញាអន្តរជាតិដែលកម្ពុជាបានក្លាយជាសមាជិក ដើម្បីធ្វើការវាយតម្លៃ និងផ្ដល់ត្រលប់មកវិញនូវអនុសាសន៍សម្រាប់ការអភិវឌ្ឍន៍ការងារទាក់ទងនឹងការលើកកម្ពស់សមភាពយេនឌ័រ នៅក្នុងវិស័យសេដ្ឋកិច្ចឲ្យកាន់តែមានភាពប្រសើរឡើង។

[172] សេចក្ដីសង្ខេបគោលនយោបាយ៣, ២២។

[173] សេចក្ដីសង្ខេបគោលនយោបាយ១, ៥។

[174] សេចក្ដីសង្ខេបគោលនយោបាយ១, ៥។

# សេចក្តីសន្និដ្ឋាន

ការលើកម្ពស់ស្ថានភាពស្ត្រីកម្ពុជានៅក្នុងវិស័យសេដ្ឋកិច្ច ដើរតួយ៉ាងសំខាន់ក្នុងការចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ហើយការលើកកម្ពស់នេះសំដៅទៅលើការបង្កើនឱកាសឲ្យស្ត្រីចូលរួមនៅក្នុងការងារមានប្រាក់កម្រៃ ការអភិវឌ្ឍន៍អាជីវកម្ម កសិកម្ម និងសកម្មភាពអភិវឌ្ឍន៍ជីវភាពរស់នៅជនបទ។បន្ថែមទៅលើនេះ គឺការបង្កើនអត្ថប្រយោជន៍របស់ស្ត្រីកម្ពុជាទទួលបានពីការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការផ្តល់ឱកាសឲ្យស្ត្រីមានតួនាទីច្រើនក្នុងការធ្វើសេចក្តីសម្រេច។ នេះមានគោលបំណងបង្កើនប្រាក់ចំណូលសម្រាប់ស្ត្រី តាមរយៈការលើកកម្ពស់ការងារដែលមានប្រាក់កម្រៃសមរម្យ និងការអភិវឌ្ឍន៍អាជីវកម្មខ្នាតមីក្រូ តូច និងមធ្យមរបស់ស្ត្រី ។ ការបង្កើនឱកាសសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព រួមទាំងកំណើនប្រាក់ចំណូល និងកម្មសិទ្ធិលើទ្រព្យសម្បត្តិ ត្រូវបានរំពឹងទុកថានឹងជួយកាត់បន្ថយភាពងាររងគ្រោះរបស់ស្ត្រី ដូចជាការជួញដូរស្ត្រីភេទ ការធ្វើទេសន្តប្រវេសន៍មិនស្របច្បាប់ និងអំពើហិង្សាជាដើម។

ដើម្បីសម្រេចឲ្យបានការលើកកម្ពស់នេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតក្រសួងកិច្ចការនារីដែលជាយន្តការសម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ និងការបញ្ជ្រាបយេនឌ័រនៅក្នុងក្រសួង និងស្ថាប័ន។ ម្យ៉ាងវិញទៀតច្បាប់ គោលនយោបាយ និងផែនការជាក់លាក់ត្រូវបានបង្កើត បន្ថែមទៅលើនេះគឺការផ្តល់សច្ចាប័នទៅលើសទ្ធិសញ្ញាអន្តរជាតិផ្សេងៗ ដែលទាក់ទងនឹងការលើកកម្ពស់សិទ្ធិ និងស្ថានភាពស្ត្រី ។ការអនុវត្តច្បាប់ និងផែនការយុទ្ធសាស្ត្រទាំងនេះ ធ្វើឲ្យស្ថានភាពសេដ្ឋកិច្ចស្ត្រីកម្ពុជាល្អប្រសើរជាងមុន ជាពិសេសការផ្លាស់ប្តូរនូវផ្នត់គំនិតរបស់សង្គម បើសិនជាក្រឡេកទៅមើលប្រវត្តិរបស់កម្ពុជាដែលធ្លាប់ជាប្រទេសដែលមានវប្បធម៌មិនសូវឲ្យតម្លៃទៅលើស្ត្រី និងគិតថាស្ត្រីគឺជាភេទទន់ខ្សោយ តាមរយៈពាក្យមួយឃ្លា «ស្ត្រីវិលចង្ក្រានមិនជុំ»។

ថ្វីត្បិតតែកិច្ចខិតខំប្រឹងប្រែងទាំងនេះ បានលេចចេញនូវផ្លែផ្កាល្អប្រសើរជាងមុនក៏ដោយស្ត្រីកម្ពុជានៅតែជួបប្រទះបញ្ហាប្រឈមមួយចំនួន ដែលជាឧបសគ្គក្នុងការឲ្យស្ត្រីបញ្ចេញនូវសក្តានុភាពពេញលេញរបស់ខ្លួននៅក្នុងវិស័យសេដ្ឋកិច្ច។ បញ្ហាប្រឈមទាំងនោះទាក់ទងនឹងបញ្ហាកម្រិតអក្ខរកម្ម និងចំណេះដឹងទាប ដែលនាំឲ្យស្ត្រីកម្ពុជាជាច្រើនអាចត្រឹមតែធ្វើការងារកម្រិតទាប និងងាយរងគ្រោះ ដូចជាការងារនៅក្នុងវិស័យកាត់ដេរ និងការធ្វើទេសន្តប្រវេសន៍របស់ស្ត្រីទៅក្នុង និងក្រៅប្រទេសជាដើម។ ស្ត្រីកម្ពុជាក៏ជួបប្រទះនូវបញ្ហាផ្សេងៗជាច្រើនក្នុងការអភិវឌ្ឍន៍អាជីវកម្ម ការងារមានប្រាក់កម្រៃ ការអភិវឌ្ឍន៍កសិកម្ម និងជីវភាពរស់នៅជនបទ បើធៀបនឹងបុរស។ បញ្ហាដែលគួរឲ្យកត់សម្គាល់ទៀតនោះ គឺការអនុវត្តច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្ម

វិធីផ្សេងៗ របស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ស្រ្តីនៅក្នុងវិស័យសេដ្ឋកិច្ចនៅមានកម្រិតនៅឡើយ។ នេះគឺបណ្តាលមកពីការកង្វះខាតផ្នែកថវិកា និងបច្ចេសទេសរបស់ក្រសួងកិច្ចការនារី។

ដើម្បីចូលរួមកាត់បន្ថយបញ្ហា ដែលស្រ្តីជួបប្រទះនៅក្នុងវិស័យសេដ្ឋកិច្ច រាជរដ្ឋាភិបាលដែលមានក្រសួងកិច្ចការនារី បានសហការគ្នាយ៉ាងជិតស្និទ្ធិជាមួយបណ្តាស្ថាប័នរដ្ឋពាក់ពន្ធ័ សង្គមស៊ីវិល និងអង្គការអន្តរជាតិផ្សេងៗ។ ស្ថាប័នទាំងនេះព្យាយាមបន្តការបង្កើតនូវ គោលនយោបាយ ផែនការយុទ្ធសាស្រ្ត និងកម្មវិធីផ្សេងក្នុងផ្តល់ភាពអង់អាចដល់ស្រ្តីផ្នែកសេដ្ឋកិច្ច។ជាងនេះទៅទៀតគឺផ្តោតលើការលើកកម្ពស់ការសិក្សា ដល់ស្រ្តី និងក្មេងស្រី និងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ស្រ្តី ជាពិសសសម្រាប់ស្រ្តីនៅជនបទ និងក្រុមស្រ្តីងាយរងគ្រោះ ដើម្បីធ្វើជាចំណេះដឹងក្នុងការប្រកបរបរ និងធ្វើកិច្ចការងារផ្សេងៗ។ អ្វីដែលសំខាន់ជាងនេះទៅទៀត គឺការបង្កើនកាលានុវត្តភាពនិងលក្ខខណ្ឌការងារសម្រាប់ស្រ្តីឲ្យមានភាពល្អប្រសើរឡើង ដើម្បីកាត់បន្ថយការងារងាយរងគ្រោះការធ្វើទេសន្តប្រវេសន៍របស់ស្រ្តី និងអាចជំរុញឲ្យស្រ្តីធ្វើការងារដែលមានប្រាក់កម្រៃសមរម្យ នឹងល្អប្រសើរនៅក្នុងសង្គម។

ជារួមមកអាចនិយាយបានថា កិច្ចខំប្រឹងប្រែងទាំងនេះធ្វើឲ្យកម្ពុជាទទួលបានសមិទ្ធផលគួរជាទីកត់សម្គាល់ក្នុងការលើកកម្ពស់ស្ថានភាពស្រ្តីកម្ពុជានៅក្នុងវិស័យសេដ្ឋកិច្ច។ ជាពិសេស គឺមកពីនៅក្នុងរយៈពេលមួយទសវត្សន៍ចុងក្រោយនេះ ស្រ្តីកម្ពុជាខ្លួនឯងមានឆន្ទៈក្នុងការផ្លាស់ប្តូរនូវផ្នត់គំនិតរបស់សង្គម ដែលថាស្រ្តីគឺជាភេទទន់ខ្សោយរស់នៅពឹងផ្អែកលើបុរស ងាកមកស្វែងរកឯករាជ្យភាពរបស់ខ្លួន តាមរយៈការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ច។ ទោះបីជាយ៉ាងណាក៏ដោយបញ្ហាប្រឈម និងគម្លាតយេនឌ័ររបស់ស្រ្តីនៅតែមាននៅក្នុងសេដ្ឋកិច្ច។ នេះបានបង្ហាញថាការអនុវត្តច្បាប់ និងផែនការយុទ្ធសាស្រ្តផ្សេងៗនៅមានកម្រិតនៅមានកម្រិតនៅឡើយ។ ជាងនេះទៅទៀតគឺមកពីកម្ពុជាធ្លាប់ជាប្រទេសមានវប្បធម៌រើសអើងស្រ្តី ទោះបីជាមនុស្សភាគច្រើនបានផ្លាស់ប្តូរផ្នត់គំនិត ក៏នៅតែមានបុគ្គលមួយចំនួននៅប្រកាន់ភ្ជាប់គំនិតបែបនេះ រួមបញ្ចូលស្រ្តីខ្លួនឯងមួយចំនួនផងដែរ។ ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្រ្តីក្នុងកម្រិតទាប អាចបណ្តាលឲ្យសកគ្តានុភាពសេដ្ឋកិច្ចកម្ពុជាធ្លាក់ចុះ ឬនៅនឹងមួយកន្លែងគឺដោយសារតែស្រ្តីកម្ពុជាមានចំនួនច្រើនជាងពាក់កណ្តាលនៃប្រជាជនសរុប និងការចូលរួមដ៏ច្រើនរបស់ស្រ្តីនៅក្នុងសកម្មភាពសេដ្ឋកិច្ច។ ផ្ទុយទៅវិញការកើនឡើននៃការចូលរួមរបស់ស្រ្តី ការទទួលបានអត្ថប្រយោជន៍ និងតួនាទីក្នុងការធ្វើសេចក្តីសម្រេចរបស់ស្រ្តីនៅក្នុងសេដ្ឋកិច្ចនឹងធ្វើឲ្យស្ថានភាពសេដ្ឋកិច្ចស្រ្តីកម្ពុជា កាន់តែល្អប្រសើរឡើង។ នេះគឺជាកតាលីករដែលជំរុញឲ្យមានកំណើនសេដ្ឋកិច្ច ការកាត់បន្ថយវិសមភាពយេនឌ័រ និងភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា។

# អនុសាសន៍

ដើម្បីចូលរួមដោះស្រាយបញ្ហាប្រឈមរបស់ស្ត្រីកម្ពុជា នៅក្នុងវិស័យសេដ្ឋកិច្ចនាពេលបច្ចុប្បន្ននេះ ក្នុងនាមនាងខ្ញុំជានិស្សិតថ្នាក់បរិញ្ញបត្ររដ្ឋបាលសាធារណៈម្នាក់ សុំលើកជាអនុសាសន៍មួយចំនួនដូចខាងក្រោម៖

## សម្រាប់រាជរដ្ឋាភិបាល៖

- បង្កើនការគ្រប់គ្រងនូវធនធាន និងទ្រព្យរបស់ស្ត្រីដើម្បីជំរុញជីវភាពរស់នៅជនបទ និងការងារកសិកម្ម។ តាមរយៈការដោះស្រាយនូវបញ្ហាដែលស្ត្រីជួបប្រទះនៅក្នុងការចុះបញ្ជីដីធ្លី និងបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងកម្មវិធីតម្រង់ទិសស្តីពីកសិកម្ម និងការបណ្តុះបណ្តាលជំនាញ ដើម្បីឲ្យស្ត្រីយល់ដឹងពីបច្ចេកទេសថ្មីក្នុងការធ្វើកសិកម្ម ការទប់ស្កាត់គ្រោះមហន្តរាយ និងអាចស្វែងរកនូវប្រាក់ចំណូលបន្ថែមពីការងារបន្ទាប់បន្សំក្រៅកសិកម្ម។ ជាពិសេសសហការជាមួយវិស័យឯកជនដើម្បីស្វែងរកទីផ្សារលក់ផលិតផលរបស់ស្ត្រី។
- បន្តការគាំទ្រការបង្កើតអាជីវកម្មខ្នាតមីក្រូ តូច និងមធ្យមរបស់ស្ត្រី ហើយកំណត់នូវបញ្ហារបស់ស្ត្រីក្នុងការចុះបញ្ជីអាជីវកម្ម និងទ្រព្យសម្បត្តិនៅក្នុងឈ្មោះរបស់ខ្លួន។ ចំនុចនេះត្រូវរួមបញ្ចូលទាំងនៅក្នុងការបណ្តុះបណ្តាលរបស់មន្ត្រីជំនាញ។ ជាងនេះទៅទៀតគឺការលុបបំបាត់នូវសេវាក្រៅផ្លូវការ និងជំរុញឲ្យស្ត្រីចូលរួមនៅក្នុងវេទិកាធុរកិច្ចជាតិ និងអន្តរជាតិ ដើម្បីឲ្យស្ត្រីស្វែងយល់បន្ថែមទៀតពីមូលដ្ឋានគតិយុត្តទាក់ទងនឹងធុរកិច្ច អំពីភាពជាសហគ្រិន និងទីផ្សារកាន់តែទូលំទូលាយ។
- គាំទ្រនូវកំណើន នៃឱកាសការងារមានប្រាក់កម្រៃ និងធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌការងាររបស់ស្ត្រី។ តាមរយៈការអនុវត្តឲ្យតឹងរឹងនូវច្បាប់ការងារ និងធ្វើកែប្រែនូវច្បាប់ និងបទបញ្ញាផ្សេងៗដើម្បីលើកកម្ពស់សមភាពយេនឌ័រនៅក្នុងទីផ្សារការងារ និងដើម្បីធានាថាការរើសអើងប្រឆាំងរើសអើងស្ត្រីទាំងក្នុងទម្រង់ផ្ទាល់ និងមិនផ្ទាល់ត្រូវបានលុបបំបាត់។ ការលើកកម្ពស់នេះគឺធ្វើឡើងតាមរយៈការបន្តជំរុញឲ្យស្ត្រី និងក្មេងស្រីទទួលបានការសិក្សាអប់រំផ្លូវការ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ជាពិសេសសម្រាប់ស្ត្រីនៅជនបទ និងក្រុមស្ត្រីងាយរងគ្រោះ ដើម្បីចូលរួមកាត់បន្ថយការងារងាយរងគ្រោះសម្រាប់ស្ត្រី ការបង្កើនសមាមាត្រស្ត្រីនៅក្នុងការងារកម្រិតខ្ពស់ និងកាត់បន្ថយហានិភ័យរបស់ស្ត្រីទេសន្តប្រវេសន៍ និងការធ្វើទេសន្តប្រវេសន៍មិនស្របច្បាប់របស់ស្ត្រី។

**សម្រាប់សង្គមស៊ីវិលៈ**

- បន្តធ្វើការគាំទ្រមតិ បច្ចេកទេស និងមូលនិធិដល់រាជរដ្ឋាភិបាល និងសិក្សាបន្ថែមទៀតទៅលើបញ្ហាប្រឈមរបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច ដើម្បីបង្កើតគម្រោងឆ្លើយតបទៅនឹងបញ្ហានោះ។
- ផ្តល់ការអប់រំដល់ប្រជាជននៅមូលដ្ឋានឲ្យយល់ដឹងអំពីយេនឌ័រដើម្បីចូលរួមលុបបំបាត់នូវគំនិតសេសសល់រើសអើងស្ត្រី និងអំពើហិង្សាប្រឆាំងស្ត្រី។
- បញ្ជ្រាបនូវគំនិតវិជ្ជមាននៃការបែងចែកការងារផ្ទះសម្បែង និងការងារថែទាំស្មើរវាងបុរស និងស្ត្រី តាមរយៈការជំរុញលើកទឹកចិត្តបុរសឲ្យចេះជួយរំលែកការងារផ្ទះ តាមការបញ្ជ្រាបគំនិតទៅក្នុងការអប់រំតាមសាលា និងមូលដ្ឋាន និងការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ ប្រពន្ធ័បណ្តាញសង្គមជាដើម។នេះមានគោលបំណងដើម្បីកាត់បន្ថយបន្ទុករបស់ស្ត្រី និងអនុញ្ញាតឲ្យស្ត្រីពេលវេលាគ្រប់គ្រាន់ក្នុងការអភិវឌ្ឍន៍សមត្ថភាពរបស់ខ្លួន និងបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ច។

**សម្រាប់សង្គម ជាពិសេសស្ត្រីកម្ពុជាខ្លួនឯង**

- ស្ត្រីគួរមានឯករាជ្យភាពខាងផ្នែកហិរញ្ញវត្ថុ តាមរយៈការបង្កើនការសិក្សាអប់រំ និងការបណ្តុះបណ្តាលជំនាញ ដើម្បីការពារខ្លួនពីភាពងាយគ្រោះ និងនៅពេលមានបញ្ហាអកុសលកើតឡើងដូចជា៖ រមណៈភាពរបស់ស្វាមី ការលែងលះ ជាដើម។
- សង្គមគួរតែឲ្យតម្លៃស្មើគ្នារវាងបុរស និងស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច និងផ្តល់ឱកាសស្មើគ្នាដល់ក្មេងស្រី និងក្មេងប្រុស ទទួលបានការអប់រំ ជាពិសេសសនៅតាមទីជនបទ និងតួនាទីរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេច នៅក្នុងគោលបំណងឲ្យស្ត្រីបញ្ចេញនូវសេកត្តានុភាពពេញលេញរបស់ខ្លួននៅក្នុងវិស័យសេដ្ឋកិច្ច។

# គន្ថនិទ្ទេស

## ច្បាប់ជាតិ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។

- ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ, លេខនស/រកម/០៧១១/០១៣, ០៤ កក្កដា ២០១១។

- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ,លេខនស/រកត/០២០៨/០០៥, ១៥ កុម្ភៈ ២០០៨។

- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, លេខនស/រកម/១០០៥/០៣១, ២១ តុលា២០០៥។

- ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី, លេខនស/រកម/០១០៥/០០២, ២៤ មករា ២០០៥។

- ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន, លេខនស/រកម/០៩៩៩/១០, ១៨ កញ្ញា ១៩៩៩។

- ច្បាប់ស្តីពីការងារ, លេខជស/រកម/០៣៩៧/០១, ១៣ មិនា ១៩៩៧។

- ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា, លេខនស/រកត/០៩១៣/៩០៣, ២៤ កញ្ញា ២០១៣។

- ព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី, លេខនស/រកត០២/០១/០៣៦, ១៤ កុម្ភៈ ២០០១។

- ក្រសួងមុខងារសាធារណៈ. *តារាងស្ថិតិមន្ត្រីរាជការស៊ីវិល ដែលមានមុខតំណែងចាប់ពីថ្នាក់ការិយាល័យតាមក្រុង/ស្រុក/ខណ្ឌ រហូតដល់អគ្គនាយក និងថ្នាក់ស្មើឆ្នាំ២០១៥*, ២៧ មករា ២០១៦។

- ក្រសួងមុខងារសាធារណៈ. *តារាងស្ថិតិមន្ត្រីរាជការស៊ីវិលនៅតាមក្រសួង ស្ថាប័ននានាឆ្នាំ ២០១៥*, ២៧ មករា ២០១៦។

## ច្បាប់អន្តរជាតិ

- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, ០៣ មករា ១៩៧៦។

- អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ, ០៣ កញ្ញា ១៩៨១។

- សេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងប៉េកាំង, ១៥ កញ្ញា ១៩៩៥។

## ផែនយុទ្ធសាស្ត្រ និងសេចក្តីសង្ខេបគោលនយោបាយ

- រាជរដ្ឋាភិបាលកម្ពុជា. *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨*, ២០១៥។

- ក្រសួងកិច្ចការនារី. *នារីរតនៈទី៤៖ ផែនការយុទ្ធសាស្ត្រដើម្បីសមភាពយេនឌ័រ និងការបង្កើតភាពអង់អាចដល់ស្ត្រី* ឆ្នាំ២០១៤-២០១៨, ២០១៤។

- ក្រសួងកិច្ចការនារី. *សេចក្តីសង្ខេបគោលនយោបាយ១៖ បរិបទគោលនយោបាយ ស្ថាប័ន និងភាពជាដៃគូ*, ២០១៤។

- ក្រសួងកិច្ចការនារី. *សេចក្តីសង្ខេបគោលនយោបាយ៣, សេដ្ឋកិច្ច៖ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី*, ២០១៤។

- ក្រសួងកិច្ចការនារី. *សេចក្តីសង្ខេបគោលនយោបាយ៨៖ ភាពជាអ្នកដឹកនាំស្ត្រីក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ និងនយោបាយ*, ២០១៤។

- រាជរដ្ឋាភិបាលកម្ពុជា. *យុទ្ធសាស្ត្រចតុកោណ៖ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពកម្ពុជា ដំណាក់កាលទី៣*, ២០១៣។

- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ. *ផែនការបីឆ្នាំដំបូង(២០១១-២០១៣) នៃផែនការជាតិសម្រាប់ការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ*, ២០១១។

- ក្រសួងមុខងារសាធារណៈ. *ផែនការក្របខណ្ឌក្រសួងស្ថាប័នឆ្នាំ២០០៨*, ២០០៨។

## របាយការណ៍ និងជីណាល

- វិទ្យាស្ថានជាតិស្ថិតិ. ក្រសួងផែនការ, *Economic Census of Cambodia2011: Analysis of census results[ជំរឿនសេដ្ឋកិច្ចកម្ពុជា២០១១៖ ការវិភាគទៅលើលទ្ធផលជំរឿន]. Women in Business report No9*. ភ្នំពេញ៖ វិទ្យាស្ថានជាតិស្ថិតិ, ២០១៣។

- វិទ្យាស្ថានជាតិស្ថិតិ. ក្រសួងផែនការ និងអង្គការពលកម្មពិភពលោក. *អង្កេតកម្លាំងពលកម្ម និងពលកម្មកុមារកម្ពុជាឆ្នាំ២០១២៖ របាយការណ៍ស្តីពីកម្លាំងពលកម្ម*. ភ្នំពេញ៖ វិទ្យាស្ថានជាតិស្ថិតិ, ២០១៣។

- អង្គការកម្ពុជាអប់រំ និងថែទាំជំងឺអេដស៍(CHEC). *របាយការណ៍ប្រចាំឆ្នាំខែកក្កដា ២០១២ - មិថុនា ២០១៣*. ភ្នំពេញ៖ CHEC, ២០១៣។

- វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ. *Migration in Cambodia: Report of Cambodia Rural Urban migration Project (CRUM)[ទេសន្តប្រវេសន៍នៅកម្ពុជា៖ របាយការណ៍ស្តីពីគម្រោងទេសន្តប្រវេសន៍ទីក្រុង ជនបទកម្ពុជា].* ភ្នំពេញ៖ វិទ្យាស្ថានជាតិស្ថិតិ,២០១២។

- វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ. *Economic census of Cambodia 2011: National report on census result [ជំរឿនសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១១៖ របាយការណ៍ជាតិស្តីពីលទ្ធផលជំរឿន].* ភ្នំពេញ៖ វិទ្យាស្ថានជាតិស្ថិតិ, ២០១២។

- វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ និងអង្គការកសិកម្ម និងម្ហូបអាហារ(FAO). *National Gender profile of agricultural households [ប្រវត្តិយេនឌ័រជាតិស្តីពីគ្រួសារកសិកម្ម]. Report bases on the 2008 CSES*. ភ្នំពេញ៖ វិទ្យាស្ថានជាតិស្ថិតិ, ២០១០។

- អង្គការសហប្រជាជាតិ. *Comprehensive proposal for the composite entity for gender equality and the empowerment of women [សេចក្តីស្នើសុំលម្អិតស្តីពីការបង្កើតអង្គភាពសម្រាប់គាំទ្រសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី].* Report of the Secretary General .New York: UN, ២០១០។

- អង្គកាសហប្រជាជាតិ. *"គណៈកម្មាធិការទទួលបន្ទុកស្ថានភាពស្ត្រី".* Journal of the Economic and Social council. New York: UN, ១៣ កក្កដា ១៩៤៦។

## អត្ថស្រាវជ្រាវ និងលិខិតបោះពុម្ពផ្សាយផ្សេងទៀត

- ធនាគារអភិវឌ្ឍន៍អាស៊ី(ADB), *Promoting women's economic empowerment in Cambodia [ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៅកម្ពុជា].* Mandaluyong: ADB, ២០១៥។

- UN Women*. Out from behind closed doors: A study on domestic workers in Cambodia [នៅខាងក្រោយទ្វារដែលបានបិទ៖ ការសិក្សាទៅលើកម្មករធ្វើការតាមផ្ទះនៅកម្ពុជា].* Research paper. ភ្នំពេញ៖ UN Women, ២០១៥។

- វិទ្យាស្ថានជាតិស្ថិតិ,ក្រសួងផែនការ. *Cambodia Socio-economic Survey 2014[អង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា២០១៤]*, ២០១៥។

- អង្គសហប្រជាជាតិ. *Transforming Our World: The 2030 Agenda for Sustainable Development [ការផ្លាស់ប្តូរពិភពលោករបស់យើង៖ របៀបវីរៈសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃឆ្នាំ២០៣០]*, New York: United Nation, ២០១៥។

- អង្គការផ្សព្វផ្សាយសេវាសុខភាពអប់រំកម្ពុជា(CHEM) និងអង្គការកម្ពុជាអប់រំ និងថែទាំជំងឺអេដស៍(CHEC). *ការពង្រីកកាលានុវត្តភាពសេដ្ឋកិច្ចជីវភាពរស់នៅរបស់ស្ត្រីក្រីក្រ និងស្រីមានផ្ទុកមេរោគអេដស៍ ឬហៅកាត់ថាគម្រោងសេក្លូះ មគ្គុទេសរបស់គម្រោងសេក្លូ*. ភ្នំពេញះCHEM and CHEC, សីហា ២០១១។

## គេហទំព័រ

- គេហទំព័ររបស់UN Women អាចស្វែងរកបាននូវះ

http://asiapacific.unwomen.org/en/countries/cambodia/about-un-women-in-cambodia